# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដី នៅក្នុងឃុំ ក្រយា
# ស្រុកសន្ទុក ខេត្តកំពង់ធំ
# ឆ្នាំ២០១៧ ដល់ ២០៣២




រៀបចំដោយ : ក្រុមហ៊ុនផ្តល់សេវាកម្មSBK R&D
សម្របសម្រួលដោយ : ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីស្រុកសន្ទុក
គាំទ្របច្ចេកទេសដោយ : អង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ(NIO-MLMUPC) និងថ្នាក់ខេត្ត(PIO)
ឧបត្ថម្ភថវិកាដោយ : រាជរដ្ឋាភិបាលកម្ពុជា (RGC), ADB_Loan , GAFSP_Grant និងSCF_ADB

# មាតិកា


**អារម្ភកថា** .......... VII

**សេចក្តីផ្តើម** .......... 1

**ជំពូក ១៖ ព័ត៌មានស្តីពីស្ថានភាពឃុំក្រយា** .......... 3

**១.១. ស្ថានភាពឃុំ** .......... 3

១.១.១.ទីតាំងរដ្ឋបាលឃុំ .......... 3

១.១.២.ប្រជាសាស្ត្រ .......... 5

ក. ចំនួនប្រជាជន .......... 5

ខ.អត្រាកំណើន ដង់ស៊ីតេ និងរបាយប្រជាជន .......... 7

គ. ជនជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់ .......... 8

ឃ. របររកទទួលទាន .......... 8

ង. ចំណូលស្រុក និងចំណាកស្រុក .......... 10

១.១.៣. ស្ថានភាពសេដ្ឋកិច្ច .......... 11

ក. ប្រភពចំណូលចម្បង និងបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋ .......... 11

ខ. កម្រិតជីវភាពរស់នៅ ចំណូល ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ .......... 11

គ. ស្ថានភាពចំណុលសរុប និងអត្រាការប្រាក់ .......... 13

ឃ. ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់ ឬក្រោមរូបភាពផ្សេងៗ .......... 14

ង. ចំណូលពីប្រភពផ្សេងៗ .......... 14

១.១.៤.ស្ថានភាពសិក្សាធិការ .......... 14

ក. ស្ថានភាពអប់រំ .......... 14

ខ. ស្ថានភាពអក្ខរកម្ម .......... 15

គ. ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត .......... 16

១.១.៥.ស្ថានភាពសុខាភិបាល .......... 17

១.១.៦. ស្ថានភាពយេនឌ័រ .......... 19

**១.២.ស្ថានភាពភូមិសាស្ត្រ** .......... 21

១.២.១.ទីតាំងភូមិសាស្ត្រ .......... 21

១.២.២.អាកាសធាតុ (ពិពណ៌នាតាមរដូវកាល) .......... 27

១.២.៣.ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន .......... 27

១.២.៤. បរិក្ខាសាធារណៈ ...... 29

ក. ស្ថានភាពប្រើប្រាស់អគ្គិសនី ...... 29

ខ. ប្រព័ន្ធទឹកស្អាត ...... 30

**១.៣.ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន** ...... 31

១.៣.១.ស្ថានភាពការកាន់កាប់ និងគ្រប់គ្រង ...... 31

ក. ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ ...... 33

ខ. ដីកសិកម្ម ...... 34

ខ.១. ដីស្រែវស្សា ...... 34

ខ.២. ដីចម្ការ ...... 35

គ. ដីព្រៃ/គម្របព្រៃ ...... 36

ឃ. ផ្ទៃទឹក និងខ្សែទឹក ...... 38

១.៣.២.ផលិតកម្ម កសិកម្ម ...... 40

ក. ផលិតកម្មដំណាំស្បៀង ...... 40

ខ. ផលិតកម្មដំណាំរួមផ្សំ ...... 41

គ. ផលិតកម្មខ្វស្សាហកម្ម ...... 41

១.៣.៣.ធនធានធម្មជាតិ ...... 42

ក. ធនធានព្រៃឈើ ...... 42

ខ. ធនធានជលផល ...... 42

១.៣.៤.ធនធានដី ...... 43

**១.៤.ទីផ្សារ និងខ្សែសង្វាក់ផលិតផល** ...... 43

១.៤.១.ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ ...... 43

១.៤.២.ខ្សែសង្វាក់ និងចរាចរផលិតផល ...... 44

១.៤.៣.ឧបសគ្គ និងឱកាស ...... 46

**ជំពូក ២៖ ការវិភាគ តម្រូវការ សក្តានុពល និងឧបសគ្គសម្រាប់អនាគត** ...... 47

**២.១.តម្រូវការសម្រាប់អនាគត** ...... 47

២.១.១.ផែនការអភិវឌ្ឍន៍ឃុំ ...... 47

ក. ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ(២០១៧-២០២២) ...... 47

ខ. គម្រោងអភិវឌ្ឍន៍ផ្សេងៗទៀតដែលបានអនុម័តរួច ...... 50

២.១.២.ចំណោលប្រជាសាស្ត្រគិតទៅដល់ឆ្នាំ២០៣២ ........ 51

២.១.៣. តម្រូវការដីធ្លីជាមូលដ្ឋាន ........ 53

ក. ដីលំនៅឋាន ........ 53

ខ. ដីកសិកម្ម ........ 54

គ. ដីព្រៃឈើ ........ 54

ឃ. ធនធានទឹក ........ 55

ង. ហេដ្ឋារចនាសម្ព័ន្ធសង្គម និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត ........ 55

ង.១. វិស័យអប់រំ ........ 55

ង.២. វិស័យសុខាភិបាល ........ 57

ង.៣. អគ្គិសនី ........ 57

ង.៤. ទីលានចាក់សំរាម ........ 58

ង.៥. ដីកប់ខ្មោច ........ 58

ង.៦. ស្រះ និងអណ្ដូងទឹក ........ 59

**២.២. តំបន់សើប** ........ 59

**២.៣.ការប្រឈម** ........ 60

២.៣.១.ការប្រឈមដោយធម្មជាតិ ........ 60

ក. កំណើនប្រជាជន ........ 60

ខ. គ្រោះធម្មជាតិ ការរេចរឹលនៃធម្មជាតិ ........ 61

២.៣.២. ការប្រឈមដោយ ការអភិវឌ្ឍន៍ដែលពុំមាននិរន្តរភាព ........ 61

**២.៤. ឱកាស** ........ 61

២.៤.១.ដោយអំណោយផលពីធម្មជាតិ ........ 61

២.៤.២. ដោយបច្ចេកវិទ្យាថ្មីៗ ........ 62

២.៤.៣. ដោយគម្រោងវិនិយោគ ........ 62

**២.៥. បញ្ហា មូលហេតុ និងដំណោះស្រាយ** ........ 63

**ជំពូក ៣៖ ផែនការប្រើប្រាស់ដីសម្រាប់អនាគតឆ្នាំ២០១៧-២០៣២** ........ 67

**៣.១. តម្រូវការ ស្ថានភាព និងសក្តានុពលដីជាក់ស្តែង** ........ 67

៣.១.១. តម្រូវការដីទៅតាមប្រភេទ ........ 67

៣.១.២.ស្ថានភាពនៃដីធ្លី និងសក្តានុពល ........ 67

**៣.២.ការបែងចែកដីទៅតាមតម្រូវការប្រើប្រាស់** ........ 68

៣.២.១.ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ ........ 68
៣.២.២.ផែនទីប្រើប្រាស់ដីអនាគត........ 70
៣.២.៣.សេចក្តីអត្ថាធិប្បាយអំពីការប្រើប្រាស់ដីនាពេលអនាគត ........ 72
ក. ដីលំនៅឋាន ទួមិះ........ 72
ខ. ដីស្រែវស្សា........ 72
គ. ដីចម្ការ........ 74
ឃ. ព្រៃល្បោះ ........ 74
ង. ព្រៃស្រោង........ 75
ច. ស្ទឹងមានទឹកតាមរដូវ ........ 75
ឆ. ស្រះ ........ 75
ជ. បឹង........ 75
**៣.៣. ដំណោះស្រាយផ្សេងៗ ក្នុងករណីខ្វះខាតដីធ្លី** ........ 76
**៣.៤. កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព** ........ 76
៣.៤.១.កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព ........ 76
ក. ការគ្រប់គ្រងប្រព័ន្ធកសិកម្ម ........ 76
ខ. ការគ្រប់គ្រងព្រៃឈើ ផលផល និង ធនធានសំខាន់ៗផ្សេងៗទៀត ........ 78
៣.៤.២.គម្រោងគាំទ្រចាំបាច់ សម្រាប់គាំទ្រនិរន្តរភាព........ 79
**៣.៥. សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់ ២០៣២)** ........ 79

## បញ្ជីតារាង

តារាង 1៖ ស្ថានភាពទូទៅនៃឃុំ........ 3
តារាង 2៖ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្តាភូមិ ........ 6
តារាង 3៖ ស្ថិតិប្រជាជន ឆ្នាំ២០១៧ តាមក្រុមអាយុ........ 7
តារាង 4៖ ស្ថិតិប្រជាជនតាមបណ្តាឆ្នាំ និងការគណនាអត្រាកំណើនមធ្យម........ 8
តារាង 5៖ តារាងមុខរបរ........ 8
តារាង 6៖ តារាងមុខរបរបន្ទាប់បន្សំ ........ 10
តារាង 7៖ ស្ថិតិប្រជាជនផ្លាស់ប្តូរទីលំនៅក្នុងឆ្នាំ២០១៦-២០១៧ ........ 10
តារាង 8៖ ស្ថិតិប្រជាជនចំណាកស្រុក........ 11
តារាង 9៖ តារាងកម្រិតជីវភាពរបស់ប្រជាជន ........ 12
តារាង 10៖ ស្ថិតិសាលារៀន ស្ថានភាពអប់រំ និងសិក្សាធិការក្នុងឃុំឆ្នាំ២០១៧ ........ 15
តារាង 11៖ ស្ថិតិអ្នកមិនចេះអក្សរ ........ 16

តារាង 12៖ ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត .......... 16
តារាង 13៖ សុខភាពមាតានិងទារក .......... 17
តារាង 14៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព .......... 18
តារាង 15៖ ការវិភាគលើតួនាទីយេនឌ័រ ឃុំក្រយា .......... 20
តារាង 16៖ ដ្យាក្រាមពំនុះកាត់ទទឹង ឃុំក្រយា ស្រុកសន្ទុក .......... 23
តារាង 17៖ ប្រព័ន្ធធារាសាស្ត្រ .......... 25
តារាង 18៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ .......... 27
តារាង 19៖ ប្រព័ន្ធផ្លូវដឹកជញ្ជូន .......... 28
តារាង 20៖ ស្ថិតិអ្នកប្រើប្រាស់អគ្គិសនី .......... 29
តារាង 21៖ ស្ថិតិប្រភពទឹកប្រើប្រាស់ .......... 30
តារាង 22៖ តារាងរាយលម្អិតតាមប្រភេទនៃការប្រើប្រាស់ដីបច្ចុប្បន្ន ឃុំក្រយា .......... 33
តារាង 23៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស .......... 40
តារាង 24៖ តារាងអធិប្បាយពីឧបសគ្គ និងឧកាស .......... 41
តារាង 25៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស .......... 41
តារាង 26៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស .......... 42
តារាង 27៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស .......... 43
តារាង 28៖ ស្ថិតិផលិតផលស្រូវ និងតម្លៃ .......... 43
តារាង 29៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ទីផ្សារនិងខ្សែសង្វាក់ផលិតផល .......... 46
តារាង 30៖ ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ និងជម្រើសនៃការប្រាស់ដីធ្លីអនាគត .......... 47
តារាង 31៖ ចំណោលប្រជាសាស្ត្រនៃចំនួនគ្រួសារ និងប្រជាជនសរុប (០៥ឆ្នាំ) .......... 52
តារាង 32៖ ចំណោលប្រជាសាស្ត្រតាមក្រុមអាយុ (០៥ឆ្នាំ) .......... 52
តារាង 33៖ តម្រូវការដីសម្រាប់លំនៅឋានក្នុងឆ្នាំ២០៣២ .......... 53
តារាង 34៖ តម្រូវការដីសម្រាប់កសិកម្មក្នុងឆ្នាំ២០៣២ .......... 54
តារាង 35៖ កំណើនកុមារ តម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១៨ ដល់ ឆ្នាំ២០៣២ .......... 57
តារាង 36៖ បញ្ហាប្រឈម និងសក្តានុពល(ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ) .......... 63
តារាង 37៖ តារាងប្រើប្រាស់ដីនាពេលអនាគតឃុំ ក្រយា .......... 69
តារាង 38៖ តារាងផែនការផ្អែកហេដ្ឋារចនាសម្ព័ន្ធនាពេលអនាគត .......... 69
តារាង 39៖ តារាងផែនការផ្អែកសេវាកម្មនាពេលអនាគត .......... 70

## បញ្ជីដ្យាក្រាម

ដ្យាក្រាម 1៖ ស្ថិតិប្រជាជនឆ្នាំ ២០១៧ .......... 6
ដ្យាក្រាម 2៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព .......... 19
ដ្យាក្រាម 3៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ .......... 27
ដ្យាក្រាម 4៖ គំនូសតាងនៃការលំហូផលិតផលកសិកម្ម នៅក្នុងភូមិ និង ការប្រើប្រាស់ .......... 45

## បញ្ជីផែនទី


ផែនទី 1៖ ផែនទីទីតាំងឃុំក្រយា ស្រុកសន្ទុក ........ 4
ផែនទី 2៖ ផែនទីព្រំប្រទល់រដ្ឋបាល ឃុំក្រយា ........ 5
ផែនទី 3៖ ផែនទីសណ្ឋានដីឃុំក្រយា ........ 22
ផែនទី 4៖ តំបន់វិភាគប្រព័ន្ធគ្បេត្របរិស្ថានឃុំក្រយា ........ 22
ផែនទី 5៖ ផែនទីប្រព័ន្ធធារាសាស្ត្រ ឃុំក្រយា ........ 26
ផែនទី 6៖ ផែនទីហេដ្ឋារចនាសម្ព័ន្ធ ឃុំក្រយា ........ 29
ផែនទី 7៖ ផែនទីប្រើប្រាស់ដីសាមញ្ញ ឃុំក្រយា ........ 31
ផែនទី 8៖ ផែនទីប្រើប្រាស់ដីលម្អិត ឃុំក្រយា ........ 32
ផែនទី 9៖ ផែនទីគម្រោងអាទិភាព ឃុំក្រយា ........ 51
ផែនទី 10៖ ផែនទីតំបន់រសើប ........ 60
ផែនទី 11៖ ផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ ........ 66
ផែនទី 12៖ ផែនទីប្រើប្រាស់ដីពេលអនាគត ឃុំក្រយា ........ 71


## បញ្ជីរូបភាព


រូបភាព 1៖ សាលារៀន ........ 14
រូបភាព 2៖ មណ្ឌលសុខភាព ល្អក់ ........ 18
រូបភាព 3៖ ប្រឡាយរង ........ 26
រូបភាព 4៖ ប្រព័ន្ធគមនាគមន៍ ........ 28
រូបភាព 5៖ ដីលំនៅឋាន ភូមិ ........ 34
រូបភាព 6៖ ដីស្រែវស្សា ........ 35
រូបភាព 7៖ ដីចម្ការ ........ 36
រូបភាព 8៖ ព្រៃល្បោះ ........ 37
រូបភាព 9៖ ព្រៃស្រោង ........ 37
រូបភាព 10៖ ស្ទឹង ........ 38
រូបភាព 11៖ ស្រះទឹក ........ 39
រូបភាព 12៖ បឹង ........ 39
រូបភាព 13៖ ផលិតកម្មកសិកម្ម ........ 44

## អារម្ភកថា

ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ គឺ ជាឧបករណ៍មួយដ៏សំខាន់ក្នុងការជួយដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ផ្ទាល់ ក៏ដូចជាដល់អ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ នៅក្នុងការរួមចំណែកដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងសមធម៌ ជាពិសេសការគ្រប់គ្រងនិងប្រើប្រាស់ដី ដែលជាកត្តាស្នូលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងលើកស្ទួយដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ដូច្នេះក្រោយពេលមានផែនការប្រើប្រាស់ដីនេះអាជ្ញាធរគ្រប់ផ្នែកនៅថ្នាក់ក្រោមជាតិ ជាពិសេសអាជ្ញាធរដែនដី នឹងមានមូលដ្ឋានកាន់តែគ្រប់ជ្រុងជ្រោយក្នុងការរៀបចំបញ្ចូលផែនការប្រើប្រាស់នៅក្នុងឃុំ/សង្កាត់នេះទៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចថ្នាក់មូលដ្ឋាន ដោយធ្វើសមាហរណកម្មផែនការនៅថ្នាក់ស្រុក និងការអនុម័តនៅថ្នាក់រាជធានី/ខេត្ត ទៅតាមនីតិវិធី ដូចដែលបានធ្លាប់អនុវត្តក្នុងការកសាង ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច កន្លងមក ដោយមានគ្រប់ភាគីពាក់ព័ន្ធចូលរួមធ្វើការសម្រេច។ ក្នុងទឹកចិត្តសោមនស្សរីករាយជាអនេក ខ្ញុំមានកិត្តិយសសូមបង្ហាញនូវរបាយការណ៍បច្ចេកទេសស្តីពីផែនការប្រើប្រាស់ដីនៅក្នុងឃុំក្រយាមានចក្ខុវិស័យរហូតដល់ឆ្នាំ ២០៣២ ដែលក្រុមការងារបានប្រឹងប្រែងសិក្សាស្រាវជ្រាវ និងរៀបចំឡើងអស់រយៈពេលជាងពីរឆ្នាំកន្លងមកនេះ ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងកម្មវិធីកសិកម្មនិងសន្តិសុខស្បៀងពិភពលោក (GAFSP) ដែលបានគាំទ្រឧបត្ថម្ភថវិកា ក្រុមហ៊ុនផ្តល់សេវាកម្មមកជួយសិក្សារៀបចំផែនការនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលបានទទួលគ្រប់គ្រងគម្រោងនិងគាំទ្របច្ចេកទេស រដ្ឋបាលខេត្តកំពង់ធំ និងរដ្ឋបាលស្រុកសន្ទុក ដែលបានសម្របសម្រួលដល់កិច្ចដំណើរការរបស់គម្រោង និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមនៅក្នុងដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំក្រយានេះ។ ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ផែនការប្រើប្រាស់ដីនៅក្នុងឃុំក្រយានេះ នឹងបានចូលរួមចំណែកដល់ការអភិវឌ្ឍន៍ឃុំប្រកបដោយចីរភាព ថែមទាំងត្រូវបានប្រើប្រាស់ដោយមានការចូលរួម និងគាំទ្រយ៉ាងពេញទំហឹងពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ៕

ថ្ងៃ អង្គារ ១២កើត ខែ កត្តិក ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤

ក្រយា ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០២០

ប្រធានក្រុមប្រឹក្សាឃុំ និងជាមេឃុំក្រយា

កែវ ឆេង

# សេចក្តីផ្តើម

ស្ថិតនៅក្នុងបរិយាកាសណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញ និងច្បាប់ រាជរដ្ឋាភិបាល ដែលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាល បានបន្តធ្វើការជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ នៅក្នុងគោលដៅបង្កើន និងកែលម្អការផ្តល់គុណភាពសេវាសាធារណៈប្រកបទៅដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

ផ្អែកតាមយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលកម្ពុជា នៅក្រោមការដឹកនាំប្រកបទៅដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដាក់ចេញនូវគោលនយោបាយជាតិ ស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជាសំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍ តាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្រ្តរៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាន ឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្រ្តនីមួយៗ។

ឃុំក្រយា ជាឃុំមួយក្នុងចំណោមឃុំទាំង១០ ស្ថិតក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ ដែលមានតំបន់លំនៅឋានមួយផ្នែក និងមួយផ្នែកទៀតជាតំបន់កសិកម្ម មានផ្ទៃដីសរុបចំនួន ៨៨ ៥៨២,៥៩ ហិកតា មានព្រំប្រទល់ខាងជើងជាប់នឹង ឃុំស្រើង ស្រុកប្រាសាទសំបូរ និងឃុំទំរីង ស្រុកសណ្តាន់ ខាងត្បូងជាប់នឹង ឃុំអូរម្លូ ឃុំដងក្តារ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម និងឃុំគគីរធំ ឃុំបាក់ស្នា ឃុំក្រវ៉ា ឃុំចើងដើង ស្រុកបារាយណ៍ ខាងកើតជាប់ឃុំបឹងល្វា ស្រុកសន្ទុក ខាងលិចជាប់នឹង ឃុំកំពង់ថ្ម ឃុំទីពោ ស្រុកសន្ទុក មានគ្រួសារសរុបចំនួន ៣ ៨៩៥ គ្រួសារ មានប្រជាជនសរុប ១៦ ៤៨៩ នាក់ នៅក្នុងនោះស្ត្រី ៨ ៣០៤ នាក់ ហើយមានប្រជាពលរដ្ឋ ៨៧% ជាកសិករ។ ឃុំក្រយា មានផ្ទៃដីស្រែសរុបទំហំ ២ ៤៦៨,១០ ហិកតា គឺជាផ្ទៃដីដែលមានទំហំវិសាលភាពស្រួបអស់ ៣% នៃផ្ទៃដីសរុបរបស់ឃុំ ដែលជាបង្អែកដ៏មានសក្តានុពលតែមួយគត់សម្រាប់ការអភិវឌ្ឍន៍ឃុំក្រយា ប្រកបដោយចីរភាព។

ក្នុងគោលដៅធានាការគ្រប់គ្រងនិងអភិវឌ្ឍឃុំក្រយា ប្រកបដោយចីរភាពនេះ គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ និងស្រុកសន្ទុក ព្រមទាំងក្រុមប្រឹក្សាឃុំក្រយា ក្រោមការទទួលសិទ្ធិផ្តល់សេវាកម្មរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំក្រយាដោយក្រុមហ៊ុន SBK Co.LTd និងមានការគ្រប់គ្រងគាំទ្របច្ចេកទេសដោយអង្គភាពអនុវត្តគម្រោងនៅថ្នាក់ខេត្ត (PIO) និងអង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ (NIO) នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងមានការគាំទ្រនិងឧបត្ថម្ភថវិកាពីរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី បានរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំក្រយា ចក្ខុវិស័យឆ្នាំ ២០៣២ សម្រាប់តម្រង់ទិសដល់ការអភិវឌ្ឍន៍ឃុំ ពាក់ព័ន្ធការប្រើប្រាស់ដីនៅក្នុងឃុំក្រយា ឆ្លើយតបទៅនឹងកំណើនប្រជាសាស្រ្ត ដើម្បីជាមូលដ្ឋានជួយដល់ក្រុមប្រឹក្សាឃុំក្រយាផ្ទាល់ ក៏ដូចជា អ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ នៅក្នុងការរួមចំណែកដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងសមធម៌ ដែលក្នុងនោះមានការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដែលជាកត្តាស្នូលនៃការអភិវឌ្ឍន៍ឃុំ ធ្វើឱ្យជីវភាពប្រជាពលរដ្ឋមានភាពប្រសើរឡើងរួចផុតពីភាពក្រីក្រ ជាពិសេសការប្រើប្រាស់ដីកសិកម្មនៅក្នុងឃុំក្រយាឱ្យអស់សក្តានុពលដែលមានក្នុងការផលិតស្រូវ ដើម្បីបង្កើនការនាំចេញអង្ករឱ្យបានច្រើននៅពេលខាងមុខ ដើម្បីអាចឆ្លើយតបបានទៅនឹងគោលនយោបាយ ស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្កររបស់រាជរដ្ឋាភិបាល នៅសល់ពីការហូបចុកតាមរយៈការប្រើប្រាស់ផែនការប្រើប្រាស់ដីនៅក្នុងឃុំក្រយានេះ ធ្វើជាមូលដ្ឋានបង្អែក សម្រាប់រៀបចំផែនការអភិវឌ្ឍន៍ឃុំនៅតាមអាណត្តិនីមួយៗរបស់ខ្លួន។

ផែនការប្រើប្រាស់ដីនៅក្នុងឃុំក្រយា ត្រូវបានរៀបចំឡើង ដោយមានការសិក្សាស្រាវជ្រាវច្បាស់លាស់ទៅលើកត្តាភូមិសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថាន ព្រមទាំងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួន ដែលពាក់ព័ន្ធទៅនឹងការរៀបចំដែនដី នគរូបនីយកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានជាអាទិ៍ ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី នគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ និងអនុក្រឹត្យស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន។ ចំពោះនីតិវិធីនៃការរៀបចំផែនការនេះវិញ ត្រូវបានរៀបចំឡើងដោយផ្អែកទៅលើអនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីក្នុងឃុំ/សង្កាត់ ព្រមទាំងប្រកាសរួមស្តីពីនីតិវិធីលម្អិត សម្រាប់រៀបចំអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ និងឯកសារណែនាំអនុវត្តស្តីពីការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ ដែលមានដំណើរការរៀបចំផែនការដូចមានសង្ខេបក្នុងដ្យាក្រាមខាងក្រោម។

ដ្យាក្រាម៖ ដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់




សម្គាល់៖ ប្រអប់បង្ហាញទំហំការងារដែលត្រូវអនុវត្តតាមឯកសារណែនាំ

# ជំពូក ១៖ ព័ត៌មានស្តីពីស្ថានភាពឃុំក្រយា

## ១.១. ស្ថានភាពឃុំ

កាលពីមុនសម័យអង្គរ មានព្រះមហាក្សត្រមួយព្រះអង្គ បានយាងធ្វើដំណើរមកដល់តំបន់ភាគខាងជើងនៃឃុំ ជាមួយនឹងពលសេនា និងមន្ត្រីរបស់ព្រះអង្គ ដើម្បីសោយក្រយានៅទីនោះ បន្ទាប់មកទ្រង់ក៏បានយាងបន្តដំណើរទៅកាន់ភូមិកំពង់ស្តេចទៀត កន្លែងដែលព្រះអង្គគង់សោយក្រយាស្ងោយនោះ ក៏មានប្រជាជនមករស់នៅជាបន្តបន្ទាប់ ហើយក៏បាននាំគ្នាហៅតំបន់នេះថា **"ភូមិក្រយា"** ។ អំណើះតមកដល់រៀងបច្ចុប្បន្ននេះ ឃុំក្រយានៅតែរក្សាឈ្មោះថា **"ឃុំក្រយា"**ដដែល ទៅតាមប្រកាសរបស់ក្រសួងមហាផ្ទៃលេខ៤៩៣ប្រ.ក ចុះថ្ងៃទី ៣០ មេសា ២០០១។

### ១.១.១.ទីតាំងរដ្ឋបាលឃុំ

ឃុំក្រយា គឺជាឃុំមួយនៅក្នុងចំណោមឃុំទាំង ១០ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរដ្ឋបាលរបស់ស្រុកសន្ទុក ខេត្តកំពង់ធំ មានផ្ទៃដីសរុបចំនួន ៨៨ ៥៨២,៥៩ហិកតា (ទិន្នន័យ GIS) និងមានព្រំប្រទល់ជាប់នឹង៖

- ខាងជើង ជាប់នឹង ឃុំស្រើង ស្រុកប្រាសាទសំបូរ និងឃុំទំរីង ស្រុកសណ្តាន់
- ខាងត្បូង ជាប់នឹង ឃុំអូរម្លូរ ឃុំដងក្តារ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម និងឃុំគគីរធំ ឃុំបាក់ស្នា ឃុំក្រវ៉ា ឃុំចើងដើង ស្រុកបារាយណ៍ ។
- ខាងកើត ជាប់នឹង ឃុំបឹងល្វា ស្រុកសន្ទុក
- ខាងលិច ជាប់នឹង ឃុំកំពង់ថ្ម ឃុំទីពោ ស្រុកសន្ទុក។

ឃុំនេះ មានភូមិចំនួន១៤ គឺ ភូមិក្រយា ភូមិទក់ ភូមិត្រពាំងព្រីង ភូមិដងក្តារ ភូមិតាម៉ិញ ភូមិសុភមង្គល ភូមិថ្មសំលៀង ភូមិត្រពាំងឫស្សី ភូមិអូរទឹកថ្លា ភូមិសែនសេរីមង្គល ភូមិឈើទាលជ្រុំ ភូមិភ្នំប្រាច់ ភូមិសូងសាង និងភូមិបន្ទាយរងៀង។

តារាង 1៖ ស្ថានភាពទូទៅនៃឃុំ

| **ខេត្ត** | **កំពង់ធំ** | **លេខកូដខេត្តៈ ០៦** |
|---|---|---|
| **ស្រុក** | **សន្ទុក** | **លេខកូដស្រុកៈ ០៦០៧** |
| **ឃុំ** | **ក្រយា** | **លេខកូដឃុំៈ ០៦០៧០៥** |
| ចំនួន១៤ភូមិ | ១.ភូមិក្រយា | លេខកូដភូមិៈ ០៦០៧០៥០១ |
| | ២.ភូមិទក់ | លេខកូដភូមិៈ ០៦០៧០៥០២ |
| | ៣.ភូមិត្រពាំងព្រីង | លេខកូដភូមិៈ ០៦០៧០៥០៣ |
| | ៤.ភូមិដងក្តារ | លេខកូដភូមិៈ ០៦០៧០៥០៤ |
| | ៥.ភូមិតាម៉ិញ | លេខកូដភូមិៈ ០៦០៧០៥០៥ |
| | ៦.ភូមិសុភមង្គល | លេខកូដភូមិៈ ០៦០៧០៥០៦ |
| | ៧.ភូមិថ្មសំលៀង | លេខកូដភូមិៈ ០៦០៧០៥០៧ |
| | ៨.ភូមិត្រពាំងឫស្សី | លេខកូដភូមិៈ ០៦០៧០៥០៨ |

| | | |
|---|---|---|
| | ៩.ភូមិអូរទឹកថ្លា | លេខកូដភូមិៈ ០៦០៧០៥០៩ |
| | ១០.ភូមិសែនសេរីមង្គល | លេខកូដភូមិៈ ០៦០៧០៥១០ |
| | ១១.ភូមិឈើទាលជ្រុំ | លេខកូដភូមិៈ ០៦០៧០៥១១ |
| | ១២.ភូមិភ្នំប្រាថ់ | លេខកូដភូមិៈ ០៦០៧០៥១២ |
| | ១៣.ភូមិសូងសាង | លេខកូដភូមិៈ ០៦០៧០៥១៣ |
| | ១៤.ភូមិបន្ទាយរងៀង | លេខកូដភូមិៈ ០៦០៧០៥១៤ |

ប្រភពទិន្នន័យៈ *CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ក្រយា ខែឧសភា ឆ្នាំ២០១៨*

ផែនទី 1៖ ផែនទីទីតាំងឃុំក្រយា ស្រុកសន្ទុក



ផែនទី 2៖ ផែនទីព្រំប្រទល់រដ្ឋបាល ឃុំក្រយា




## ១.១.២.ប្រជាសាស្ត្រ

### ក. ចំនួនប្រជាជន

នៅក្នុងរដ្ឋបាលឃុំក្រយាចែកចេញជា ១៤ ភូមិ មានគ្រួសារសរុបចំនួន ៣៨៩៥ គ្រួសារ និងប្រជាជនសរុប ១៦ ៤៨៩នាក់ ក្នុងនោះស្ត្រី ៨ ៣០៤នាក់ ហើយប្រជាជនមានអាយុពី១៨ឆ្នាំឡើងទៅមាន ១០០០២នាក់ ក្នុងនោះមានស្ត្រីចំនួន ៥ ១២៩នាក់ ។ នៅក្នុងឃុំនេះ ភូមិដែលមានប្រជាជនច្រើនជាងគេ គឺភូមិដងក្ដារ ដែលមានប្រជាជនចំនួន ៨១៣គ្រួសារ ស្មើនឹង ២៤ភាគរយ និងមានប្រជាជនសរុបចំនួន ៣ ៣០៣នាក់ ក្នុងនោះមានស្ត្រីចំនួន ១ ៦២៧នាក់ ហើយប្រជាជន ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅមានចំនួន ១ ៨៥៣នាក់ ក្នុងនោះស្ត្រីចំនួន ៩៤២នាក់ ចំណែកភូមិដែលមានប្រជាជនតិចជាងគេ គឺភូមិភ្នំប្រាច់ ដែលមានប្រជាជន ១៩១គ្រួសារ ស្មើនឹង ៤,៩ភាគរយ និងមានប្រជាជនសរុបចំនួន ៤៩៩នាក់ ក្នុងនោះមានស្ត្រីចំនួន ២៤០នាក់ ហើយប្រជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅមានចំនួន ២៧១នាក់ ក្នុងនោះមានស្ត្រី ១៣៨នាក់ ។

តារាង 2៖ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្តាភូមិ

| ឈ្មោះភូមិ | គ្រួសារ | គិតជា% | មនុស្ស | | | ១៨ឆ្នាំឡើង | | |
|---|---|---|---|---|---|---|---|---|
| | | | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| ក្រយា | ៣១៣ | ៨ | ១៤៥១ | ៧១០ | ៧៤១ | ៨៨១ | ៤៣៦ | ៤៤៥ |
| ទក់ | ៣៥៨ | ៩,២ | ១៤៨១ | ៧៣៣ | ៧៤៨ | ៩៩៤ | ៤៧៦ | ៥១៨ |
| ត្រពាំងព្រីង | ១៨៧ | ៤,៨ | ៩៥៤ | ៤៦២ | ៤៩២ | ៥៥៦ | ២៦៣ | ២៩៣ |
| ដងក្តារ | ៨១៣ | ២០,៩ | ៣៣០៣ | ១៦៧៦ | ១៦២៧ | ១៨៥៣ | ៩១១ | ៩៤២ |
| តាម៉ិញ | ២៨១ | ៧,២ | ១៣៧៨ | ៦៥៧ | ៧២១ | ៩២៤ | ៤៣៩ | ៤៨៥ |
| សុភមង្គល | ២៤៧ | ៦,៣ | ១១១៤ | ៥៥២ | ៥៦២ | ៧៦៦ | ៣៦១ | ៤០៥ |
| ថ្មសំលៀង | ២២៨ | ៥,៩ | ១០០៦ | ៥០៧ | ៤៩៩ | ៦២៣ | ៣១១ | ៣១២ |
| ឈើទាលជ្រុំ | ៣០៨ | ៧,៩ | ១២៦៤ | ៦៣៣ | ៦៣១ | ៧២១ | ៣៥២ | ៣៦៩ |
| ត្រពាំងឬស្សី | ២១៨ | ៥,៦ | ៩៨៥ | ៤៩៩ | ៤៨៦ | ៥៦៩ | ២៧៩ | ២៩០ |
| អូរទឹកថ្លា | ១៥៨ | ៤,១ | ៦៦០ | ៣១១ | ៣៤៩ | ៣៧៨ | ១៧៩ | ១៩៩ |
| សែនសិរីមង្គល | ២៧៦ | ៧,១ | ១១១៧ | ៥៥៧ | ៥៦០ | ៦៨៨ | ៣៤៤ | ៣៤៤ |
| សូងសាង | ១៤០ | ៣,៦ | ៥៦៧ | ២៧៦ | ២៩១ | ៣៤៥ | ១៧០ | ១៧៥ |
| ភ្នំប្រាច់ | ១៩១ | ៤,៩ | ៤៩៩ | ២៥៩ | ២៤០ | ២៧១ | ១៣៣ | ១៣៨ |
| បន្ទាយរងៀង | ១៧៧ | ៤,៥ | ៧១០ | ៣៥៣ | ៣៥៧ | ៤៣៣ | ២១៩ | ២១៤ |
| **សរុប** | **៣ ៨៩៥** | **១០០** | **១៦ ៤៨៩** | **៨ ១៨៥** | **៨ ៣០៤** | **១០ ០០២** | **៤ ៨៧៣** | **៥ ១២៩** |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ក្រយា ខែឧសភា ឆ្នាំ២០១៨*

ដ្យាក្រាម 1៖ ស្ថិតិប្រជាជនឆ្នាំ ២០១៧




បើយោងតាមតារាងស្ថិតិប្រជាជនតាមក្រុមអាយុឆ្នាំ ២០១៧ នៅក្នុងឃុំក្រយា បានបង្ហាញឱ្យឃើញថា ប្រជាជនពេញកម្លាំងពលកម្ម ដែលមានអាយុចាប់ពី ២៥ ឆ្នាំ ដល់ ៦០ ឆ្នាំ មានចំនួន ៤ ៣៨៨នាក់ ស្មើប្រហាក់ប្រហែល ៣៩ភាគរយ នៃប្រជាជនសរុប គឺលើស ១/៣ បន្តិច ក្រៅពីនេះមានអាយុពីកើតដល់ ២៤ឆ្នាំ មានចំនួន ៥ ៧៧០នាក់ ស្មើប្រហាក់ប្រហែល ៥២ភាគរយ នៃប្រជាជនសរុប និងប្រជាជនមានអាយុចាប់ពី ៦១ ឆ្នាំឡើង

ដែលជាអ្នកបានចូលនិវត្តន៍បាត់បង់សមត្ថភាពការងារមានចំនួន ៩៩៤នាក់ ស្មើប្រហាក់ប្រហែល ០៩ភាគរយ នៃប្រជាជនសរុប ។ ដូច្នេះសន្និដ្ឋានបានថា នៅក្នុងឃុំក្រយា មនុស្សពេញកម្លាំងពលកម្មមួយនាក់រកចំណូលបានគិតជាមធ្យមត្រូវចិញ្ចឹមមនុស្សជិតពីរនាក់បន្ថែម ។

តារាង 3៖ ស្ថិតិប្រជាជន ឆ្នាំ២០១៧ តាមក្រុមអាយុ

| តាមក្រុមអាយុ | ២០១៧ | | | ផ្សេងៗ |
|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | |
| អាយុពី០-២ឆ្នាំ | ៤៨០ | ២៣៦ | ២៤៤ | កុមារ |
| អាយុពី៣-៤ | ៦១៥ | ៣២៨ | ២៨៧ | អាយុចូលរៀនសាលាមត្តេយ្យ |
| អាយុពី៥ឆ្នាំ | ៤៨៤ | ២៤៦ | ២៣៨ | អាយុចូលរៀនសាលាមត្តេយ្យ |
| អាយុពី៦ឆ្នាំ | ៤៤៧ | ២៤២ | ២០៥ | អាយុចូលរៀនសាលាបឋម |
| អាយុពី៧-១១ឆ្នាំ | ៧៥៩ | ៣៨៣ | ៣៧៦ | អាយុចូលរៀនសាលាបឋម |
| អាយុពី១២-១៤ឆ្នាំ | ៨៧៨ | ៤៥២ | ៤២៦ | អាយុចូលរៀនអនុវិទ្យាល័យ |
| អាយុពី១៥-១៧ឆ្នាំ | ៨៦៣ | ៤៣៤ | ៤២៩ | អាយុចូលរៀនវិទ្យាល័យ |
| អាយុពី១៨-២៤ឆ្នាំ | ១២៤៤ | ៥៩៧ | ៦៤៧ | អាយុចូលរៀនមហាវិទ្យាល័យ |
| អាយុពី២៥-៣៥ឆ្នាំ | ១៧២២ | ៨៦៦ | ៨៥៦ | អាយុពេញពលកម្ម |
| អាយុពី៣៦-៤៥ឆ្នាំ | ១៣៩៨ | ៦៦៤ | ៧៣៤ | អាយុពេញពលកម្ម |
| អាយុពី៤៦-៦០ឆ្នាំ | ១២៦៨ | ៦១៤ | ៦៥៤ | អាយុពេញពលកម្ម |
| អាយុពី៦១ឆ្នាំឡើង | ៩៩៤ | ៤៥៥ | ៥៣៩ | អាយុចូលនិវត្តន៍ |
| **សរុប** | **១១ ១៥២** | **៥ ៥១៧** | **៥ ៦៣៥** | |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ក្រយា ខែឧសភា ឆ្នាំ២០១៨*

### ខ.អត្រាកំណើន ដង់ស៊ីតេ និងរបាយប្រជាជន

ដោយយោងទៅតាម CDB ឆ្នាំ២០១៧ បានឱ្យដឹងថា អត្រាកំណើនប្រជាជនជាមធ្យមក្នុងអំឡុងពេលចន្លោះពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៧ មានចំនួន ១,៩៦ ភាគរយ ដោយសង្កេតឃើញថាមានការធ្លាក់ចុះខ្លាំងនៅក្នុងឆ្នាំ២០១៤ គឺមានអត្រាកំណើនប្រជាជនចំនួន ០,៨៤ ភាគរយ មូលហេតុនៃការធ្លាក់ចុះនេះដោយសារមានការផ្លាស់ប្តូរលំនៅឋានចេញ ចំណាកស្រុក ការពន្យាកំណើត មរណភាពកុមារ និងដោយសារកត្តាគ្រោះថ្នាក់ចរាចរណ៍ ជម្ងឺ។ល។ ប៉ុន្តែអត្រាកំណើននៅឆ្នាំ២០១៦ មានការកើនឡើងខ្លាំងជាងគេ គឺ ២,៤៦ ភាគរយ មូលហេតុនៃការកើនឡើងនេះដោយសារតែមានការផ្លាស់ប្តូរទីលំនៅចូលតាមរយៈអាពាហ៍ពិពាហ៍ និងការកើតថ្មី ។ តែបើពិនិត្យទៅលើដំណើរទូទៅប្រជាជននៅឆ្នាំ២០១៩ បានឱ្យដឹងថា អត្រាកំណើនជាមធ្យមនៅក្នុងអំឡុង ១០ឆ្នាំ (២០០៨-២០១៨) នៅក្នុងខេត្តកំពង់ធំ មានចំនួន ០,៦ ភាគរយ តិចជាងអត្រាកំណើនខាងលើ។ ដូច្នេះយើងបានកំណត់យកអត្រាកំណើនប្រជាជនជាមធ្យមប្រចាំឆ្នាំនៅក្នុងឃុំក្រយា ១,៩៦ភាគរយ ជាបានការ ដើម្បីប្រើប្រាស់ក្នុងការព្យាករណ៍កំណើនប្រជាជនក្នុងឃុំ ។

នៅក្នុងឆ្នាំ២០១៧ ឃុំក្រយា មានដង់ស៊ីតេប្រជាជនជាមធ្យមចំនួន ២៨៨នាក់/គម$^{២}$ ដោយការរស់នៅរបស់ប្រជាពលរដ្ឋភាគច្រើនតាំងលំនៅឋានជាលក្ខណៈរាយប៉ាយតាមភូមិ នៅតាមដងផ្លូវសំខាន់ៗនៅក្នុងឃុំ ។

តារាង 4៖ ស្ថិតិប្រជាជនតាមបណ្តាឆ្នាំ និងការគណនាអត្រាកំណើនមធ្យម

| ចំនួន | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | កំណើនមធ្យម |
|---|---|---|---|---|---|---|---|
| ប្រជាជនសរុប | ១៣៣៥៣ | ១៣៦៤៤ | ១៣៧៥៨ | ១៤០៨៣ | ១៤៤៣០ | ១៤៧១៣ | |
| កំណើនមធ្យម(%) | | ២,១៨ | ០,៨៤ | ២,៣៦ | ២,៤៦ | ១,៩៦ | ១,៩៦ |

ប្រភពទិន្នន័យ៖ *ក្រុមការងារCL UP ឆ្នាំ២០១៩*

<u>☞ចំណាំ</u>

- អត្រាកំណើនសម្រាប់ចន្លោះឆ្នាំនីមួយៗ៖ (ឆ្នាំចុងក្រោយ-ឆ្នាំដំបូង)x១០០/ឆ្នាំដំបូង
- អត្រាកំណើនមធ្យមប្រចាំឆ្នាំ៖ (បូកសរុបអត្រាកំណើនតាមឆ្នាំនីមួយ/ចំនួនឆ្នាំ)

### គ. ជនជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់

នៅក្នុងឃុំក្រយាមានជនជាតិខ្មែរ និងខ្មែរកាត់ចិន ដែលភាគច្រើនពួកគាត់កាន់សាសនាព្រះពុទ្ធ គោរពប្រពៃណី និងទំនៀមទម្លាប់បែបខ្មែរ ដូចជា ពិធីរៀបមង្គលការ ប្រារព្ធពីធីបុណ្យទាននៅតាមវត្តអារាម និងតាមផ្ទះ និមន្តព្រះសង្ឃសូត្រមន្តតាមផ្ទះ ពិធីបូជាសព និងមួយចំនួនតិចមានទំនៀមទម្លាប់បែបចិន ដូចជា ពិធីសែនព្រេនដូនតា ពីធីបញ្ចុះសព ។ និយាយជារួមប្រជាជននៅក្នុងឃុំក្រយា តែងតែប្រារព្ធពិធីបុណ្យទានតាមប្រពៃណីទំនៀមទំលាប់ពីបុរាណរៀងមក តាមជំនឿបែបខ្មែរ បែបចិនតិចតួច ។

### ឃ. របររកទទួលទាន

បើយោងទៅតាមទិន្នន័យមន្ទីរផែនការនៅឆ្នាំ២០១៧ នៅក្នុងតារាងខាងក្រោម បានបង្ហាញឱ្យឃើញថា នៅក្នុងឃុំក្រយា អ្នកមានមុខរបរចំបងមានចំនួន ៧ ០១៨នាក់ ស្មើនឹង ៩១,៨ភាគរយ នៅក្នុងនោះប្រជាពលរដ្ឋភាគច្រើនប្រកបមុខរបរកសិកម្ម ជាចម្បង ដែលមានចំនួន ៦ ១០០នាក់ ស្មើនឹង ៨៦,៩ភាគរយ អ្នកប្រកបមុខរបរសិប្បកម្មមានចំនួន ១២នាក់ ស្មើនឹង ០,២ភាគរយ និងអ្នកមានមុខរបរសេវាកម្មមានចំនួន ៩០៦នាក់ ស្មើនឹង ១២,៩ភាគរយ ហើយមុខទាំងនោះមានច្រើនប្រភេទទៅតាមចំណង់ចំណូលចិត្ត និងជំនាញរបស់ពួកគាត់ ប៉ុន្តែមុខរបរដែលមានប្រជាពលរដ្ឋធ្វើច្រើនជាងគេ គឺធ្វើស្រែ និងមុខរបរផ្សេងៗទៀត ដូចជា ធ្វើចំការ ដាំបន្លែ នេសាទ ចិញ្ចឹមសត្វ សិប្បកម្មគ្រឿងសង្ហារឹម(លក្ខណៈគ្រួសារ) លក់ដូរនិងជំនួញ ជាជាងជួសជុល ដឹកញ្ជូន ស៊ីឈ្នួលក្នុងវិស័យកសិកម្ម កម្មករសំណង់ ការងារវិស័យឯកជន(កម្មកររោងចក្រ បុគ្គលិក អង្គការ) និងមន្ត្រីរាជការជាដើម។

តារាង 5៖ តារាងមុខរបរ

| បរិយាយ | ២០១៧ |
|---|---|
| សរុបអ្នកមានមុខរបរចម្បង | ៧ ០១៨នាក់ |
| %សរុបអ្នកមានមុខរបរចម្បង | ៩១,៨% |
| %ស្រីមានមុខរបរចម្បង(គិតក្នុងស្រី១៨-៦០ឆ្នាំ) | ៧៤,៦% |
| %ប្រុសមានមុខរបរចម្បង(គិតក្នុងប្រុស១៨-៦០ឆ្នាំ) | ៨២,៤% |
| **សរុបអ្នកមានមុខរបរចម្បងក្នុងផ្នែកកសិកម្ម** | **៦ ១០០នាក់** |
| **%អ្នកមានមុខរបរចម្បងផ្នែកកសិកម្ម(គិតក្នុងមុខរបរចម្បង)** | **៨៦,៩%** |
| **%ស្រីមានមុខរបរចម្បងផ្នែកកសិកម្ម(គិតក្នុងមុខរបរចម្បង)** | **៤៣,៣%** |

| បរិយាយ | | ២០១៧ |
|---|---|---|
| ក្នុងនោះ | %អ្នកមានមុខរបរធ្វើស្រែ | ៤១,៩% |
| | %អ្នកមានមុខរបរដាំដំណាំចម្ការរយៈពេលវែង | ២៣,៦% |
| | %អ្នកមានមុខរបរដាំដំណាំចម្ការរយៈពេលខ្លី | ១៧,៧% |
| | %អ្នកមានមុខរបរដាំដំណាំបន្លែ | ២,៣% |
| | %អ្នកមានមុខរបរនេសាទ | ០,១% |
| | %អ្នកមានមុខរបរចិញ្ចឹមសត្វ | ០,៦% |
| | %អ្នកមានមុខរបរពីអនុផលព្រៃឈើ | ០,៨% |
| **សរុបអ្នកបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសិប្បកម្ម** | | **១២នាក់** |
| **%អ្នកបម្រើការងារក្នុងផ្នែកសិប្បកម្ម** | | **០,២%** |
| **%ស្រីបម្រើការងារក្នុងផ្នែកសិប្បកម្ម** | | **០,០%** |
| ក្នុងនោះ | %អ្នកបម្រើការងារសិប្បកម្មត្បាញរវៃ | ០,០% |
| | %អ្នកបម្រើការងារសិប្បកម្មផលិតពីផ្តៅ វល្លិ ល្ពាក់... | ០,០% |
| | %អ្នកបម្រើការងារសិប្បកម្មផលិតគ្រឿងសង្ហារឹម | ០,១% |
| | %អ្នកបម្រើការងារសិប្បកម្មចម្លាក់ធ្វើពីឈើ ថ្ម ស្ពាន់.. | ០,០% |
| | %អ្នកបម្រើការងារសិប្បកម្មផលិតពីដែក អាលុយមីញ៉ូម | ០,០% |
| | %អ្នកបម្រើការងារសិប្បកម្មផលិតពីជ័រ ប្លាស្ទិក ... | ០,០% |
| | %អ្នកបម្រើការងារសិប្បកម្មកែច្នៃ ឬ វិចខ្ចប់គ្រាប់ធញ្ញជាតិ | ០,០% |
| | %អ្នកបម្រើការងារសិប្បកម្មផលិតផ្សេងៗ | ០,០% |
| **សរុបអ្នកបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសេវាកម្ម** | | **៩០៦នាក់** |
| **%អ្នកបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសេវាកម្ម** | | **១២,៩%** |
| **%ស្រីបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសេវាកម្ម** | | **៥,៦%** |
| ក្នុងនោះ | %អ្នកបម្រើការងារលក់ដូរនិងជំនួញ | ២,៧% |
| | %អ្នកបម្រើការងារជាជាងជួសជុល | ០,៦% |
| | %អ្នកបម្រើការងារក្នុងផ្នែកដឹកជញ្ជូន | ០,២% |
| | %អ្នកបម្រើការងារស៊ីឈ្នួលក្នុងវិស័យកសិកម្ម កម្មករសំណង់ | ៥,៤% |
| | %អ្នកបម្រើការងារក្នុងវិស័យឯកជន(កម្មកររោងចក្រ បុគ្គលិក អង្គការ) | ២,៨% |
| | %អ្នកបម្រើការងារជាមន្ត្រីរាជការ | ១,២% |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ក្រយា ខែឧសភា ឆ្នាំ២០១៨*

ដោយយោងទៅតាមទិន្នន័យមន្ទីរផែនការឆ្នាំ២០១៧ បានបង្ហាញឱ្យឃើញថា ប្រជាជននៅក្នុងឃុំក្រយា ក្រៅពីប្រកបមុខធ្វើស្រែ ដែលជាមុខរបរសំខាន់ហើយ ពួកគាត់តែងតែបង្កើតមុខរបរបន្ទាប់បន្សំបន្ថែមទៀត ដើម្បី

ទ្រទ្រង់ជីវភាពនៅក្នុងគ្រួសារឱ្យកាន់តែប្រសើរឡើង នៅក្នុងនោះប្រជាជនដែលមានមុខរបរបន្ទាប់បន្សំផ្នែកសិកម្ម មានចំនួន ១ ០៣៧នាក់ ស្មើនឹង ៨៤,១ភាគរយ ក្នុងនោះមានស្ត្រីចំនួន ៧២៨នាក់ ស្មើនឹង ៥៩,០ភាគរយ អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសិប្បកម្មមាន ០១នាក់ ស្មើនឹង ០,១ ភាគរយ ជាស្ត្រី និងអ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្មចំនួន ១៦៤នាក់ ស្មើនឹង ១៥,៨ភាគរយ ក្នុងនោះមានស្ត្រី ១៣៩នាក់ ស្មើនឹង ១១,៣ភាគរយ។

ដូច្នេះតាមពត៌មានខាងលើបានបង្ហាញឱ្យឃើញថា ប្រជាពលរដ្ឋនៅក្នុងឃុំក្រយាក្រៅពីប្រកបរបរធ្វើស្រែជាចម្បង មានប្រជាជនមួយចំនួនប្រមាណជិតពាក់កណ្តាលបានខិតខំប្រកបរបរទទួលទានបន្ទាប់បន្សំថែមទៀត ដូចជា លក់ដូរនិងជំនួញ ផ្នែកដឹកជញ្ជូន និង កម្មករសំណង់។ល។ ចំណែកអ្នកដែលមានរបរផ្នែកសេវាកម្មជាចម្បងស្ទើរតែទាំងអស់បានខិតខំប្រកបរបរកសិកម្មដែលជាមុខរបរបន្ទាប់បន្សំបន្ថែមទៀតផងដែរដូចមានរៀបរាប់ក្នុងតារាងខាងក្រោមនេះ៖

តារាង 6៖ តារាងមុខរបរបន្ទាប់បន្សំ

| បរិយាយ | ២០១៧ | ២០១៧ចំនួន(នាក់) |
|---|---|---|
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកកសិកម្ម | ៨៤,១% | ១ ០៣៧ នាក់ |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកកសិកម្ម | ៥៩,០% | ៧២៨នាក់ |
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសិប្បកម្ម | ០,១% | ១នាក់ |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកសិប្បកម្ម | ០,១% | ១នាក់ |
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម | ១៥,៨% | ១៦៤នាក់ |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម | ១១,៣% | ១៣៩នាក់ |

ប្រភពទិន្នន័យ៖ *CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ក្រយា ខែឧសភា ឆ្នាំ២០១៨*

## ង. ចំណូលស្រុក និងចំណាកស្រុក

កត្តាដែលធ្វើឱ្យមានការផ្លាស់ប្តូរលំនៅឋាន គឺដោយសារតែនៅភូមិចាស់ដែលគាត់បានរស់នៅពិបាកក្នុងការរកស៊ី និងគ្មានការងារធ្វើនៅក្នុងភូមិ ព្រមទាំងមូលហេតុមួយចំនួនទៀត ដូចជា ៖ ស្ថានភាពដី នៅក្នុងតំបន់មូលដ្ឋានមួយចំនួនមានការប្រែប្រួលដោយដីខូច ងាប់សារធាតុបម្រុង ហើយឡើងខ្សោះ ឬហិរជាដើម ខ្វះប្រភពទឹក ធ្វើឱ្យទទួលបានទិន្នផលទាប តម្លៃផលិតផលកសិកម្មមិនទៀងទាត់ និងគ្មានទីផ្សារផលិតផល ចំណែកសមាជិកគ្រួសារកើនឡើង និងមួយចំនួនជាប់បំណុលធនាគារ និងមីក្រូហិរញ្ញវត្ថុជាដើម។ល។ ការផ្លាស់ប្តូរលំនៅឋានរបស់ប្រជាជនមួយចំនួនទៅរស់នៅទីប្រជុំជនឃុំ ស្រុក ខេត្ត ឬក្រុងភ្នំពេញ និងទៅធ្វើការងារនៅប្រទេសផ្សេងៗ។ មូលហេតុចម្បងនៃការធ្វើចំណាកស្រុកគ្រប់ប្រភេទគឺក្នុងគោលបំណងលើកស្ទួយតម្លៃសេដ្ឋកិច្ចគ្រួសារ។ នៅក្នុងឃុំក្រយាមានប្រជាជនផ្លាស់លំនៅឋានចូលចំនួន ៤២គ្រួសារ មានមនុស្សសរុបចំនួន ១៦២នាក់ ក្នុងនោះស្រីចំនួន ៨៦នាក់ ចំណែកគ្រួសារផ្លាស់លំនៅឋានចេញមានចំនួន ១៨៥គ្រួសារ មានមនុស្សសរុបចំនួន ៧៤២នាក់ ក្នុងនោះស្រីចំនួន ៣៤៧នាក់ ។

តារាង 7៖ ស្ថិតិប្រជាជនផ្លាស់ប្តូរទីលំនៅក្នុងឆ្នាំ២០១៦-២០១៧

| ល.រ | បរិយាយ | ចំនួនគ្រួសារ | ចំនួនប្រជាជនសរុប | |
|---|---|---|---|---|
| | | | សរុប | ស្រី |
| ១ | ចំនួនគ្រួសារផ្លាស់លំនៅឋានចូល | ៤២ | ១៦២ | ៨៦ |
| ២ | ចំនួនគ្រួសារផ្លាស់លំនៅឋានចេញ | ២៧២ | ៧៤២ | ៣៤៧ |

ប្រភពទិន្នន័យ៖ *ក្រុមប្រឹក្សាឃុំ ក្រយា ខែឧសភា ឆ្នាំ២០១៨*

ដោយយោងតាមទិន្នន័យមន្ទីរផែនការនៅឆ្នាំ២០១៧ បានបង្ហាញថាប្រជាជនដែលធ្វើចំណាកស្រុកមានចំនួនសរុប ៩៣៩នាក់ និងមានស្ត្រីចំនួន ៤៣៨នាក់ នៅក្នុងនោះប្រជាជនដែលធ្វើចំណាកស្រុកក្នុងប្រទេសមានចំនួន ៧១០នាក់ ក្នុងនោះស្ត្រីមានចំនួន ៣៥៨នាក់ តែមិនអចិន្ត្រៃយ៍នោះទេ ពួកគាត់ទៅធ្វើការនៅ ស្រុក ខេត្តផ្សេងឬរាជធានីភ្នំពេញតែមួយរយៈពេលប៉ុណ្ណោះ ហើយពួកគាត់តែងតែមកស្រុកវិញជារើយៗ។ ចំណែកចំណាកស្រុកក្រៅប្រទេសវិញមានចំនួន ២២៩នាក់ ក្នុងនោះមានស្រីចំនួន ៨០នាក់ ដោយពួកគាត់ទៅធ្វើការនៅប្រទេសថៃ ម៉ាឡេស៊ី ជប៉ុន និងប្រទេសកូរ៉េជាដើម ពួកគាត់ទៅតែមួយរយៈប៉ុណ្ណោះនិងត្រលប់មកស្រុកកំណើតវិញ ។

ប្រជាជនធ្វើចំណាកស្រុកចេញទៅរកស៊ីនៅស្រុក និងខេត្តផ្សេងៗ ឬទៅប្រទេសជិតខាងដូចជាប្រទេសថៃជាដើម ដោយសារកត្តាមួយចំនួនដូចខាងក្រោម៖

- ដីបង្កបង្កើនផលសម្រាប់វិស័យកសិកម្មតិចតួច ធ្វើស្រែបានផលតិច
- ការធ្វើស្រែចម្ការបានតែមួយរដូវ និងគ្មានទីផ្សារគ្រប់គ្រាន់សម្រាប់លក់ផលិតផល
- មិនមានការងារគ្រប់គ្រាន់នៅក្នុងស្រុក
- ជំពាក់បំណុលធនាគារ ឬឯកជនមិនមានលទ្ធភាពសង
- គ្មានមុខរបរច្បាស់លាស់ និងមានប្រាក់ចំណូលប្រចាំថ្ងៃទាប។
- កំណើនសមាជិកគ្រួសារមានមានការកើនឡើង។
- ដោយធ្វើស្រែប្រើឧបករណ៍ពាក់កណ្ដាលស្វ័យប្រវត្តិធ្វើឱ្យកម្លាំងពលកម្មថយចុះ។
- គ្រួសារមានដីតិចតួច មិនគ្រប់គ្រាន់ក្នុងការចិញ្ចឹមគ្រួសារ បន្ទាប់មកលក់ចេញទៅស្រុកផ្សេង។

តារាង ៤៖ ស្ថិតិប្រជាជនចំណាកស្រុក

| បរិយាយ | ២០១៦ | | | ២០១៧ | | |
|---|---|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| ចំនួនអ្នកធ្វើចំណាកស្រុកក្នុងប្រទេស | ៥៧៩ | ២៧៨ | ៣០១ | ៧១០ | ៣៥២ | ៣៥៨ |
| ចំនួនអ្នកធ្វើចំណាកស្រុកក្រៅប្រទេស | ២២០ | ១៤២ | ៧៨ | ២២៩ | ១៤៩ | ៨០ |
| **សរុប** | **៧៩៩** | **៤២០** | **៣៧៩** | **៩៣៩** | **៥០១** | **៤៣៨** |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ក្រយា ខែឧសភា ឆ្នាំ២០១៨*

### ១.១.៣. ស្ថានភាពសេដ្ឋកិច្ច

#### ក. ប្រភពចំណូលចម្បង និងបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋ

បើយោងតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន នៅត្រង់ចំណុចនៃការវិភាគចំណាត់ថ្នាក់ទ្រព្យធនបានឱ្យដឹងថាគ្រួសារដែលមានជីវភាពគ្រាន់បើ និងគ្រួសារមានជីវភាពមធ្យម មានប្រភពចំណូលទី១ គឺដំឡូងមី ប្រភពចំណូលទី២ គឺលក់គ្រប់ស្វាយចន្ទី និងប្រភពចំណូលទី៣ គឺកៅស៊ូ និងគ្រួសារមានជីវភាពក្រ និងក្រណាស់មានប្រភពចំណូលតែមួយគត់គឺលក់កម្លាំង។

#### ខ. កម្រិតជីវភាពរស់នៅ ចំណូល ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ

បើយោងទៅតាមតារាងចំណាត់ថ្នាក់ទ្រព្យធននៅក្នុងឆ្នាំ ២០១៧ ដែលទទួលបានពីរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានខាងលើ បានបង្ហាញឱ្យឃើញថានៅក្នុងឆ្នាំ២០១៧ ប្រជាពលរដ្ឋក្នុងឃុំក្រយាមាន

កម្រិតជីវភាពរស់នៅចែកចេញជាបួនកម្រិតគឺ ១)គ្រួសារបង្គួរ/គ្រាន់បើមានចំនួន ២០ ភាគរយ ដែលជាគ្រួសារមានកម្រិតជីវភាពធូរធាជាងគេ មានដីកាន់កាប់ពី ២៧,១៤ហិកតា ២)គ្រួសារមធ្យមមានចំនួន ៦២ ភាគរយ ជាចំនួនច្រើនជាងគេ (លើសពាក់កណ្ដាល) មានដីកាន់កាប់ពី ១១,៦០ហិកតា ៣) គ្រួសារក្រមាន ០៨ ភាគរយ មានដីកាន់កាប់ពី ២,៦០ហិកតា និង ៤)គ្រួសារក្រណាស់ដែលជាគ្រួសារក្រីក្របំផុតមានចំនួន ១០ភាគរយ មានដីកាន់កាប់ពី ១,១៤ហិកតាចុះក្រោមរហូតដល់អ្នកគ្មានដី ។

យោងតាមការសាកសួរក្រុមប្រឹក្សាឃុំក្រយា បានបង្ហាញថាចំណូលប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ជាមធ្យមចាប់ពី ២០ ០០០ទៅ ២៥ ០០០រៀល/គ្រួសារ ដូចនេះ ចំណូលប្រចាំឆ្នាំជាមធ្យមស្មើនឹង ៧ ៣០០ ០០០ ទៅ ៩១ ២៥០ ០០០រៀល/គ្រួសារ ចំណែកការចំណាយប្រចាំឆ្នាំវិញដូចជា ស្បៀងអាហារ សម្លៀកបំពាក់ ឧបករណ៍ប្រើប្រាស់ សម្ភារសិក្សា និងថ្នាំសង្កូវ ព្រមទាំងចំណាយផ្សេងៗស្មើនឹង ៥៤ ៧៧៥ ០០០ ទៅ ៧ ៣០០ ០០០ រៀល/គ្រួសារ

តារាង ១៖ តារាងកម្រិតជីវភាពរបស់ប្រជាជន

| ចំណាត់ថ្នាក់ធនធាន | បង្គួរ/គ្រាន់បើ | មធ្យម | ក្រ | ក្រណាស់/គ្មានដី | សរុប |
|---|---|---|---|---|---|
| **ប្រៀបធៀបជា(%)តំបន់ទី I** | ៣២ | ៦០ | ០៥ | ០៣ | ១០០ % |
| **តំបន់ទី II** | ៣០ | ៥៥ | ១០ | ០៥ | ១០០ % |
| **តំបន់ទី III** | ៣០ | ៧០ | ១០ | ១៥ | ១០០ % |
| **ទូទាំងឃុំ** | ២០ | ៦២ | ០៨ | ១០ | ១០០ % |
| **ទំហំគ្រួសារ** | ០៣ | ០៤ | ០៦ | ០៧ | - |
| **កម្លាំងពលកម្ម** | ០២ | ០៣ | ០៣ | ០៤ | - |
| **ទំហំដីកាន់កាប់សរុប(ហ.ត)** | ២៧,១៤ | ១១,៦០ | ២,៦០ | ១,១៤ | - |
| **ចំនួន និងប្រភេទក្បាលដី** | - | - | - | - | - |
| **ដីលំនៅឋាន(ហ.ត)** | 0,១៤ | 0,១0 | 0,0៦ | 0,0៤ | - |
| **ដីស្រែ(ហ.ត)** | 0២ | 0១ | 0,៥0 | 0,១0 | - |
| **ដីផ្សេងៗទី១(ហ.ត)** | 0១ | 0,៥0 | 0,៥0 | 0 | - |
| **ដីផ្សេងៗទី២(ហ.ត)** | 0១ | 0 | 0 | 0 | - |
| **ប្រភេទពូជស្រូវដាំដុះ** | - ស្រូវផ្ការំដួល<br>- ស្រូវរាំងជ័យ<br>- ស្រូវលាក់សន្លឹក | - ស្រូវផ្ការំដួល<br>- ស្រូវរាំងជ័យ | -ស្រូវនាងគង់<br>- ស្រូវរាំងជ័យ | - ស្រូវនាងគង់<br>- ស្រូវនាងម៉ិញ | - |
| **ដំណាំទី១៖** កៅស៊ូ (ហ.ត) | ១0 | ៣,៥ | 0 | - | - |
| **ដំណាំទី២៖**ស្វាយចន្ទី(ហ.ត) | 0៣ | ១,៥ | 0,៥0 | - | - |
| **ដំណាំទី៣៖** ដំឡូងមី(ហ.ត) | ១0 | ៥ | 0,50 | - | - |
| **ការចិញ្ចឹមត្រី** | គ្មាន | គ្មាន | គ្មាន | គ្មាន | - |
| ចំនួនគោ | 0៥ | 0៧ | 0២ | - | - |
| ចំនួនក្របី | 0៤ | 0២ | - | - | - |

| | | | | | |
|---|---|---|---|---|---|
| ចំនួនជ្រូក | ១០ | ០៥ | ០១ | - | - |
| **ការប្រើប្រាស់ឧបករណ៍នេសាទ** | - មង<br>- សន្ទូច<br>- សំណាញ់ | - មង<br>- សន្ទូច<br>- សំណាញ់ | - មង<br>- សន្ទូច | - មង<br>- សន្ទូច | - |
| **ប្រភពចំណូលទី១៖** | - ដំឡូងមី | - ដំឡូងមី | - លក់កម្លាំងពលកម្ម | - លក់កម្លាំងពលកម្ម | - |
| **ប្រភពចំណូលទី២៖** | - ស្វាយចន្ទី | - ស្វាយចន្ទី | | | - |
| **ប្រភពចំណូលទី៣៖** | - កៅស៊ូ | - កៅស៊ូ | | | - |
| **ការងារក្រៅពីកសិកម្ម (ប្រភេទពលកម្ម)** | លក់ចាប់ហួយ | លក់កម្លាំងពលកម្មក្នុងនិងក្រៅប្រទេស | លក់កម្លាំងពលកម្មក្នុង និងក្រៅប្រទេស | លក់កម្លាំងពលកម្មក្នុង និងក្រៅប្រទេស | - |
| **ការប្រើប្រាស់ឥណទាន** | ចងការពីធនាគារ និងឯកជន | ចងការពីឯកជន | ចងការពីសហគមន៍កសិកម្ម និងឯកជន | ខ្ចីបុលអ្នកជិតខាង | - |

ប្រភពទិន្នន័យ៖ *របាយការណ៍ក្សេត្រ-បរិស្ថាន និងក្រុមប្រឹក្សាឃុំ ក្រយា ខែមិថុនា ឆ្នាំ២០១៧*

### គ. ស្ថានភាពចំណូលសរុប និងអត្រាការប្រាក់

ប្រជាពលរដ្ឋនៅក្នុងឃុំក្រយាមានចំនួន ៤៧៥គ្រួសារ ស្មើនឹងប្រមាណជា ១២ភាគរយ ដែលមានជាប់បំណុលពីមីក្រូហិរញ្ញវត្ថុ និងធនាគារ ដូចមានរាយខាងក្រោម៖

- អ្នកមានជីវភាពបង្គួរ៖ មានលទ្ធភាពអាចខ្ចីប្រាក់ពីធនាគារ យកមកចងការបន្ត និងពង្រីកមុខរបរ ដូចជា កសិកម្ម សិប្បកម្ម និងលក់ដូរ។ល។
- អ្នកមានជីវភាពមធ្យម៖ មានលទ្ធភាពខ្ចីប្រាក់ពីធនាគារ យកមកចងការបន្ត និងពង្រីកមុខរបរ ដូចជា កសិកម្ម សិប្បកម្ម និងលក់ដូរ។ល។
- អ្នកមានជីវភាពខ្សត់ខ្សោយក្រ៖ ពុំអាចមានលទ្ធភាពខ្ចីប្រាក់ពីធនាគារឬមីក្រូហិរញ្ញវត្ថុឯកជនទេ ដោយសារគ្មានទ្រព្យបញ្ចាំ តែត្រូវខ្ចីប្រាក់បន្តពីអ្នកមានជីវភាពបង្គួរ និងមធ្យម។
- ចំណែកអ្នកក្របំផុត៖ ប្រកបរបរដោយលក់កម្លាំងពលកម្ម និងធ្វើចំណាកស្រុក។

នៅក្នុងឃុំក្រយាមានទីតាំងធនាគាចំនួន ០២កន្លែង និងស្ថាប័នមីក្រូហិរញ្ញវត្ថុឬសាខាចំនួន ០៣កន្លែង។ ប្រជាពលរដ្ឋទទួលបានសេវាប្រាក់កម្ចីពីធានាគារនិងស្ថាប័នមីក្រូហិរញ្ញវត្ថុជាច្រើនទាំងនៅក្នុងនិងក្រៅមូលដ្ឋាន។ ចំពោះអត្រាការប្រាក់វិញ គិតតាមចំនួននៃប្រាក់កម្ចី បើកម្ចីកាន់តែច្រើនអាត្រាការប្រាក់កាន់តែទាបរហូតទៅដល់ ០,៩ភាគរយ តែបើកម្ចីកាន់តែតិចនោះអាត្រាការប្រាក់កាន់តែខ្ពស់រហូតទៅដល់ ១,៨ភាគរយ ។ ទាំងធនាគា និង ស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងអស់ មានអត្រាការប្រាក់ប្រហាក់ប្រហែលគ្នា ហើយប្រជាពលរដ្ឋទូទៅអាចទទួលសេវាកម្ចីពី ធនាគារអេស៊ីលីដា ធានាគារអេប៊ីអេ និងស្ថាប័នមីក្រូហិរញ្ញវត្ថុមួយចំនួនទៀតដូចជា ស្ថាបនា ហត្ថាកសិករ ប្រាសាក់ ធនាគារភូមិ អេអឹមខេ គ្រេឌីត បណ្តាញសេដ្ឋកិច្ច អម្រឹត ចំរើន ប្រៃសណីយ៍ មហានគ រុងរឿង។

ចំណែកអ្នកខ្សត់ខ្សោយដែលខ្ចីប្រាក់បន្តពីអ្នកមានជីវភាពបង្គួរ និងជីវភាពមធ្យម មានអត្រាការប្រាក់ខ្ពស់គឺចាប់ពី ១,៥ភាគរយ ទៅ ១០ភាគរយ។

### ឃ. ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់ ឬក្រោមរូបភាពផ្សេងៗ

ជាទូទៅនៅក្នុងឃុំក្រយា មានការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់សុទ្ធ ដើម្បីយកទៅប្រើប្រាស់ពង្រីកមុខរបរ ចងការបន្ត ទិញសម្ភារៈកសិកម្ម ទិញជី និងប្រើប្រាស់តាមតម្រូវការចាំបាច់ផ្សេងៗទៀត ក៏នៅមានក្រោមរូបភាពប្រជាពលរដ្ឋមួយចំនួន ទៅទទួលយកជីដាក់ស្រូវមុន និងសន្យាសងប្រាក់ក្រោយពេលប្រមូលផលស្រូវផងដែរ។

### ង. ចំណូលពីប្រភពផ្សេងៗ

ប្រជាពលរដ្ឋនៅក្នុងឃុំក្រយា ពួកគាត់អាចទទួលបាននូវប្រភពចំណូលពីប្រភពផ្សេងៗដូចជា៖

- ចំណាកស្រុកក្រៅប្រទេស(ពលករផ្នែក កសិកម្ម ឧស្សាហកម្ម) ដូចជាប្រទេសថៃជាដើម
- និងចំណូលមួយចំនួនតូចទៀតបានមកពីគ្រួសារឬបងប្អូនរស់នៅជាអចិន្ត្រៃយ៍នៅបរទេស ដែលពួកគាត់បានផ្ញើមកដើម្បីផ្គត់ផ្គង់គ្រួសារនៅស្រុកខ្មែរ ។

## ១.១.៤.ស្ថានភាពសិក្សាធិការ

### ក. ស្ថានភាពអប់រំ

យោងទៅតាមផែនការអភិវឌ្ឍឃុំក្រយា ៥ឆ្នាំ (២០១៧-២០២២) បានឱ្យដឹងថា ជារៀងរាល់ឆ្នាំកុមារាកុមារីគ្រប់អាយុចូលរៀន បានចុះឈ្មោះចូលរៀនគ្រប់គ្នា ទោះបីជាកុមារ ស្ថិតនៅក្នុងស្ថានភាពគ្រួសារក្រីក្រ គ្រួសារដែលជាស្ត្រីមេម៉ាយ ឬក្មេងកំព្រា កុមារពិការក៏ដោយក្តី ។ មកដល់ពេលបច្ចុប្បន្ន វិស័យអប់រំនៅក្នុងឃុំក្រយា មានការរីកចម្រើនជាងមុន ដូចជា ៖ អគារសិក្សាត្រូវបានសាងសង់ថ្មីៗ និងមានការកែលម្អបន្ទប់រៀនថែមទៀត នៅតាមសាលារៀនគ្រប់កម្រិត ដែលផ្តល់លទ្ធភាពឱ្យសិស្សបានរៀនសូត្រគ្រប់ពេលពុំមានការខ្វះខាតអ្វីឡើយ ។ ចំណុចអវិជ្ជមានក៏មាននៅក្នុងឃុំផងដែរ ដូចជា ៖ ខ្វះគ្រូបង្រៀន មិនទាន់មានសាលាមត្តេយ្យសហគមន៍គ្រប់គ្រាន់នៅតាមភូមិនៅឡើយ មានអ្នកមិនចេះអក្សរ (អនក្ខរជន) ជាពិសេសមនុស្សវ័យចំណាស់ពួកគាត់ពុំសូវមានស្មារតីសិក្សារៀនសូត្រ ទោះបីមានការយកចិត្តទុកដាក់ជម្រុញលើកទឹកចិត្តពីអាជ្ញាធរមូលដ្ឋានយ៉ាងណាក៏ដោយ ។

រូបភាព 1៖ សាលារៀន

| | |
|---|---|
|  |  |
| សាលាបឋមសិក្សា | សាលាអនុវិទ្យាល័យ |

នៅក្នុងឃុំក្រយា មានកម្រិតអប់រំចាប់ពីបឋមសិក្សារហូតដល់អនុវិទ្យាល័យ ចំណែកមតេយ្យសិក្សា និងវិទ្យាល័យវិញមិនមាននៅក្នុងឃុំនោះទេ តែមាននៅឃុំដែលជាប់ព្រំប្រទល់គ្នា។ ឃុំក្រយាមានសាលាបឋមសិក្សាចំនួន ១២កន្លែង ៦៥បន្ទប់ ៧៨ថ្នាក់ មានគ្រូបង្រៀនសរុបចំនួន ៧៨នាក់ ក្នុងនោះជាស្ត្រី ៤៤នាក់ និងមានសិស្សដែលកំពុងរៀនចំនួនសរុប ២ ២៧៨នាក់ ក្នុងនោះសិស្សស្រីចំនួន ១១៤២នាក់ ។ អនុវិទ្យាល័យមានចំនួន ០១កន្លែង ០៥បន្ទប់ ០៧ថ្នាក់ មានគ្រូបង្រៀនចំនួន ១០នាក់ ក្នុងនោះស្ត្រី ០៣នាក់ និងសិស្សដែលកំពុងរៀនមានចំនួន ៣៤៨នាក់ ក្នុងនោះមានស្រីចំនួន ២១៦នាក់ ។

តារាង 10៖ ស្ថិតិសាលារៀន ស្ថានភាពអប់រំ និងសិក្សាធិការក្នុងឃុំឆ្នាំ២០១៧

| ស្ថានភាពសាលា | ចំនួនសាលារៀន | | | ចំនួនសិស្ស | | គ្រូបង្រៀន | |
|---|---|---|---|---|---|---|---|
| | សាលា | បន្ទប់ | ថ្នាក់ | សរុប | ស្រី | សរុប | ស្រី |
| ១.សាលាមត្តេយ្យ | 0 | 0 | 0 | 0 | 0 | 0 | 0 |
| ២.សាលាបឋមសិក្សា | ១២ | ៦៥ | ៧៨ | ២ ២៧៨ | ១ ១៤២ | ៧៨ | ៤៤ |
| ៣.អនុវិទ្យាល័យ | ១ | ៥ | ៧ | ៣៤៨ | ២១៦ | ១០ | ០៣ |
| ៤.វិទ្យាល័យ | 0 | 0 | 0 | 0 | 0 | 0 | 0 |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ក្រយា ខែឧសភា ឆ្នាំ២០១៨*

### ខ. ស្ថានភាពអក្ខរកម្ម

អក្ខរកម្មគឺជាគ្រឹះនៃចំណេះដឹងការអប់រំ នឹងជាគន្លឹះនៃចំណេះដឹងការអប់រំ នឹងជាគន្លឹះនៃការអភិវឌ្ឍនឹងការចូលរួមចំណែកកាត់បន្ថយចំណាកស្រុក ដោយប្រថុយប្រថាន ហើយអក្ខរកម្មនាំឱ្យសង្គមជាតិកាន់តែអភិវឌ្ឍរីកចម្រើន។ នៅក្នុងឃុំក្រយាមនុស្សដែលមានអាយុពី ១៥ ទៅ ៤៥ឆ្នាំ មានចំនួន ៦៨ ៧១២នាក់ ហើយក្នុងនោះអ្នកដែលមិនចេះអក្សរមានចំនួន ២៥,៣ភាគរយ ។ បើគិតទៅក្រុមអាយុវិញឃើញថានៅក្នុងឃុំក្រយាមានអ្នកមិនចេះអក្សរអាយុពី ១៥ ទៅ ២៤ឆ្នាំមានចំនួន ៥៥៣នាក់ ស្មើនឹង ១៨,៧ភាគរយ អាយុពី ២៥ ទៅ ៤៥ឆ្នាំ មានចំនួនសរុប ១ ១៨៧នាក់ ស្មើនឹង ៣០,៣ភាគរយ ។

ប្រជាពលរដ្ឋភាគច្រើនដែលមិនចេះអក្សរ គឺដោយសារមិនបានចូលរៀន មូលហេតុដោយសារសាលារៀននៅឆ្ងាយពីភូមិឃុំ ប្រជាពលរដ្ឋនៅតែមានកង្វះមធ្យោបាយធ្វើដំណើរទៅសាលារៀន ខ្វះថវិកាសម្រាប់ទិញសម្ភារៈសិក្សា សម្លៀកបំពាក់ និងផ្នត់គំនិតរបស់ឪពុកម្តាយចាស់គំរឹលឬមិនជឿនលឿន ។ ទោះបីជាយ៉ាងនោះក្តី នៅក្នុងឃុំនៅមានថ្នាក់អក្ខរកម្មជាប្រចាំ តែពួកគាត់ពុំទាន់មានពេលចូលសិក្សាព្រោះជាប់រវល់ប្រកបរបរចិញ្ចឹមជីវិត ដែលជាហេតុនាំមកនូវការភ្លេចអក្សរ ក្នុងចំណោមអ្នកដែលបានចូលមកសិក្សាក្នុងថ្នាក់អក្ខរកម្មកន្លងមក ។

**- អនុវិស័យអប់រំក្រៅប្រព័ន្ធ**

ក្របខ័ណ្ឌស្ថាប័ន និងគោលនយោបាយត្រូវបានពង្រឹង តាមរយៈការពិនិត្យឡើងវិញគោលនយោបាយអប់រំក្រៅប្រព័ន្ធ ការបង្កើតអនុក្រុមការងារអប់រំក្រៅប្រព័ន្ធ និងមានភារកិច្ចច្បាស់លាស់ ការវាយតម្លៃសមត្ថភាពអប់រំក្រៅប្រព័ន្ធ និងការកសាងផែនទី ក៏ដូចជា ការពិនិត្យឡើងវិញកម្មវិធីចូលរៀនឡើងវិញនិងការរៀបចំសេចក្តីណែនាំស្តីពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំនៅក្រៅប្រព័ន្ធនិងកម្មវិធីសមមូល ។ ដើម្បីជម្រុញឱ្យផែនការយុទ្ធសាស្ត្រអនុវិស័យអប់រំក្រៅប្រព័ន្ធបានទទួលជោគជ័យ ត្រូវបន្តអនុវត្តសកម្មភាពដូចខាងក្រោម៖

១. បន្តពង្រឹងសកម្មភាពមជ្ឈមណ្ឌលសិក្សាសហគមន៍ បណ្ណាល័យ និងមណ្ឌលអានដែលមានស្រាប់
២. បន្តពង្រឹងការអនុវត្តកម្មវិធីសមមូលបឋមសិក្សា និងមធ្យមសិក្សា
៣. អនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ
៤. បន្តអនុវត្តការងារអក្ខរកម្មតាមការជាក់ស្តែង
៥. បន្តអនុវត្តកម្មវិធីចូលរៀនឡើងវិញ។

តារាង 11៖ ស្ថិតិអ្នកមិនចេះអក្សរ

| បរិយាយ | ២០១៦ | ២០១៧ |
|---|---|---|
| ចំនួនអ្នកមិនចេះអក្សរអាយុ១៥-២៤ឆ្នាំ | ៥២៨ នាក់ | ៥៥៣នាក់ |
| %អ្នកមិនចេះអក្សរអាយុ១៥-២៤ឆ្នាំ | ១៨% | ១៨,៧% |
| ចំនួនអ្នកមិនចេះអក្សរអាយុ២៥-៤៥ឆ្នាំ | ១ ១៤៩នាក់ | ១ ១៨៧នាក់ |
| %អ្នកមិនចេះអក្សរអាយុ២៥-៤៥ឆ្នាំ | ៣១% | ៣០,៣% |
| សរុបមនុស្សអាយុ១៥-៤៥ឆ្នាំ | ៦ ៦៤៤នាក់ | ៦ ៨៧១នាក់ |
| %អ្នកមិនចេះអក្សរអាយុ១៥-៤៥ឆ្នាំ | ២៥,២% | ២៥,៣% |

ប្រភពទិន្នន័យ៖ *CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ក្រយា ខែឧសភា ឆ្នាំ២០១៨*

**គ. ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត**

បើយោងទៅតាមប្រភពទិន្នន័យមន្ទីរផែនការខេត្តឆ្នាំ២០១៧បានបង្ហាញឱ្យឃើញថាលទ្ធភាពក្នុងការបន្តការសិក្សារបស់សិស្សនៅក្នុងឃុំក្រយា ទៅថ្នាក់ខ្ពស់ទៀតមានដូចខាងក្រោម៖

- អាយុពី១២-១៤ឆ្នាំរៀនអនុវិទ្យាល័យសរុបចំនួន ២៤២នាក់ ស្រីមានចំនួន ១២៤នាក់
- អាយុពី១៥-១៧ឆ្នាំរៀនអនុវិទ្យាល័យសរុបចំនួន ៣១៣នាក់ ស្រីមានចំនួន ១៤៩នាក់
- អាយុពី១៥-១៧ឆ្នាំរៀនវិទ្យាល័យសរុបចំនួន ៩៧នាក់ ស្រីមានចំនួន ៣១នាក់
- អាយុពី១៨-២៤ឆ្នាំរៀនវិទ្យាល័យសរុបចំនួន ៩៨នាក់ ស្រីមានចំនួន ៣៥នាក់
- អាយុពី១៨-២៤ឆ្នាំរៀនសកលវិទ្យាល័យសរុបចំនួន ២៧នាក់ ស្រីមានចំនួន ១៦នាក់។
- អាយុពី២៥-៣៥ឆ្នាំរៀនសកលវិទ្យាល័យសរុបចំនួន ១២នាក់ ស្រីចំនួន ០៥នាក់
- អាយុពី១៨-២៤ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈសរុបចំនួន ១២នាក់ ស្រីចំនួន ០៨នាក់
- អាយុពី២៥-៣៥ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈសរុបចំនួន ០៣នាក់ ស្រីចំនួន ០២នាក់

តារាង 12៖ ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត

| ការអប់រំតាមក្រុមអាយុ | សរុប | ស្រី |
|---|---|---|
| អាយុពី១២-១៤ឆ្នាំរៀនអនុវិទ្យាល័យ | ២៤២ | ១២៤ |
| អាយុពី១៥-១៧ឆ្នាំរៀនអនុវិទ្យាល័យ | ៣១៣ | ១៤៩ |
| អាយុពី១៥-១៧ឆ្នាំរៀនវិទ្យាល័យ | ៩៧ | ៣១ |
| អាយុពី១៨-២៤ឆ្នាំរៀនវិទ្យាល័យ | ៩៨ | ៣៥ |
| អាយុពី១៨-២៤ឆ្នាំរៀនសកលវិទ្យាល័យ | ២៧ | ១៦ |

| | | |
|---|---|---|
| អាយុពី២៥-៣៥ឆ្នាំរៀនសកលវិទ្យាល័យ | ១២ | ៥ |
| អាយុពី១៨-២៤ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ | ១២ | ៨ |
| អាយុពី២៥-៣៥ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ | ៣ | ២ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ក្រយា ខែឧសភា ឆ្នាំ២០១៨*

### ១.១.៩.ស្ថានភាពសុខាភិបាល

មណ្ឌលសុខភាព គឺជាកន្លែងផ្តល់សេវាអប់រំសុខភាព ថែទាំនិងព្យាបាលអ្នកជម្ងឺផ្សេងៗ។ ឃុំក្រយាមិនមានមណ្ឌលសុខភាពនៅក្នុងឃុំនោះទេ មានតែប៉ុស្តិ៍សុខភាពនៅក្នុងភូមិសែនសេរីមង្គល ប្រជាពលរដ្ឋមួយចំនួនបានមកប្រើប្រាស់សេវាសុខភាពនៅប៉ុស្តិ៍សុខភាព និងមួយចំនួនទៀតមកកាន់មណ្ឌលសុខភាពល្អក់ ដែលស្ថិតនៅក្នុងភូមិល្អក់ឃុំកំពង់ថ្ម ។ ប្រភេទជម្ងឺដែលកាចសាហាវ ឬជម្ងឺឆ្លង ដែលកើតញឹកញាប់ គឺជម្ងឺរលាកផ្លូវដង្ហើម ។ ស្ថានភាពមាតា និងទារកនៅក្នុងឃុំក្រយាមានស្ត្រីសម្រាលកូនដោយឆ្មបបុរាណក្នុង១ឆ្នាំកន្លងទៅចំនួន ០២ នាក់ ស្ត្រីដែលសម្រាលកូនដោយឆ្មបមានការបណ្តុះបណ្តាលក្នុង១ឆ្នាំកន្លងទៅមានចំនួន ១៩៤ នាក់ ទារកដែលបានកើតរស់ដោយឆ្មបពេទ្យមានចំនួន ១៩៤ នាក់ មរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ០-១ខែ ដោយឆ្មបបុរាណមិនមាននោះទេ មរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ០-១ខែដោយឆ្មបពេទ្យមិនមានទេ មរណភាពទារកក្នុងចន្លោះអាយុ០-១ខែដោយឆ្មបបុរាណមិនមែនទេ មរណភាពទារកក្នុងចន្លោះអាយុ០-១ខែដោយឆ្មបពេទ្យមិនមានទេ ចំនួនទារកដែលបានចុះសំបុត្រកំណើតមានចំនួន ១២២ នាក់ ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែមាន ៨១នាក់ កុមារដែលមានអាយុចន្លោះពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន ៨១នាក់ សម្រាប់ការចាក់ថ្នាំបង្ការជម្ងឺផ្សេងៗនេះធ្វើនៅប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព និងតាមភូមិជូនប្រជាពលរដ្ឋ មានជម្ងឺមួយចំនួនដូចជា៖ ជម្ងឺកញ្ជ្រិល ស្វិតដៃជើង ក្អកមាន់ របេង តេតាណូស រលាកថ្លើមប្រភេទបេ ផ្តាសាយបក្សី គ្រុនចាញ់ រាករូស និងគ្រុនឈាម។ ករណី ជម្ងឺធ្ងន់ធ្ងរការបញ្ជូនអ្នកជម្ងឺដោយមធ្យោបាយខ្លួនឯងផ្ទាល់មកមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព ព្រោះស្ថិតនៅជិតពួកគាត់ ឯការបញ្ជូនទៅកាន់មន្ទីរពេទ្យបង្អែក ដោយមធ្យោបាយផ្ទាល់ខ្លួន និងរថយន្តសង្គ្រោះរបស់ពេទ្យបង្អែក ទាំងការចំណាយវាយផ្សេងៗជាបន្ទុករបស់អ្នកជម្ងឺ បើក្នុងករណីអ្នកជម្ងឺមិនមានប័ណ្ណក្រីក្រ។

តារាង 13៖ សុខភាពមាតានិងទារក

| ល.រ | សុខភាពមាតានិងទារក | ឆ្នាំ២០១៧ |
|---|---|---|
| ១ | ចំនួនបុគ្គលិកពេទ្យនៅមណ្ឌលសុខភាព | 0 |
| ២ | ចំនួនពេទ្យឆ្មបនៅមណ្ឌលសុខភាព | 0 |
| ៣ | ចំនួនឆ្មបបុរាណនៅមណ្ឌលសុខភាព | 0 |
| ៤ | ចំនួនបន្ទប់នៅមណ្ឌលសុខភាព | 0 |
| ៥ | ចំនួនគ្រែនៅមណ្ឌលសុខភាព | 0 |
| ៦ | ចំនួនឆ្មបដែលបានបណ្តុះបណ្តាលមានក្នុងភូមិ | ៥នាក់ |
| ៧ | ចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបបុរាណក្នុង១ឆ្នាំកន្លងទៅ | ២នាក់ |
| ៨ | ចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបមានការបណ្តុះបណ្តាលក្នុង ១ឆ្នាំកន្លងទៅ | ១៩៤នាក់ |

| | | |
|---|---|---|
| ៩ | ចំនួនទារកដែលបានកើតរស់ដោយឆ្មបបុរាណ | ២នាក់ |
| ១០ | ចំនួនទារកដែលបានកើតរស់ដោយឆ្មបពេទ្យ | ១៩៤នាក់ |
| ១១ | ចំនួនមរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ 0-១ខែដោយឆ្មបបុរាណ | 0 |
| ១២ | ចំនួនមរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ 0-១ខែដោយឆ្មបពេទ្យ | 0 |
| ១៣ | ចំនួនមរណភាពទារកក្នុងចន្លោះអាយុ 0-១ខែដោយឆ្មបបុរាណ | 0 |
| ១៤ | ចំនួនមរណភាពទារកក្នុងចន្លោះអាយុ 0-១ខែដោយឆ្មបពេទ្យ | 0 |
| ១៥ | ចំនួនទារកដែលបានចុះសំបុត្រកំណើត | ១២២នាក់ |
| ១៦ | ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែ | ៨១នាក់ |
| ១៧ | ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន | ៨១នាក់ |

ប្រភពទិន្នន័យ៖ *ក្រុមប្រឹក្សាឃុំ ក្រយា ខែឧសភា ឆ្នាំ២០១៨*

រូបភាព 2៖ មណ្ឌលសុខភាព ល្អក់




បើយោងតាមទិន្នន័យមន្ទីរផែនការខេត្តកំពង់ធំឆ្នាំ ២០១៧ បានឱ្យដឹងថា ចម្ងាយពីភូមិនីមួយៗទៅកាន់មណ្ឌលសុខភាព នៅមានចម្ងាយឆ្ងាយសម្រាប់ភូមិមួយចំនួនដូចជា៖ ភូមិសែនសិរីមង្គលចម្ងាយ ១៩គីឡូម៉ែត្រ ភូមិថ្មសំលៀង ២០ គីឡូម៉ែត្រ ភូមិត្រពាំងឫស្សី ៣៧គីឡូម៉ែត និងភូមិអូរទឹកថ្លា ៤៧គីឡូម៉ែត ដូចមានក្នុងតារាងសង្ខេបខាងក្រោម ។ ចំណែកស្ថានភាពផ្លូវទៅកាន់មណ្ឌលសុខភាពក៏នៅមានការពិបាកក្នុងការធ្វើដំណើរដែរ ។

តារាង 14៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព

| ល.រ | ឈ្មោះភូមិ | ចម្ងាយជាមធ្យម ពីភូមិទៅមណ្ឌលសុខភាព | ផ្សេងៗ |
|---|---|---|---|
| ១ | ក្រយា | ១០ គីឡូម៉ែត | |
| ២ | ទក់ | ១ គីឡូម៉ែត | |
| ៣ | ត្រពាំងព្រីង | ៣ គីឡូម៉ែត | |
| ៤ | ដងក្តារ | ១២ គីឡូម៉ែត | |

| | | | |
|---|---|---|---|
| ៥ | តាម៉ិញ | ៦ គីឡូម៉ែត | |
| ៦ | សុភមង្គល | ៧ គីឡូម៉ែត | |
| ៧ | ថ្មសំលៀង | ២០ គីឡូម៉ែត | |
| ៨ | ឈើទាលជ្រុំ | ១២ គីឡូម៉ែត | |
| ៩ | ត្រពាំងឬស្សី | ៣៧ គីឡូម៉ែត | |
| ១០ | អូរទឹកថ្លា | ៤៧ គីឡូម៉ែត | |
| ១១ | សែនសិរីមង្គល | ១៩ គីឡូម៉ែត | |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ក្រយា ខែឧសភា ឆ្នាំ២០១៨*

ដ្យាក្រាម 2៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព




## ១.១.៦. ស្ថានភាពយេនឌ័រ

បើតាមផែនការអភិវឌ្ឍឃុំក្រយារយៈពេល៥ឆ្នាំ(២០១៨-២០២២) បានឱ្យដឹងថា សមភាពការងាររបស់ស្ត្រីនិងបុរសក្នុងឃុំក្រយានាពេលបច្ចុប្បន្នគ្មានការរើសអើង ឬគាបសង្កត់ទៅលើស្ត្រីនោះទេ។ ផ្ទុយទៅវិញការងារយេនឌ័រកំពុងមានការគាំទ្រយ៉ាងពេញទំហឹង ជាក់ស្តែងក្នុងការងារមានថ្នាក់ដឹកនាំជាស្ត្រីនៅថ្នាក់ភូមិ និងថ្នាក់ឃុំកំពុងតែត្រូវបានលើកកម្ពស់ និងលើកទឹកចិត្តស្ត្រីឱ្យមានការចូលរួមយ៉ាងសកម្មក្នុងការកសាងផែនការអភិវឌ្ឍឃុំក៏ដូចជាផែនការ វិនិយោគផងដែរ ។ ទោះជាយ៉ាងនេះក្តី បញ្ហាប្រឈមនៅតែកើតមានឡើងទៅលើសមត្ថភាពស្ត្រីដោយមានមួយចំនួននៅតែមានកម្រិតជីវភាពក្រីក្រខ្លះបោះបង់ការសិក្សាដើម្បីរកចំណូលមកទ្រទ្រង់ជីវភាពក្នុងគ្រួសារ អ្នកខ្លះចំណាកស្រុកទៅភ្នំពេញដើម្បីធ្វើកម្មកររោងចក្រ ។ ដើម្បីដោះស្រាយបញ្ហានេះក្រុមប្រឹក្សាឃុំ បានសហការជាមួយនឹងមន្ទីរការិយាល័យជំនាញជំនាញ និងដៃគូរអភិវឌ្ឍនានាជុំវិញ និងបានលើកទឹកចិត្តឱ្យមានការបណ្តុះបណ្តាលបច្ចេកទសនានា និងជំនាញវិជ្ជាជីវៈបង្កើនមុខរបរថ្មីៗ ដើម្បីបង្កើនប្រាក់ចំណូល និងកាត់បន្ថយការចំណាកស្រុក ។ ប៉ុន្តែបើតាមរយៈរបាយការណ៍នៃការវិភាគប្រព័ន្ធភ្សេត្របរិស្ថានឃុំក្រយា ឆ្នាំ២០១៧ បានឱ្យដឹងអំពីតួនាទីយេនឌ័រក្នុងការចូលរួមសកម្មភាពការងារផលិតកម្មកសិកម្ម និងការងារទូទៅក្នុងជីវភាពគ្រួសាររបស់កសិករក្នុងឃុំក្រយា មានលម្អិតក្នុងតារាងខាងក្រោម។

តារាង 15៖ ការវិភាគលើតួនាទីយេនឌ័រ ឃុំក្រយា

| សកម្មភាព | បុរស | ស្រ្តី | យោបល់បន្ថែម |
|---|---|---|---|
| ស្រូវវស្សា និង ស្រូវប្រាំង | | | |
| ការរៀបចំដីលើកទី១ | ៩០ % | ១០ % | បុរសអនុវត្តនៅទីវាល ស្រ្តីរៀបចំផ្ទះ |
| ការរៀបចំដីលើកទី២ | ៧០ % | ៣០ % | ស្រ្តីអាចជួយបាចដីទ្រាបបាត សម្អាតស្មៅ |
| ការត្រាំពូជ | ៥០ % | ៥០ % | |
| ព្រួស | ៧០ % | ៣០ % | ស្រ្តីអាចជួយព្រួសមួយចំនួន |
| ការដាក់ជីបំប៉ន | ៩០ % | ១០ % | ស្រ្តីជួយជញ្ជូនជីបានខ្លះ |
| គ្រប់គ្រងទឹកស្រែ | ៥០ % | ៥០ % | |
| ការថ្នាំកសិកម្ម | ៨០ % | ២០ % | ស្រ្តីជួយទិញថ្នាំ, រៀបចំ ម្ហូបអាហារ សម្ភារៈឱ្យប្តី |
| ការច្រូតកាត់ | ៥០ % | ៥០ % | |
| ការដឹកជញ្ជូន | ៧០ % | ៣០ % | ស្រ្តីជួយចងមាត់បាវ, ច្រកស្រូវ |
| ហាលសម្ងួត | ៥០ % | ៥០ % | |
| ទុកដាក់ស្រូវ | ៥០ % | ៥០ % | |
| លក់ស្រូវ | ៥០ % | ៥០ % | |
| សកម្មភាពមុខរបរចិញ្ចឹមជីវិតសំខាន់ផ្សេងទៀត | | | |
| សួនបន្លែ | ៥០ % | ៥០ % | |
| ចិញ្ចឹមជ្រូក | ៣០ % | ៧០ % | បុរសជួយធ្វើទ្រុង,ជួយលាងសម្អាតទ្រុងម្តងម្កាល |
| ចិញ្ចឹមគោ ក្របី | ៧០ % | ៣០ % | ស្រ្តីជួយរៀបចំម្ហូបអាហារផ្ទះ |
| ចិញ្ចឹមមាន់ ទា | ៥០ % | ៥០ % | |
| ការប្រមូលអនុផលព្រៃឈើ | ៧០ % | ៣០ % | ជួយជញ្ជូនដាករទេះ |
| រកត្រី | ៧០ % | ៣០ % | ជួយកាន់ឧបករណ៍រកត្រី |
| ជំនួញទូទៅ | ៥០ % | ៥០ % | |
| ការថែទាំប្រព័ន្ធធារាសាស្រ្ត | ៧០ % | ៣០ % | ស្រ្តីជួយឱ្យយោបល់ |
| ដំណាំឪឡឹក | | | |
| ការរៀបចំដី | ៨០ % | ២០ % | ជួយរៀបចំម្ហូបអាហារ |
| ភ្ជួរ | ៩០ % | ១០ % | ដាំបាយ ស្ល យកបាយឱ្យប្តី |
| រាស់ | ៩០ % | ១០ % | ស្រ្តីមើលកូននៅផ្ទះ, បោកខោអាវឱ្យប្តី |
|ឆូតរង | ៥០ % | ៥០ % | |
| ដាក់ជី | ៦០ % | ៥០ % | |
| ផ្តុំរង | ៩០ % | ១០ % | ធ្វើកិច្ចការនៅផ្ទះ |
| ដាំគ្រាប់ | ១០ % | ៩០ % | ទៅមើលគោ ក្របី |
| ដាក់ជី | ១០ % | ៩០ % | |
| ពូនរង | ៩០ % | ១០ % | |

| | | | |
|---|---|---|---|
| បូមទឹក | ៩០% | ១០% | រៀបចំសម្ភារៈស្រាល |
| ថែទាំ | ៦០% | ៥០% | |
| លក់ដោយម៉ៅ | ៥០% | ៥០% | |

ប្រភពទិន្នន័យ៖ *របាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំក្រយាឆ្នាំ២០១៧*

បើយោងទៅតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំក្រយា ឆ្នាំ២០១៧ បានរកឃើញពីការវិភាគតួនាទីយេនឌ័រក្នុងឃុំក្រយាដូចខាងក្រោម៖

១.ស្ត្រីភាគច្រើនជាអ្នកផលិតផលកសិកម្ម

២.បុរសទៅរកចំណូលនៅឆ្ងាយៗផ្ទះ

៣.ស្ត្រីមើលថែការងារនៅផ្ទះជាប្រចាំ

៤.សកម្មភាពការងារមានការចូលរួមធ្វើទាំងអស់គ្នា

៥.ការងារធ្ងន់ៗជាបន្ទុករបស់បុរស

បើតាមប្រភពព័ត៌មានដែលទទួលបាន ដូចមានរៀបរាប់ខាងលើពាក់ព័ន្ធការលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិអំណាចស្ត្រីនៅក្នុងឃុំក្រយា យើងសង្កេតឃើញថា បុរស និងស្ត្រីមិនមានការរើសអើងគ្នាធ្ងន់ធ្ងរអ្វីនោះទេ គឺមានភាពលំអៀងតិចតួចប៉ុណ្ណោះ ដូចជា ការងារធ្វើស្រែឃើញថាបុរសមានការចូលរួមច្រើនជាងស្ត្រី ជាពិសេសការងាររៀបចំដីស្រែ ឃើញថាការងារនេះ បុរសជាអ្នកទទួលរ៉ាប់រងស្ទើរតែទាំងស្រុង ដែលស្ត្រីជាអ្នកមានកម្លាំងទន់ខ្សោយជាងជាអ្នកចម្អិនអាហារនៅផ្ទះ ហើយក៏ឃើញការងារដឹកជញ្ជូនគ្រាប់ស្រូវ បាញ់ថ្នាំសម្លាប់សត្វល្អិតនិងដាក់ជី ច្រូតកាត់ និងការងារទុកដាក់ស្រូវជាដើមគឺ បុរសបានចូលរួមច្រើនជាងស្ត្រី ប៉ុន្តែការងារក្នុងផ្ទះនិងនៅជិតផ្ទះឃើញស្ត្រីបានចូលរួមច្រើនជាងបុរសវិញ តែក្នុងនោះក៏បានរកឃើញថា ការសម្រេចចិត្តនៅក្នុងគ្រួសារបុរសនៅមានសិទ្ធិច្រើនជាងស្ត្រី និងមានស្ត្រីមួយចំនួននៅទទួលរងអំពើហិង្សាក្នុងគ្រួសារនៅឡើយ ។ ប៉ុន្តែទោះបីមានបញ្ហាប្រឈមខ្លះក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិអំណាចស្ត្រីក៏ដោយ ក៏យើងឃើញកិច្ចការនេះមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដែលទៅថ្ងៃអនាគតនឹងឈានទៅកាន់តែប្រសើរឡើង ។

## ១.២.ស្ថានភាពភូមិសាស្ត្រ

### ១.២.១.ទីតាំងភូមិសាស្ត្រ

ឃុំក្រយា ជាឃុំមួយ ស្ថិតនៅក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ ដែលមានទីតាំងផ្អែកទៅលើនិយាមកាផែនទី (អាប់ស៊ីស) ៥២៧ ៦៨២,១១ និង(អ័រដោនេ) ១ ៣៩០ ០២៥,៨២ ។ សណ្ឋានដីនៅក្នុងឃុំក្រយា បើផ្អែកតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំ បានឱ្យដឹងថា ជាដីមិនរាបស្មើមានទាបមានខ្ពស់ ដោយបានចែកចេញជា ០៣តំបន់គឺ

**តំបន់ I៖** នៅភាគខាងជើងជាតំបន់ខ្ពង់រាបខ្ពស់ មានប្រភេទក្រុមដីប្រទះឡាង និងក្រុមដីបាកានត្រូវបានប្រើប្រាស់សម្រាប់ដំណាំកសិ-ឧស្សាហកម្មដំណាំឈើហូបផ្លែ ដំណាំចម្រុះ និងលំនៅឋានជាតំបន់ ។

តំបន់ **II**៖ នៅភាគកណ្តាលនៃឃុំ ជាតំបន់ខ្ពង់រាបមធ្យម មានប្រភេទក្រុមដីប្រទះឡាង ក្រុមដីបាកានក្រុមដីគោកត្រប់ត្រូវបានប្រើប្រាស់សម្រាប់កសិ-ឧស្សាហកម្ម ដំណាំឈើហូបផ្លែ ដំណាំចម្រុះ និងលំនៅឋាន ។

តំបន់ IIIៈ នៅភាគខាងត្បូងនៃឃុំ ជាតំបន់ទំនាបមធ្យម មានប្រភេទក្រុមដីព្រៃខ្មែរ ក្រុមដីប្រទះឡាង ក្រុមដីបាកាន ត្រូវបានប្រើប្រាស់ដំណាំស្រូវវស្សា ដំណាំចម្រុះ និងលំនៅឋាន ។

ផែនទី 3ៈ ផែនទីសណ្ឋានដីឃុំក្រយា




ផែនទី 4ៈ តំបន់វិភាគប្រព័ន្ធគេ្យត្របរិស្ថានឃុំក្រយា



តារាង 16៖ ដ្យាក្រាមពំនុះកាត់ទទឹង ឃុំក្រយា ស្រុកសន្ទុក

| តំបន់<br>បរិយាយ | តំបន់ I | តំបន់ II | តំបន់ III |
|---|---|---|---|
| រូបថតតំណាងតំបន់ភ្សេត្រ-បរិស្ថាន |  |  |  |
| ឈ្មោះតំបន់ | ជាតំបន់ខ្ពង់រាបមធ្យមដំណាំកសិឧស្សាហកម្ម, ដំណាំឈើហូបផ្លែ, ដំណាំចម្រុះនិងលំនៅឋាន | ជាតំបន់ខ្ពង់រាបទាបដំណាំកសិឧស្សាហកម្ម, ដំណាំឈើហូបផ្លែ, ដំណាំចម្រុះនិងលំនៅឋាន | តំបន់ទំនាបមធ្យមដំណាំស្រូវវស្សា, ដំណាំចម្រុះនិងលំនៅឋាន |
| រៀបរាប់ដោយសង្ខេប | -ដីមានរាងជម្រាលខាងជើងឆៀងខាងកើត<br>- ស្រោចស្រដោយទឹកកភ្លៀង<br>- មានដំណាំកសិឧស្សាហកម្ម<br>- មានដំណាំឈើហូបផ្លែ<br>- មានដំណាំចម្រុះ<br>- មានដំណាំដំឡូងមី<br>- មានការចិញ្ចឹមសត្វពាហនៈ<br>- មានលំនៅឋាន<br>- មានផ្ទៃដីសរុប ៥០.១៨៦,៨៤ ហិកតា (ផ្ទៃដីជាក់ស្តែងតាមផែនទីទូទាំងប្រទេស) | - ដីមានជម្រាលរាបស្មើ<br>- ស្រោចស្រពដោយទឹកភ្លៀង<br>- មានដំណាំកសិឧស្សាហកម្ម<br>- មានដំណាំឈើហូបផ្លែ<br>- មានដំណាំចម្រុះ<br>- មានដំណាំដំឡូងមី<br>- មានការចិញ្ចឹមសត្វពាហនៈ<br>- មានលំនៅឋាន<br>- មានផ្ទៃដីសរុប ២០.៦៥៦,៧៧ ហិកតា (ផ្ទៃដីជាក់ស្តែងតាមផែនទីទូទាំងប្រទេស) | - ដីមានជម្រាលរាបស្មើ<br>- ស្រោចស្រពដោយទឹកភ្លៀង<br>- មានដំណាំស្រូវវស្សា<br>- មានដំណាំចម្រុះ<br>- មានការចិញ្ចឹមសត្វពាហនៈ<br>- មានលំនៅឋាន<br>- មានផ្ទៃដីសរុប ៩០,៧២៨.៩៨ ហិកតា(ផ្ទៃដីជាក់ស្តែងតាមផែនទីទូទាំងប្រទេស) |
| ឋានលេខា | - តំបន់ខ្ពង់រាបស្មើដូចទឹករលក | - តំបន់រាបស្មើទាបជាងតំបន់ទី I | - តំបន់រាបស្មើទាបជាងតំបន់ទី II |
| ប្រភេទដី | - ក្រុមដីប្រទះឡាង<br>- ក្រុមដីបាកាន | - ក្រុមដីប្រទះឡាង<br>- ក្រុមដីបាកាន<br>- ក្រុមដីគោកត្រប់ | - ក្រុមដីព្រៃខ្មែរ<br>- ក្រុមដីប្រទះឡាង<br>- ក្រុមដីបាកាន |
| ជលសាស្ត្រ | - ទឹកភ្លៀង<br>- ទឹកស្ទឹងតាំងក្រសាំង<br>- ទឹកស្ទឹងជីនិត | - ទឹកភ្លៀង<br>- ទឹកស្ទឹងតាំងក្រសាំង<br>- ទឹកស្ទឹងជីនិត | - ទឹកភ្លៀង<br>- ទឹកស្ទឹងតាំងក្រសាំង<br>- ទឹកស្ទឹងជីនិត |
| ធនធានទឹក | - អណ្តូងទឹក<br>- ស្ទឹងតាំងក្រសាំង<br>- ស្ទឹងជីនិត<br>- អូរ<br>- ត្រពាំងធម្មជាតិ<br>- បឹងធម្មជាតិ | - អណ្តូងទឹក<br>- ស្ទឹងតាំងក្រសាំង<br>- ស្ទឹងជីនិត<br>- អូរ<br>- ត្រពាំងធម្មជាតិ<br>- បឹងធម្មជាតិ | - អណ្តូងទឹក<br>- ស្ទឹងតាំងក្រសាំង<br>- ស្ទឹងជីនិត<br>- អូរ<br>- ត្រពាំងធម្មជាតិ<br>- បឹងធម្មជាតិ |
| គំរបដី/ការប្រើប្រាស់ដី | -ដីដាំដំណាំកសិឧស្សាហកម្ម (កៅស៊ូ)<br>- ដីដាំដំណាំឈើហូបផ្លែ<br>- ដីដាំដំណាំចម្រុះ<br>- ដីដាំដំណាំដំឡូងមី | -ដីដាំដំណាំកសិឧស្សាហកម្ម (កៅស៊ូ)<br>- ដីដាំដំណាំឈើហូបផ្លែ<br>- ដីដាំដំណាំចម្រុះ<br>- ដីដាំដំណាំដំឡូងមី | - ដីដាំដំណាំស្រូវវស្សា<br>- ដីដាំដំណាំចម្រុះ<br>- វាលស្រែ<br>- ដីលំនៅឋាន<br>- ស្ទឹងតាំងក្រសាំង |

| | | | |
|---|---|---|---|
| | - ដីព្រៃរបស់រដ្ឋ ដីព្រៃសហគមន៍<br>- ដីលំនៅឋាន<br>- ស្ទឹងតាំងក្រសាំង ស្ទឹងជីនិត<br>- អូរ ត្រពាំងធម្មជាតិ<br>- បឹងធម្មជាតិ | - ដីព្រៃរបស់រដ្ឋ ដីព្រៃសហគមន៍<br>- ដីលំនៅឋាន<br>- ស្ទឹងតាំងក្រសាំង ស្ទឹងជីនិត<br>- អូរ ត្រពាំងធម្មជាតិ<br>- បឹងធម្មជាតិ | - ស្ទឹងជីនិត<br>- អូរ<br>- ត្រពាំងធម្មជាតិ<br>- បឹងធម្មជាតិ<br>- ប្រឡាយអូររន្ធ |
| ដំណាំសំខាន់ៗ | - ដំណាំកៅស៊ូ ដំណាំស្វាយចន្ទី<br>- ដំណាំដំឡូងមី<br>- ដំណាំស្វាយកែវរមៀត<br>- ដំណាំអំពៅ ដំណាំឪឡឹក<br>- ដំណាំចេក | - ដំណាំកៅស៊ូ<br>- ដំណាំស្វាយចន្ទី<br>- ដំណាំដំឡូងមី<br>- ដំណាំស្វាយកែវរមៀត<br>- ដំណាំឪឡឹក ដំណាំចេក | - ដំណាំស្រូវវស្សា<br>- ដំណាំឪឡឹក<br>- ដំណាំចម្រុះ |
| ពូជស្រូវ | - ពូជស្រូវផ្ការំដួល<br>- ពូជស្រូវឆ្លឹងមាន់<br>- ពូជស្រូវក្រឹម | - ពូជស្រូវផ្ការំដួល<br>- ពូជស្រូវខា៤<br>- ពូជស្រូវលាក់សន្លឹក<br>- ពូជស្រូវនាងគង់ | - ពូជស្រូវផ្ការំដួល<br>- ពូជស្រូវខា៤<br>- ពូជស្រូវលាក់សន្លឹក<br>- ពូជស្រូវនាងគង់ |
| ការប្រើប្រាស់ជី | - ដេអាប៉េ (18-46-0)<br>- អ៊ុយរ៉េ (46-0-0)<br>- កាលី ( 0-0-60)<br>- ជី 20-20-15-TE<br>- ជីសរីរាង្គ ជីធម្មជាតិ | - ដេអាប៉េ (18-46-0)<br>- អ៊ុយរ៉េ (46-0-0)<br>- កាលី ( 0-0-60)<br>- ជី 20-20-15-TE<br>- ជីសរីរាង្គ ជីធម្មជាតិ | - ដេអាប៉េ (18-46-0)<br>- អ៊ុយរ៉េ (46-0-0)<br>- កាលី ( 0-0-60)<br>- ជី 20-20-15-TE<br>- ជីសរីរាង្គ ជីធម្មជាតិ |
| ការចិញ្ចឹមសត្វ | - គោ,ក្របី,ជ្រូក,មាន់,ទា | - គោ,ក្របី,ជ្រូក,មាន់,ទា | - គោ,ក្របី,ជ្រូក,មាន់,ទា |
| ដីរបស់រដ្ឋ/ ដីសហគមន៍ | - សាលារៀន វត្តអារាម<br>- ភ្នំព្រះធាតុ(ភូមិត្រពាំងឫស្សី)ទំហំ ប្រហែល ១,៥០ហិកតា<br>- ព្រៃគ្រួច(ក្នុងចំការកៅស៊ូក្រុមហ៊ុន រឹទ្ធមុនី,សំណាងលាភហៅ៩៥) ទំហំ២ ហិកតា<br>- ដីព្រៃសហគមន៍វាលអូរក្តីចំនួន ៤២១៨ហិកតា<br>- អូរតាព្រំ អូរធំ អូរបឹងរូង<br>- ត្រពាំងឈូក ត្រពាំងព្រៃ<br>- ត្រពាំងកូនអន្ទង់<br>- ដីមានទំនាស់ជាមួយប្រជាពលរដ្ឋ (ដីសម្បទានសង្គមកិច្ចអតីតយុទ្ធជន, ក្រុមហ៊ុននុភាពសុភី, ភូមិ សូងសាង,ភូមិថ្មសំលៀង) | - សាលារៀន<br>- វត្តអារាម<br>- សាលាឃុំ<br>- អូរផ្ការ<br>- អូររន្ធ<br>- អូរព្រៃជំរ<br>- ត្រពាំងផ្លុង<br>- ត្រពាំងបឹង<br>- ត្រពាំងក្បាលដំរី<br>- ត្រពាំងក្រយា<br>- ត្រពាំងអញ្ចាញ<br>- ត្រពាំងសន្ទង<br>-មានទំនាស់ជាមួយប្រជាពលរដ្ឋ (ដីសម្បទានសង្គមកិច្ចអតីត យុទ្ធជន) | - សាលារៀន<br>- វត្តអារាម<br>- សាលាឆទានតាម៉ិញ |
| បញ្ហាផ្សេងៗ | - បម្រែបម្រួលអាកាសធាតុ<br>- ខ្វះប្រព័ន្ធស្រោចស្រព<br>-សត្វល្អិតជម្ងឺបំផ្លាញដំណាំដំឡូងមីនិង ស្វាយចន្ទី<br>- ពូជមិនសុទ្ធល្អ<br>-ជម្ងឺលើសត្វចិញ្ចឹម(គោ ក្របី មាន់)<br>- ខ្វះកម្លាំងពលកម្ម | - បម្រែបម្រួលអាកាសធាតុ<br>- ខ្វះប្រព័ន្ធស្រោចស្រព<br>-សត្វល្អិតជម្ងឺបំផ្លាញដំណាំដំឡូងមី និងស្វាយចន្ទី<br>- ពូជមិនសុទ្ធល្អ<br>-ជម្ងឺលើសត្វចិញ្ចឹម(គោ ក្របី មាន់)<br>- ខ្វះកម្លាំងពលកម្ម | - បម្រែបម្រួលអាកាសធាតុ<br>- សត្វល្អិតចង្រៃបំផ្លាញដំណាំ<br>- ពូជស្រូវមិនសុទ្ធល្អ<br>- ជម្ងឺលើសត្វចិញ្ចឹម(គោ,ក្របី មាន់,ទា)<br>- ខ្វះកម្លាំងពលកម្ម<br>- ខ្វះបច្ចេកទេសផលិតកម្មដំណាំ |

| | | | |
|---|---|---|---|
| | -ខ្វះបច្ចេកទេសផលិតកម្មដំណាំដំឡូងមី<br>- តម្លៃដំឡូងមីមិនចិតថេរ(ឡើងចុះតាមឈ្មួញ) | -ខ្វះបច្ចេកទេសផលិតកម្មដំណាំដំឡូងមី<br>- តម្លៃដំឡូងមីមិនចិតថេរ(ឡើងចុះតាមឈ្មួញ) | ស្រូវ<br>- ខ្វះបច្ចេកទេសផលិតកម្មគ្រាប់ពូជស្រូវ<br>- តម្លៃស្រូវថោក |
| កាឡានុវត្តភាព/ឱកាស | - ពង្រីកការដាំដុះដំណាំកៅស៊ូ<br>- ពង្រីកការដាំដុះដំណាំស្វាយចន្ទី<br>-ពង្រីកការដាំដុះស្វាយកែវល្មៀត<br>- ពង្រីកការដាំដុះដំណាំដំឡូងមី<br>- ពង្រីកការដាំដុះដំណាំអំពៅ<br>- ពង្រីកការដាំដុះដំណាំចេក<br>- ពង្រីកការដាំដុះដំណាំឪឡឹក<br>- ពង្រីកការចិញ្ចឹមសត្វពាហនៈ<br>- កែលម្អនិងការគ្រប់គ្រងជីវជាតិដី<br>-ផ្តល់ចំណេះដឹងបច្ចេកទេសកសិកម្ម | -ពង្រីកការដាំដុះដំណាំកៅស៊ូ(តិចជាងតំបន់ I)<br>- ពង្រីកការដាំដុះដំណាំស្វាយចន្ទី<br>-ពង្រីកការដាំដុះស្វាយកែវល្មៀត<br>- ពង្រីកការដាំដុះដំណាំដំឡូងមី<br>- ពង្រីកការដាំដុះដំណាំចេក<br>- ពង្រីកការដាំដុះដំណាំឪឡឹក<br>- ពង្រីកការចិញ្ចឹមសត្វពាហនៈ<br>- កែលម្អនិងការគ្រប់គ្រងជីវជាតិដី<br>-ផ្តល់ចំណេះដឹងបច្ចេកទេសកសិកម្ម<br>-ជួសជុលកសាងប្រព័ន្ធស្រោចស្រព | - ពង្រីកការដាំដុះដំណាំស្រូវវស្សា<br>- ពង្រីកផលិតកម្មពូជស្រូវវស្សា<br>- ពង្រីកការដាំដុះដំណាំឪឡឹក<br>- ពង្រីកការចិញ្ចឹមសត្វពាហនៈ<br>- កែលម្អនិងការគ្រប់គ្រងជីវជាតិដី<br>- ផ្តល់ចំណេះដឹងបច្ចេកទេសកសិកម្ម<br>- ជួសជុល និងកសាងប្រព័ន្ធស្រោចស្រព |

បើយោងតាមរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន និងក្រុមប្រឹក្សាឃុំក្រយា បានបង្ហាញឱ្យឃើញថា នៅក្នុងឃុំមានប្រភពទឹកសំខាន់ៗដូចជាទឹកភ្លៀង ស្ទឹងតាំងក្រសាំង ស្ទឹងជីនិត អូរ ត្រពាំងធម្មជាតិ បឹងធម្មជាតិ ព្រមទាំងមានប្រឡាយមេចំនួន ០២ខ្សែ ប្រវែង ១៩ ២២០,៩៨ ម៉ែត្រ និងប្រឡាយរងចំនួន ០៥ខ្សែ មានប្រវែង ២ ៣២០,៥៥ម៉ែត្រ និងប្រឡាយតូចមានចំនួន ០៣ខ្សែ ប្រវែង ៣០៤៦,២៤ម៉ែត្រ។ ចំណែកទឹកក្រោមដីនៅក្នុងឃុំក្រយាមានការប្រើប្រាស់ តាមរយៈអណ្តូងស្នប់សម្រាប់ស្រោចស្រព និងសម្រាប់ការប្រើប្រាស់ទូទៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋប៉ុណ្ណោះ ។ ប្រភពទឹកដែលនាំទឹកមកប្រើប្រាស់នៅក្នុងឃុំ មានតែរដូវវស្សាពីស្ទឹងតាំងក្រសាំង និងស្ទឹងជីនិត តាមរយៈប្រឡាយមេ និងរង ដែលឃុំបានជីក និងស្ពានសម្រាប់នាំយកទឹកមកស្រោចស្រពនៅក្នុងភូមិសាស្ត្រដីស្រែវស្សា និងស្រែប្រាំង ក្រៅពីស្ទឹងតាំងក្រសាំង និងស្ទឹងជីនិត ឃុំមានបឹង ស្រះទឹកដែលជាប្រភពទឹកបន្ទាប់បន្សំតែប៉ុណ្ណោះ ។

តារាង 17៖ ប្រព័ន្ធធារាសាស្ត្រ

| ល.រ | ប្រភេទប្រឡាយ | ប្រវែង (ម) |
|---|---|---|
| ១ | ប្រឡាយមេ | ៧ ២៦៨,៥៦ |
| ២ | ប្រឡាយមេ | ៤ ១៨៣,១៥ |
| ៣ | ប្រឡាយរង | ១ ០៥០,២៥ |
| ៤ | ប្រឡាយរង | ៣ ៧១៨,៨៩ |
| ៥ | ប្រឡាយរង | ៦៦១,៧២ |
| ៦ | ប្រឡាយរង | ២ ៤៧១,១៩ |
| ៧ | ប្រឡាយរង | ១ ៤៨៧,៣៩ |
| ៨ | ប្រឡាយតូច | ២៧០,៧៨ |
| ៩ | ប្រឡាយតូច | ១ ៦៦៧,៤៧ |

| | | |
|---|---|---|
| ១០ | ប្រឡាយតូច | ១ ១០៧,៩៩ |
| ១១ | ទំនប់ទឹក | ២៩៩,៧០ |
| ១២ | ទំនប់ទឹក | ៦១៥,៤១ |
| ១៣ | អូរ | ៧៣៦,៤២ |

រូបភាព 3៖ ប្រឡាយរង



ផែនទី 5៖ ផែនទីប្រព័ន្ធធារាសាស្ត្រ ឃុំក្រយា



### ១.២.២.អាកាសធាតុ (ពិពណ៌នាតាមរដូវកាល)

នៅក្នុងឃុំក្រយា ក៏ដូចជានៅទូទាំងខេត្ត គឺទទួលរបបខ្យល់មកពីតំបន់ត្រូពិច ដែលមានអាកាសធាតុក្ដៅ ហើយសើម ។ របបខ្យល់មូសុង គឺបានពាំនាំមកនូវចំនួនទឹកភ្លៀងយ៉ាងច្រើនមកជាមួយ ដែលអំណោយផលទៅដល់ការធ្វើកសិកម្មនានា និងដាំដំណាំផ្សេងៗទៀត ។

បើយោងទៅតាមប្រភពទិន្នន័យពីមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ធំ ប្រចាំស្រុកសន្ទុកក្នុងឆ្នាំ ២០១៧ បានបង្ហាញឱ្យឃើញថា នៅក្នុងស្រុកសន្ទុកទាំងមូលមានភ្លៀងធ្លាក់ចំនួន ១២៩ដង និងមានបរិមាណទឹកភ្លៀងប្រចាំឆ្នាំចំនួន ១ ៥៦៧,៩ម.ម ។

**អំពីអាកាសធាតុ៖**

- រដូវរងារ៖ ខែ វិច្ឆិកា ដល់ ខែ មីនា ( ២០ ទៅ ២៨ អង្សា )
- រដូវក្ដៅ៖ ខែ មីនា ដល់ ខែ ឧសភា ( ៣០ ទៅ ៣៥ អង្សា )
- រដូវភ្លៀង៖ ខែ ឧសភា ដល់ ខែ តុលា (២៣ ទៅ ៣០ អង្សា ជាមួយនឹងការឡើងសំណើមទៅដល់ ៩០ ភាគរយ )នៅរដូវនេះជារៀងរាល់ឆ្នាំ គឺមានភ្លៀងធ្លាក់ខ្លាំង នៅពេលរសៀល និងល្ងាច។

សំណើម៖ ឃុំក្រយា មានសំណើមជាមធ្យម៤៨ភាគរយ និងមានល្បឿនខ្យល់៣គីឡូម៉ែត្រ/១ម៉ោង។

តារាង 18៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ

| ខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| បរិមាណទឹកភ្លៀង | ១៣ | ១១ | ៣៤ | ៦៨.៦ | ១៩៥.១ | ២៤៦.៤ | ២២២.៩ | ១៥៨.២ | ២២៦.៦ | ២២៥.១ | ១០៦.២ | ៦០.៨ |
| ចំនួនថ្ងៃភ្លៀងធ្លាក់ | ៣ | ១ | ៥ | ៥ | ១៣ | ១៧ | ១៦ | ១៧ | ១៤ | ១៦ | ១៦ | ៦ |

ដ្យាក្រាម 3៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ




ប្រភពទិន្នន័យ៖ *មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ធំ ឆ្នាំ២០១៧*

### ១.២.៣.ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន

ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍រួមមាន ផ្លូវគោក ផ្លូវដែក ផ្លូវទឹក និងផ្លូវអាកាស ។ បច្ចុប្បន្នឃុំក្រយាមានតែប្រព័ន្ធគមនាគមន៍ផ្លូវគោកនិងផ្លូវទឹកប៉ុណ្ណោះ ហើយបានដើរតួយ៉ាងសំខាន់ក្នុងការសម្រួលដល់ការដឹកជញ្ជូន និងការធ្វើដំណើររបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ដែលក្នុងនោះមានផ្លូវគ្រួសក្រហម ប្រវែង ២២ ១៩៤,៦១ម៉ែត្រ ចេញ

ពីឃុំទំរីង ស្រុកសណ្តាន់ ឆ្ពោះទៅកាន់ឃុំកំពង់ថ្ម និងផ្លូវគ្រួសក្រហមមួយខ្សែទៀតប្រវែង ២១ ០០០ម៉ែត្រ ជាច្រកចេញ-ចូលសំខាន់របស់ឃុំ ដែលទំនាក់ទំនងតភ្ជាប់ជាមួយផ្លូវជាតត្រង់ចំណុចភូមិដងក្តារ កាត់តាមភូមិថ្មសំលៀងបន្តរហូតព្រំប្រទល់ឃុំបឹងល្វា និងផ្លូវក្នុងឃុំផ្សេងៗគ្រប់គ្រាន់អាចតភ្ជាប់ទំនាក់ទំនងពីភូមិមួយទៅភូមិមួយ រួមទាំងអាចទំនាក់ទំនងទៅក្រៅឃុំបានយ៉ាងងាយស្រួល ។ ចំណែកផ្លូវទឹកមានចរាចរតាមស្ទឹងជីនិត ដែលធ្វើចរាចរបានតែកាណូតស្ទាច់តូចៗ។

ឃុំក្រយា មានផ្លូវគោកចំនួន ១២៦ខ្សែ ប្រវែងសរុប ៣០២ ៨៦៣,៨៧ម៉ែត្រ ក្នុងនោះផ្លូវកៅស៊ូ ០១ខ្សែ ប្រវែង ៤០ ៦០៦,៣៧ម៉ែត្រ ផ្លូវក្រាលគ្រួសក្រហមមាន ៥៨ ខ្សែ ប្រវែង ១០៩ ០៨៩,៣៩ ម៉ែត្រ និង ផ្លូវដីស ឬ ផ្លូវរទេះមាន ៦៧ ខ្សែ ប្រវែង ១៥៣ ១៦៨,១១ម៉ែត្រ ព្រមទាំងផ្លូវទឹកតាមដងស្ទឹងជីនិត ។

តារាង 19៖ ប្រព័ន្ធផ្លូវដឹកជញ្ជូន

| ល.រ | ប្រភេទផ្លូវ | ចំនួនខ្សែផ្លូវ | ប្រវែង (ម៉ែត្រ) |
|---|---|---|---|
| ១ | ផ្លូវកៅស៊ូ | ១ខ្សែ | ៤០ ៦០៦,៣៧ |
| ២ | ផ្លូវគ្រួសក្រហម ឬក្រាលថ្ម | ៥៨ខ្សែ | ១០៩ ០៨៩,៣៩ |
| ៣ | ផ្លូវដីស ឬផ្លូវរទេះ | ៦៧ខ្សែ | ១៥៣ ១៦៨,១១ |

រូបភាព 4៖ ប្រព័ន្ធគមនាគមន៍


ប្រភេទផ្លូវកៅស៊ូ


ប្រភេទផ្លូវគ្រួសក្រហម


ប្រភេទផ្លូវលំដីស

ផែនទី ៦៖ ផែនទីហេដ្ឋារចនាសម្ព័ន្ធ ឃុំក្រយា




## ១.២.៤. បរិក្ខាសាធារណ:

### ក. ស្ថានភាពប្រើប្រាស់អគ្គិសនី

បេសកកម្មរបស់មន្ទីររ៉ែ និងថាមពលខេត្តកំពង់ធំ គឺដឹកនាំជំរុញការគ្រប់គ្រង និងសមាហរណកម្មលើវិស័យរ៉ែ និងថាមពលរួមទាំងប្រេងកាត ឧស្ម័ន និងអគ្គិសនី នៅក្នុងសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ចសង្គម នៅមូលដ្ឋាន និងក្នុងខេត្តកំពង់ធំ ក្នុងនាមជាសេនាធិការឱ្យក្រសួងរ៉ែ និងថាមពល ។

នៅក្នុងឃុំក្រយា បើយោងតាមទិន្នន័យពីមន្ទីរផែនការនៅឆ្នាំ ២០១៧ បានបង្ហាញឱ្យឃើញថានៅក្នុងឃុំនេះមានប្រជាពលរដ្ឋប្រើប្រាស់បណ្តាញអគ្គិសនីចំនួន ១ ០៩០ខ្នង ស្មើនឹង ៣២,៨ភាគរយ ផ្ទះបំភ្លឺទៅដោយអាគុយមានចំនួន ១ ៦១៦ខ្នង ស្មើនឹង ៤៨,៦ភាគរយ ផ្ទះប្រើប្រាស់បន្ទះសូឡាចំនួន ៥១៣ខ្នងផ្ទះ ស្មើនឹង ១៥,៤ភាគរយ ផ្ទះបំភ្លឺដោយឡជីវឧស្ម័នមានចំនួន ០៧ ខ្នងផ្ទះ ស្មើនឹង ០,២ ភាគរយ ។ ដូច្នេះប្រជាពលរដ្ឋប្រើប្រាស់អាគុយមានចំនួនច្រើនជាងគេ និងផ្ទះបំភ្លឺដោយឡជីវឧស្ម័នមានចំនួនតិចជាងគេ ។

តារាង 20៖ ស្ថិតិអ្នកប្រើប្រាស់អគ្គិសនី

| **បរិយាយ** | **២០១៦(%)** | **២០១៧** | |
|---|---|---|---|
| | | **ភាគរយ(%)** | **ចំនួនផ្ទះ** |
| ផ្ទះបំភ្លឺដោយបណ្តាញអគ្គិសនី | ២៧,២ | ៣២,៨ | ១ ០៩០ |
| ផ្ទះបំភ្លឺដោយអាគុយ | ៤៧,៧ | ៤៨,៦ | ១ ៦១៦ |
| ផ្ទះបំភ្លឺដោយបន្ទះសូឡា | ៩,៤ | ១៥,៤ | ៥១៣ |
| ផ្ទះបំភ្លឺដោយឡជីវឧស្ម័ន | ១,១ | ០,២ | ៧ |

ប្រភពទិន្នន័យ៖ *CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ក្រយា ខែឧសភា ឆ្នាំ២០១៨*

## ខ. ប្រព័ន្ធទឹកស្អាត

អាជ្ញាធរខេត្តកំពង់ធំ បានអំពាវនាវឱ្យប្រជាពលរដ្ឋ ដែលធ្លាប់ប្រើប្រាស់ទឹក ស្ទឹង ត្រពាំង ឬអណ្តូងដៃ ងាកមកបរិភោគទឹកស្អាតវិញ ដើម្បីជួយលើកកម្ពស់សុខភាពនិងលើកស្ទួយអនាម័យនៅតាមជនបទ។ នៅក្នុងឃុំក្រយា បានចំណាយថវិកាមូលនិធិឃុំ ក៏បានកៀងគរធនធានពីខាងក្រៅក្នុងការសាងសង់ដូចជា៖ អណ្តូងស្នប់ ឬអណ្តូងចម្រុះមានចំនួន ១០៩អណ្តូង អណ្តូងជីកមានការពារចំនួន ៣៤៦អណ្តូង និងចំនួនអណ្តូងជីកគ្មានការពារចំនួន ១ ៩០០អណ្តូង ចំនួនស្រះទឹកដែលប្រើប្រាស់មានចំនួន ០៤ស្រះ ហើយនៅក្នុងនោះចំនួនអណ្តូងជីកគ្មានការពារមានប្រជាពលរដ្ឋប្រើប្រាស់មានចំនួនច្រើនជាគេ និងចំនួនស្រះទឹកដែលប្រើប្រាស់មានចំនួនតិចជាងគេ ។

តារាង 21៖ ស្ថិតិប្រភពទឹកប្រើប្រាស់

| ល.រ | បរិយាយ | ២០១៦ | ២០១៧ |
|---|---|---|---|
| ១ | ចំនួនអណ្តូងស្នប់ឬអណ្តូងចម្រុះ | ៥៥ | ១០៩ |
| ២ | ចំនួនអណ្តូងជីកមានការពារ | ២៣៤ | ៣៤៦ |
| ៣ | ចំនួនអណ្តូងជីកគ្មានការពារ | ១ ៥៥៩ | ១ ៩០០ |
| ៤ | ចំនួនស្រះទឹកដែលប្រើប្រាស់ | 0 | ៤ |

ប្រភពទិន្នន័យ៖ *CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ក្រយា ខែឧសភា ឆ្នាំ២០១៨*

# ១.៣.ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

## ១.៣.១.ស្ថានភាពការកាន់កាប់ និងគ្រប់គ្រង

ផែនទី 7៖ ផែនទីប្រើប្រាស់ដីសាមញ្ញ ឃុំក្រយា



ផែនទី ៨៖ ផែនទីប្រើប្រាស់ដីលម្អិត ឃុំក្រយា



តារាង 22៖ តារាងរាយលម្អិតតាមប្រភេទនៃការប្រើប្រាស់ដីបច្ចុប្បន្ន ឃុំក្រយា

| ប្រភេទដីប្រើប្រាស់ | បរិយាយ | ផ្ទៃដី( ហិកតា ) | ភាគរយ |
|---|---|---|---|
| **ក.ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ** | | **៧៣៤,៦២** | **០,៨៣** |
| -ដីលំនៅឋាន ភូមិក្រៅគម្របព្រៃឈើឆ្នាំ២០០២ | តំបន់ដីសង់លំនៅឋាន | ៥៣៨,៨១ | ០,៦១ |
| -ដីលំនៅឋាន ភូមិក្នុងគម្របព្រៃឈើឆ្នាំ២០០២ | តំបន់ដីសង់លំនៅឋាន | ១៩៥,៨១ | ០,២២ |
| **ខ.ដីកសិកម្ម** | | **៨០ ៣១២,៨២** | **៩០,៦៦** |
| **ខ.១.ដីស្រែវស្សា** | | **២ ៤៦៨,១** | **២,៧៩** |
| -ដីស្រែវស្សាក្រៅគម្របព្រៃឈើឆ្នាំ២០០២ | តំបន់ដីធ្វើស្រែវស្សា | ២ ៤២៦,០៣ | ២,៧៤ |
| -ដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ២០០២ | តំបន់ដីធ្វើស្រែវស្សា | ៤២,០៧ | ០,០៥ |
| **ខ.២.ដីចម្ការ** | | **៧៧ ៨៤៤,៧២** | **៨៧,៨៨** |
| -ដីចម្ការក្រៅគម្របព្រៃឈើឆ្នាំ២០០២ | តំបន់ដាំដំណាំ | ៨ ៧៣៨,៥៣ | ៩,៨៦ |
| -ដីចម្ការក្នុងគម្របព្រៃឈើឆ្នាំ២០០២ | តំបន់ដាំដំណាំ | ៦៩ ១០៦,១៩ | ៧៨,០១ |
| **គ.ដីព្រៃ/គម្របព្រៃ** | | **៧ ០៥៣,៥៧** | **៧,៩៦** |
| -ព្រៃល្បោះ | តំបន់សហគមន៍ព្រៃឈើ | ៥ ៤៤១,៤៤ | ៦,១៤ |
| -ព្រៃស្រោង | តំបន់មានព្រៃឈើធំៗ | ១ ៦១២,១៣ | ១,៨២ |
| **ឃ.ផ្ទៃទឹក និងខ្សែទឹក** | | **៤៨១,៥៨** | **០,៥៤** |
| -ស្ទឹងមានទឹកតាមរដូវ | ស្ទឹងមានទឹកតែរដូវវស្សា | ៤០៤,៣៤ | ០,៤៦ |
| -ស្រះក្រៅគម្របព្រៃឈើឆ្នាំ២០០២ | ទីតាំងស្រះទឹក | ២៨,៥៥ | ០,០៣ |
| -ស្រះក្នុងគម្របព្រៃឈើឆ្នាំ២០០២ | ទីតាំងស្រះទឹក | ២៩,៤៨ | ០,០៣ |
| -បឹងមានទឹកតាមរដូវ | តំបន់ដីបឹង | ១៩,២១ | ០,០២ |
| **ផ្ទៃដីឃុំសរុប** | | **៨៨ ៥៨២,៥៩** | **១០០** |

### ក. ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ

**-ដីលំនៅឋាន ភូមិ**

ដីលំនៅឋានភូមិ គឺជាដីត្រូវបានប្រើប្រាស់សម្រាប់លំនៅឋាន មានលាយសួនដំណាំ និងឈើហូបផ្លែៗ នៅក្នុងឃុំក្រយា ដីលំនៅឋានភូមិមានស្ថិតនៅតាមតំបន់ប្រមូលផ្តុំភូមិ ដែលស្ថិតនៅអមតាមដងផ្លូវជាតិលេខជាតិ ២៦៤មួយផ្នែកធំ ដែលសព្វថ្ងៃជាផ្លូវគ្រួសក្រហម ចេញពីឃុំកំពង់ថ្មកាត់កណ្តាលឃុំ ពីត្បូងឆៀងខាងលិចទៅជើងឆៀងខាងកើតនៃឃុំឆ្ពោះទៅកាន់ឃុំទំរីង ស្រុកសណ្តាន់ មាន ០៨ ភូមិ គឺភូមទក់ ភូមិត្រពាំងព្រីង ភូមិតាម៉ិញ ភូមិសុភមង្គល ភូមិក្រយា ភូមិដងក្ដារ ភូមិឈើទាលជ្រុំ និងភូមិត្រពាំងឫស្សី និងមួយផ្នែកទៀត ចេញពីផ្លូវជាតិលេខ ២៦៤ មានផ្លូវគ្រួសក្រហមមួយបត់មកខាងកើតឃុំត្រង់ភូមិក្រយា មានភូមិថ្មសំលៀង ភូមិអូរទឹកថ្លា និងភូមិបន្ទាយរងៀង និងមានភូមិពីរទៀតនៅតាមផ្លូវគ្រួសក្រហមមួយទៀតកាត់ទៅខាងកើតឃុំជាប់ព្រំប្រទល់ឃុំបឹងល្វាមានភូមិសូសាង និងភូមិភ្នំប្រាថ់ ដែលមានផ្ទៃដីសរុបទំហំ ៧៣៤,២៦ ហិកតា ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹង

នៃរបាយការណ៍វិភាគប្រព័ន្ធកៀ្យត្រ-បរិស្ថាន ដីលំនៅឋាន ភូមិទាំងអស់ ជាតំបន់ទំនាបមធ្យមមានប្រភេទក្រុមដីព្រៃខ្មែរ ក្រុមដីប្រទះឡាង និងក្រុមដីបាកាន ជាដីដែលកាន់កាប់ដោយប្រជាពលរដ្ឋ(ដីកម្មសិទ្ធឯកជន) និងជាដីសាធារណៈរបស់រដ្ឋ ដែលត្រូវបានចុះបញ្ជីជាលក្ខណៈប្រព័ន្ធបានចំនួន ២០ភាគរយហើយ ។ ដីលំនៅឋានភូមិត្រូវបានបែងចែកជាពីរតំបន់ផ្សេងគ្នាដូចជា៖

**-ដីលំនៅឋាន ភូមិ ក្រៅតំបន់គម្របព្រៃឈើឆ្នាំ២០០២៖**

ដីលំនៅឋាន ភូមិ ក្រៅតំបន់គម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ៥៣៨,៨១ហិកតា ដែលស្ថិតភាគខាងត្បូងឆៀងខាងលិចតាមផ្លូវជាតិលេខ២៦៤ មាន៦ភូមិ គឺភូមិទក់ ភូមិត្រពាំងព្រីង ភូមិតាម៉ិញ ភូមិសុភមង្គល ភូមិក្រយា និងភូមិដងក្ដារ ។ ដីលំនៅឋាននេះ ជាដីកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋ ដែលប្រជាពលរដ្ឋមានសិទ្ធិកាន់កាប់ និងប្រើប្រាស់បាន ។

**-ដីលំនៅឋានភូមិ ក្នុងតំបន់គម្របព្រៃឈើឆ្នាំ២០០២៖**

ដីលំនៅឋានភូមិ ក្នុងតំបន់គម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ១៩៥,៨១ហិកតា ដែលស្ថិតតាមផ្លូវជាតិលេខ២៦៤នេះ តែបន្តមកភាគកណ្ដាលនៃឃុំទៅខាងជើងឆៀងខាងកើតនៃឃុំ មាន៦ភូមិ គឺភូមិត្រពាំងឬស្សី ភូមិថ្មសំលៀង ភូមិភ្នំប្រាថ់ ភូមិសូសាង ភូមិអូរទឹកថ្លា និងភូមិបន្ទាយរងៀង។ ដីលំនៅឋាននេះ គឺជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋមានសិទ្ធិត្រឹមតែអាស្រ័យផលតែប៉ុណ្ណោះ ដោយមិនមានសិទ្ធចាត់ចែងនោះឡើយ ។ ដីលំនៅឋានភូមិក្នុងគម្របព្រៃឈើឆ្នាំ ២០០២ នាពេលបច្ចុប្បន្ននេះ ត្រូវបានប្រជាពលរដ្ឋប្រើប្រាស់សម្រាប់តាំងលំនៅឋានរស់នៅរួចហើយ ។

រូបភាព 5៖ ដីលំនៅឋាន ភូមិ



លំនៅឋានភូមិក្រៅគម្របព្រៃឈើឆ្នាំ២០០២



លំនៅឋានភូមិក្នុងគម្របព្រៃឈើឆ្នាំ២០០២

## ខ. ដីកសិកម្ម

### ខ.១. ដីស្រែវស្សា

នៅក្នុងឃុំក្រយាដីស្រែវស្សាមានផ្ទៃដីសរុបទំហំ ២៤៦៨,១ហិកតា ដែលក្នុងនោះមានមួយផ្នែកធំស្ថិតនៅអមសងខាងផ្លូវជាតិលេខ២៦៤ ដល់ត្រឹមផ្លូវកែងគ្រួសក្រហមបត់មកខាងកើត ជាដីស្រែវស្សាក្រៅតំបន់គម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ២ ៤២៦,០៣ហិកតា និងមួយភាគតូចពីផ្លូវកែងតាមបណ្ដោយផ្លូវជាតិលេខ២៦៤ ឆ្ពោះទៅខាងជើងបន្តិចបន្តួច ជាដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ៤២,០៧ហិកតា។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំក្រយានៃរបាយការណ៍វិភាគប្រព័ន្ធកៀ្យត្រ-បរិស្ថាន ដីស្រែវស្សាទាំងអស់ គឺជាតំបន់

ទំនាបមធ្យម មានប្រភេទដីបាកាន និងក្រុមដីប្រទះឡាង ហើយគឺជាដីកម្មសិទ្ធឯកជន ដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ និងជាដីសាធារណៈរបស់រដ្ឋ ដែលត្រូវបានកំពុងតែដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធបាន ២០ភាគរយហើយ ។ ដីស្រែវស្សាទាំងនេះ មានប្រភពទឹកស្រោចស្រពមកពីទឹកភ្លៀង ស្ទឹងជីនិត ស្ទឹងតាំងក្រសាំង បឹង អណ្តូងទឹក និងស្រះជាដើម ។ ដីស្រែវស្សាទាំងនេះត្រូវបានបែងចែកជាពីរតំបន់ផ្សេងៗគ្នាដូចជា៖

**-ដីស្រែវស្សាក្រៅគម្របព្រៃឈើឆ្នាំ២០០២**

នៅឃុំក្រយាមានដីស្រែវស្សាក្រៅគម្របព្រៃឈើឆ្នាំ២០០២ ទំហំផ្ទៃដីសរុបចំនួន ២ ៤២៦,០៣ហិកតា ស្ថិតនៅភាគខាងលិចឆៀងខាងត្បូងនៃឃុំ ។ ដីស្រែវស្សាក្រៅគម្របព្រៃឈើឆ្នាំ ២០០២ ជាតំបន់ខ្ពង់រាបមធ្យម មានប្រភេទក្រុមដីប្រទះឡាង និងក្រុមដីបាកាន គឺជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់ដោយប្រជាពលរដ្ឋ ដែលបច្ចុប្បន្ននេះត្រូវបានប្រជាពលរដ្ឋប្រើប្រាស់ជាដីស្រែ ដែលមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ស្ទឹងជីនិត ស្ទឹងតាំងក្រសាំង ស្រះទឹក និងអណ្តូងទឹកជាដើម ។

**-ដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ២០០២**

នៅក្នុងឃុំក្រយា មានដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ ២០០២ ផ្ទៃដីទំហំសរុបចំនួន ៤២,០៧ ហិកតា ស្ថិតនៅបន្តចាប់ពីដីស្រែវស្សាក្រៅគម្របព្រៃឈើឆ្នាំ២០០២។ ដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ២០០២ ជាតំបន់ខ្ពង់រាបទាបមានប្រភេទក្រុមដីប្រទះឡាង ក្រុមដីគោកត្រប់ និងក្រុមដីបាកាន គឺជាដីសាធារណៈរបស់រដ្ឋ នាពេលបច្ចុប្បន្ននេះត្រូវបានប្រជាពលរដ្ឋប្រើប្រាស់ជាដីស្រែ ដែលមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ស្ទឹងជីនិត ស្ទឹងតាំងក្រសាំង ស្រះទឹក និងអណ្តូងទឹកជាដើម ។

រូបភាព ៦៖ ដីស្រែវស្សា



ស្រែវស្សាក្រៅគម្របព្រៃឈើឆ្នាំ២០០២



ស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ២០០២

## ខ.២. ដីចម្ការ

នៅក្នុងឃុំក្រយា ដីម្ការមានផ្ទៃដីសរុបទំហំ ៧៧ ៨៤៤,៧២ ហិកតា ដែលមានមួយភាគធំជាដីចម្ការស្ថិតក្នុងគម្របព្រៃឈើឆ្នាំ២០០២ ស្ថិតនៅពាសពេញផ្ទៃដីឃុំ ដែលមានភាគច្រើននៅភាគកណ្តាល និងភាគខាងលិចនៃឃុំនិងមានតិចតួចស្ថិតនៅភាគខាងកើតនៃឃុំ ដែលមានផ្ទៃដីទំហំ ៦៩១០៦,១៩ហិកតា និងដីចម្ការក្រៅតំបន់គម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ៨ ៧៣៨,៥៣ហិកតា ស្ថិតនៅភាគខាងជើងនៃឃុំជាប់ព្រំប្រទល់ជាមួយនឹងឃុំទំរីង ស្រុកសណ្តាន់។ បើផ្អែកទៅតាមផ្សាក្រមពំនុះកាត់ទទឹងឃុំក្រយានៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-

បរិស្ថាន ដីស្រែវស្សាទាំងអស់ ជាតំបន់ទំនាបមធ្យម មានប្រភេទដីបាកាន ក្រុមដីប្រទះឡាង និងក្រុមដីគោកត្រប់ ដីចម្ការទាំងនេះ ជាជាដីកម្មសិទ្ធិឯកជន ដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ និងដីសាធារណៈរបស់រដ្ឋ ហើយត្រូវបានកំពុងដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធបានចំនួន ២០ ភាគរយ ហើយ ។ ដីចម្ការទាំងអស់នេះ ពឹងផ្អែកការស្រោចស្រពពីទឹកភ្លៀង ស្ទឹងជីនិត ស្ទឹងតាំងក្រសាំង បឹង និងស្រះទឹកហើយត្រូវបានបែងចែកជាពីរតំបន់ផ្សេងៗគ្នាដូចជាៈ

**-ដីចម្ការក្រៅតំបន់គម្របព្រៃឈើឆ្នាំ២០០២**

ដីចម្ការក្រៅតំបន់គម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ៨ ៧៣៨,៥៣ ហិកតា ស្ថិតនៅភាគខាងជើងនៃឃុំជាប់ព្រំប្រទល់ជាមួយឃុំទំរីង ស្រុកសណ្ដាន់ ។ ដីចម្ការនេះ គឺជាដីកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋ ដែលអាចគ្រប់គ្រង និងប្រើប្រាស់ដោយប្រជាពលរដ្ឋ ដែលមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ស្ទឹងជីនិត ស្ទឹងតាំងក្រសាំង ស្រះទឹក និងបឹងជាដើម ។

**-ដីចម្ការក្នុងតំបន់គម្របព្រៃឈើឆ្នាំ២០០២**

ដីចម្ការក្នុងតំបន់គម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ៦៩១០៦,១៩ហិកតា ស្ថិតនៅពាសពេញផ្ទៃដីឃុំ ដែលភាគច្រើនស្ថិតនៅភាគកណ្ដាល និងភាគខាងលិចនៃឃុំ ព្រមទាំងមានចំនួនតិចតួចនៅភាគខាងកើតនៃឃុំ គឺជាដីសាធារណៈរបស់រដ្ឋ ដែលបច្ចុប្បន្ននេះ ត្រូវបានប្រជាពលរដ្ឋប្រើប្រាស់ជាដីចម្ការ ដែលមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ស្ទឹងជីនិត ស្ទឹងតាំងក្រសាំង ស្រះទឹក និងបឹងជាដើម។

រូបភាព 7៖ ដីចម្ការ

| | |
|---|---|
|  |  |
| ចម្ការស្វាយចន្ទីក្នុងគម្របព្រៃឈើឆ្នាំ២០០២ | ចម្ការកៅស៊ូក្នុងគម្របព្រៃឈើឆ្នាំ២០០២ |

គ. ដីព្រៃ/គម្របព្រៃ

**-ព្រៃល្បោះ**

នៅក្នុងឃុំក្រយា មានដីព្រៃល្បោះ ទំហំផ្ទៃដីសរុបចំនួន ៥ ៤៤១,៤៤ ហិកតា ស្ថិតនៅភាគកណ្ដាលតាមបណ្ដោយខាងលិចផ្លូវជាតិលេខ២៦៤ ជាដីកម្មសិទ្ធិឯកជនរបស់រដ្ឋដែលគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ ។ ព្រៃនេះជាដីសហគមន៍ព្រៃឈើ ដែលបានផ្ដល់នូវអនុផលព្រៃឈើជាច្រើនប្រភេទ ទៅដល់ប្រជាពលរដ្ឋរស់នៅក្នុងឃុំសម្រាប់ប្រើប្រាស់ និងបង្កើនប្រាក់ចំណូលនៅក្នុងគ្រួសារ ព្រមទាំងជាកន្លែងជម្រកសត្វព្រៃគ្រប់ប្រភេទ និងធ្វើឱ្យដីមានជីជាតិល្អ កាត់បន្ថយការហូរច្រោះដី រក្សាបាននៅលំនឹងសីតុណ្ហភាព ទាក់ទាញទឹកភ្លៀង និងជារបាំងខ្យល់

ព្យុះជាដើម។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំក្រយានៃរបាយការណ៍វិភាគប្រព័ន្ធកៀ្សត្រ-បរិស្ថាន ព្រៃល្បោះនេះ ជាតំបន់ទំនាបមធ្យម មានប្រភេទដីបាកាន ក្រុមដីប្រទះឡាង និងក្រុមដីគោកគ្រប់ ដែលមានដុះប្រភេទឈើចម្រុះ ដូចជា ខ្លុង ត្បែងកកោះ ចំបក់ និងធ្លក់ជាដើម។ល។

រូបភាព ៨៖ ព្រៃល្បោះ



**-ព្រៃស្រោង៖**

នៅក្នុងឃុំក្រយាមានដីព្រៃស្រោង ទំហំផ្ទៃដីសរុបចំនួន ១៦១២,១៣ហិកតា ដែលស្ថិតនៅភាគខាងជើងនៃឃុំជាប់ព្រំប្រទល់ជានឹងមួយឃុំទំរីង ស្រុកសណ្តាន់ គឺជាដីកម្មសិទ្ធិឯកជនរបស់រដ្ឋ ដែលកាន់កាប់ និងគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ ។ ព្រៃនេះបានផ្តល់នូវអនុផលព្រៃឈើជាច្រើនប្រភេទដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំ សម្រាប់ប្រើប្រាស់ និងបង្កើនប្រាក់ចំណូលនៅក្នុងគ្រួសារ ព្រមទាំងជាកន្លែងជម្រកសត្វព្រៃគ្រប់ប្រភេទ និងធ្វើឱ្យដីមានជីជាតិល្អ និងកាត់បន្ថយការហូរច្រោះដី និងរក្សាបាននៅលំនឹងសីតុណ្ហភាព ទាក់ទាញទឹកភ្លៀង និងជារបាំងខ្យល់ព្យុះជាដើម ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងនៃរបាយការណ៍វិភាគប្រព័ន្ធកៀ្សត្រ-បរិស្ថាន ដីព្រៃស្រោង ជាតំបន់ទំនាបមធ្យម មានប្រភេទដីបាកាន ក្រុមដីប្រទះឡាង និងក្រុមដីគោកគ្រប់ ជាប្រភេទព្រៃបៃតងដែលមានដើមឈើធំតូចដុះលូតលាស់និងលាយឡំគ្នាមានដូចជា៖ចំបក់ ក្រាយ កកោះ ធ្នង់ ក្រញូង បេង នាងនួនជាដើម ។

រូបភាព ៩៖ ព្រៃស្រោង



## ឃ. ផ្ទៃទឹក និងខ្សែទឹក

**-ស្ទឹងមានទឹកតាមរដូវ**

ឃុំក្រយាមានស្ទឹងចំនួន ០២ខ្សែ គឺស្ទឹងជីនិត និងស្ទឹងតាំងក្រសាំង ដែលមានផ្ទៃដីទំហំ ៤០៤,៣៩ហិកតា ដែលក្នុងនោះស្ទឹងជីនិតហូរកាត់ពីជើងមកត្បូងឆៀងខាងលិចនៃឃុំស្របទិសគ្នាជាមួយនឹងផ្លូវជាតិលេខ២៦៤ គឺជាប្រភពទឹកសំខាន់ទី១ របស់ឃុំ ចំណែកស្ទឹងតាំងក្រសាំងហូរកាត់ឃុំពីលិចទៅកើតនៅភាគខាងត្បូងនៃឃុំ ដែលជាទឹកសំខាន់ទី២។ ស្ទឹងទាំងពីរនេះ គឺជាប្រភពទឹកដ៏សំខាន់សម្រាប់ការស្រោចស្រព និងការប្រើប្រាស់ផ្សេងៗ របស់ជាពលរដ្ឋនៅក្នុងឃុំដែលអាចប្រើប្រាស់បានសម្រាប់តែរដូវវស្សានៅពេលមានគ្រោះរាំងស្ងួត ចំណែកនៅរដូវប្រាំងពុំមានទឹកគ្រប់គ្រាន់នោះទេ ។ ទន្ទឹមនេះស្ទឹងទាំងពីរខាងលើក៏ជាប្រភពជលផលសម្រាប់ការនេសាទជាលក្ខណៈគ្រួសារក្នុងឃុំផងដែរ ។

រូបភាព 10៖ ស្ទឹង

| | |
|---|---|
|  |  |
| ស្ទឹងជីនិត | ស្ទឹងតាំងក្រសាំង |

**-ស្រះ**

នៅក្នុងឃុំក្រយា មានស្រះទឹកជាច្រើនកន្លែង ដែលមានផ្ទៃដីសរុបទំហំ ៥៨,០៣ហិកតា ក្នុងនោះស្រះទឹកក្រៅតំបន់គម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ២៨,៥៥ ហិកតា ស្ថិតនៅវាលស្រែវស្សា ក្បែរផ្លូវជាតិលេខ ២៦៤ និងស្រះទឹកក្នុងតំបន់គម្របព្រៃឈើឆ្នាំ ២០០២ មានផ្ទៃដីទំហំ ២៩,៤៨ ហិកតា ភាគច្រើនស្ថិតនៅភាគខាងជើងនៃឃុំ និងមួយចំនួនទៀត ស្ថិតនៅភាគកណ្ដាលនៃឃុំ ។ ដីស្រះទឹកទាំងនេះ ជាដីកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋផង និងជារបស់រដ្ឋផង ដែលត្រូវបានប្រើប្រាស់សម្រាប់ស្រោចស្រព ប្រើប្រាស់ផ្សេងៗ និងជាប្រភពធនធានជលផលផងដែរ ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំក្រយា នៃរបាយការណ៍វិភាគប្រព័ន្ធភូគោលអេកូឡូស៊ី-បរិស្ថាន ស្រះទឹកទាំងនេះ ជាតំបន់ទំនាបមធ្យម មានប្រភេទដីបាកាន ក្រុមដីប្រទះឡាង និងក្រុមដីគោកត្រប់ ។

រូបភាព 11៖ ស្រះទឹក

|  |  |
|---|---|
| ស្រះទឹកក្នុងគម្របព្រៃឈើឆ្នាំ២០០២ | ស្រះទឹកក្រៅគម្របព្រៃឈើឆ្នាំ២០០២ |

**-បឹង**

ឃុំក្រយា មានបឹងជាច្រើន ដែលមានផ្ទៃដីសរុបទំហំ១៩,២១ហិកតា បឹងទាំងអស់នេះជាប្រភពទឹកសំខាន់ក្នុងឃុំសម្រាប់ ការស្រោចស្រពពេលជួបប្រទះគ្រោះរាំងស្ងួត និងការប្រើប្រាស់ផ្សេងៗទៀតរបស់ប្រជាពលរដ្ឋក្នុងឃុំ ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំក្រយានៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីបឹងទាំងនេះជាតំបន់ទំនាបមធ្យមមានប្រភេទដីបាកាន ក្រុមដីប្រទះឡាង ក្រុមដីគោកត្រប់ និងជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋមានសិទ្ធិត្រឹមតែអាស្រ័យផលតែប៉ុណ្ណោះ ។

រូបភាព 12៖ បឹង



ពាក់ព័ន្ធបញ្ហាផ្សេងៗក្នុងការប្រើប្រាស់ដីនៅក្នុងឃុំក្រយា តាមរយៈការសម្ភាសន៍លោកមេឃុំបានឱ្យដឹងថាមានប្រជាពលរដ្ឋក្នុងឃុំចំនួន ៣៣២គ្រួសារ មិនមានដីសម្រាប់សាងសង់លំនៅឋាន និង ៧៦០គ្រួសារ មិនមានដីធ្វើរបរកសិកម្មឡើយ ។ ក្នុងចំណោមប្រជាពលរដ្ឋទាំងនេះ មានមួយចំនួនរស់នៅលើដីចិញ្ចើមផ្លូវ រស់នៅលើដីកម្ម

សិទ្ធិរបស់គេផ្សេង ព្រមទាំងមួយចំនួនទៀតរស់នៅជាមួយឳពុកម្តាយ ។ ចំណែកបញ្ហាទំនាស់ក្នុងការការប្រើប្រាស់ដីនៅក្នុងឃុំក្រយាវិញ ពុំមានចេញជារូបភាពធំដុំគួរឱ្យកត់សម្គាល់ឡើយ ទោះជាដីនៅក្នុងឃុំទាំងមូលត្រូវបានចុះបញ្ជីកាន់កាប់ដីរួចរាល់ ២០ភាគរយក៏ដោយ ។

### ១.៣.២.ផលិតកម្ម កសិកម្ម

#### ក. ផលិតកម្មដំណាំស្បៀង

ផលិតកម្មដំណាំស្បៀងនៅក្នុងឃុំក្រយា បានផ្តោតសំខាន់ទៅលើផលិតកម្មដំណាំស្រូវ ហើយដំណាំនេះបានដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ឃុំដោយសារផលិតផលស្រូវ ក្រៅពីប្រជាពលរដ្ឋបានទុកផ្គត់ផ្គង់សម្រាប់ការហូបចុក និងមាននៅសល់បានទុកលក់សម្រាប់បំពេញតម្រូវការចាយវាយចាំបាច់ក្នុងជីវភាពរស់នៅផងដែរ។ ដំណាំស្រូវត្រូវបានផលិតនៅលើផ្ទៃដីស្រែទំហំ ២ ៤៦៨ ហិកតា ដែលជាប្រភេទក្រុមដីប្រទះឡាង ក្រុមដីព្រៃខ្មែរ ក្រុមដីបាកាននិងក្រុមដីគោកត្រប់ ដែលបច្ចុប្បន្នធ្វើស្រែបានតែម្តងគត់ក្នុងរដូវវស្សា ហើយនិយមប្រើពូជស្រូវផ្ការំដួល ពូជស្រូវឆ្អឹងមាន់ ពូជស្រូវក្រឹម ពូជស្រូវខា៤ ពូជស្រូវលាក់សន្លឹក និងពូជស្រូវនាងគង់ ។ ក្នុងការស្រោចស្រពសម្រាប់ដំណាំស្រូវនៅក្នុងឃុំក្រយា ត្រូវបានប្រើប្រាស់ទឹកពីប្រភពទឹកភ្លៀង ស្ទឹងតាំងក្រសាំង ស្ទឹងជីនិត អូរត្រពាំងធម្មជាតិ បឹងធម្មជាតិមួយចំនួន ដោយមានប្រើប្រាស់ប្រព័ន្ធប្រឡាយមួយចំនួន ដែលបច្ចុប្បន្ននៅមានការខ្វះខាតនៅឡើយ។ជាទូទៅនៅក្នុងឃុំក្រយា ប្រជាពលរដ្ឋបានទទួលផលស្រូវវស្សាជាមធ្យម២តោន/ហ.ត ហើយបានពិនិត្យឃើញថាក្នុងឆ្នាំ២០១៧នេះ ក្នុងឃុំទទួលបាន ផលស្រូវសរុបចំនួន ១ ៨៤០តោន ដែលក្នុងនោះផលដោយក្នុងនោះទុកហូបចុក៣០ភាគរយ ទុកពូជ១០ភាគរយ និងសល់ពីនេះបានលក់ចេញចំនួន ១ ១០៤តោនក្នុងតម្លៃជាមធ្យម៩៥២រៀល/គ.ក្រ ដែលទទួលបានចំណូលសរុបប្រមាណ១ ០៥១ ០០៨ ០០០រៀល ។

តារាង 23៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
| --- | --- |
| - ភាពរាំងស្ងួត<br>- សត្វល្អិតបំផ្លាញ និងជម្ងឺលើដំណាំស្រូវ<br>- ប្រើប្រាស់ពូជស្រូវតាមទម្លាប់<br>- ខ្វះបច្ចេកទេសប្រើប្រាស់ជីគីមី និងថ្នាំកសិកម្ម<br>- ខ្វះបច្ចេកទេសដាំ និងថែទាំដំណាំស្រូវ<br>- ប្រព័ន្ធប្រឡាយមានស្រាប់រងការខូចខាត (រាក់)<br>- ខ្វះខាតប្រព័ន្ធប្រឡាយនាំទឹកស្រចស្រព<br>- ខ្វះកម្លាំងពលកម្ម(ចំណាកស្រុកច្រើន) | - ដីស្រែមាន៣%នៃផ្ទៃដីសរុប<br>- ស្ថានភាពដីស្រែជាវាលទំនាប អាចមានលទ្ធភាពនាំទឹកពីប្រភពទឹកស្ទឹងស្ទោង អាង៣០កញ្ញា បឹងមកផ្គត់ផ្គង់ការស្រោចស្រព ដើម្បីធ្វើស្រែបង្កើនរដូវ២-៣ដងក្នុងមួយឆ្នាំបាន<br>- មានប្រព័ន្ធប្រឡាយស្រាប់<br>- មានកម្លាំងពលកម្មច្រើន<br>- មានគោលការណ៍ជាយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាលក្នុង ការពង្រឹងតួនាទីលើវិស័យកសិកម្ម<br>- មានគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ របស់រាជរដ្ឋាភិបាល។ |

### ខ. ផលិតកម្មដំណាំរួមផ្សំ

ផលិតកម្មដំណាំរួមផ្សំនៅក្នុងឃុំក្រយា បច្ចុប្បន្នមានដូចជា ៖ ពោត ស្ពៃ ត្រកួន ត្រសក់ សណ្តែក ននោងល្ពៅ ដែលភាគច្រើន ប្រជាពលរដ្ឋធ្វើការដាំដុះលក្ខណៈគ្រួសារនៅជុំវិញដីលំនៅឋាន ជុំវិញស្ទឹង និងកន្លែងដែលមានប្រភពទឹក មានទំហំតូចៗ ដែលត្រូវក្រុមការងារបញ្ចូលផ្ទៃដីទាំងនោះទៅក្នុងដីលំនៅឋាន និងមួយចំនួនទៀតបញ្ចូលទៅក្នុងដីស្ទឹង ។ ដំណាំរួមផ្សំទាំងនេះ ត្រូវទទួលបានការស្រោចស្រពពីស្ទឹងតាំងក្រសាំង ស្ទឹងជីនិត អូរត្រពាំងធម្មជាតិ បឹងធម្មជាតិ ហើយផលទទួលបានសម្រាប់ផ្គត់ផ្គង់ការហូបចុកនិងលក់ដូរបន្តិចបន្តួច ដើម្បីបានកម្រៃខ្លះក្នុងការជួយបំពេញញការខ្វះខាតក្នុងជីវភាពគ្រួសារតែប៉ុណ្ណោះ ។

តារាង 24៖ តារាងអធិប្បាយពីឧបសគ្គ និងឧកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - ការយល់ដឹងពីបច្ចេកទេសដាំដំណាំរបស់ប្រជាពលរដ្ឋនៅមានកម្រិត។<br>- សត្វល្អិតបំផ្លាញ<br>- ដំណាំកើតមានជម្ងឺ<br>- ខ្វះខាតទឹកស្រោចស្រពនៅរដូវប្រាំង | - មានដីល្បាប់តាមមាត់ស្ទឹង<br>- មានដីនៅជុំវិញលំនៅឋាន<br>- មានប្រភពទឹកស្ទឹង ស្រះ និងទឹកក្រោមដី សម្រាប់ការស្រោចស្រព<br>- ប្រជាពលរដ្ឋមានការយល់ដឹងពីសារៈប្រយោជន៍នៃដំណាំរួមផ្សំដែលអាចជួយផ្គត់ផ្គង់ដល់ការហូបចុក កាត់បន្ថយបានលើការចំណាយ ហើយបានលក់ខ្លះដោះស្រាយដល់ជីវភាពរស់នៅប្រចាំថ្ងៃ។ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ក្រយា ខែឧសភា ឆ្នាំ២០១៨*

### គ. ផលិតកម្មឧស្សាហកម្ម

ផលិតកម្មដំណាំឧស្សាហកម្មនាបច្ចុប្បន្ន នៅក្នុងឃុំក្រយា គឺបានដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ឃុំ ហើយត្រូវបានផលិតនៅលើផ្ទៃដីចំនួន ៧៧ ៨៤៤,៧២ហិកតា ស្មើនឹង ៨៨ភាគរយ នៃផ្ទៃដីឃុំទាំងមូល ដែលជាប្រភេទក្រុមដីប្រទះឡាង ក្រុមដីគោកត្រប់ និងក្រុមដីបាកាន ដែលស្ថិតនៅពាសពេញទូទាំងឃុំនិងសម្បូរច្រើនជាងគេនៅភាគលិចនិងខាងជើងនៃឃុំ និងមានតិចតួចនៅភាគខាងកើតនិងខាងត្បូងនៃឃុំ ។ ដំណាំឧស្សាហកម្មទាំងនេះ ភាគច្រើនជាដំណាំស្វាយចន្ទី និងកៅស៊ូ មិនមានការស្រោចស្រពបន្ថែមក្រៅពីទឹកភ្លៀងនោះទេ ហើយទទួលបានទិន្នផលជាមធ្យម ១,៥តោន/ហ.ត ដែលបានឱ្យដឹងថានៅក្នុងឆ្នាំ២០១៧ ទទួលបានផលិតផលសរុបប្រមាណ៣៨៣តោន និងកៅស៊ូទទួលបានទិន្នផលជាមធ្យម១តោន/ហ.ត ដែលបានឱ្យដឹងថានៅក្នុងឆ្នាំ២០១៧ ទទួលបានផលិតផលសរុបប្រមាណ ២៩ ៩០៩តោន ។

តារាង 25៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| -ជួបគ្រោះរាំងស្ងួត | -មានផ្ទៃដីធំទូលាយរហូតដល់ ៨៨% នៃផ្ទៃដីសរុប |
| -ខ្វះខាតទឹកស្រោចស្រព | -អាចពង្រីកផ្ទៃដីដាំដុះលើដំណាំនេះបាន |
| -ជួបប្រទះទឹកជំនន់(ទឹកភ្លៀង) | -មានប្រភពទឹកភ្លៀង ទឹកស្ទឹង បឹង សម្រាប់ការស្រោចស្រព |

| | |
|---|---|
| -សត្វល្អិតបំផ្លាញនិងជម្ងឺលើដំណាំ<br>-ដីខ្វះជីវជាតិ<br>-បច្ចេកទេសដាំ និងថែទាំដំណាំនៅមានកម្រិត<br>-តម្លៃនៅទីផ្សារមានការប្រែប្រួលមិនទៀងទាត់ | -មានបច្ចេកទេសដាំដុះ និងថែទាំដំណាំគ្រប់គ្រាន់ពីអ្នកជំនាញបច្ចេកទេសកសិកម្ម |

### ១.៣.៣.ធនធានធម្មជាតិ

#### ក. ធនធានព្រៃឈើ

បច្ចុប្បន្ននៅក្នុងឃុំក្រយា មានធនធានព្រៃឈើគ្របដណ្តប់នៅលើផ្ទៃដីប្រមាណជា ៧ ០៥៣,៥៧ហិកតា ស្មើនឹង ០៨ភាគរយ នៃផ្ទៃដីឃុំទាំងមូល ដែលក្នុងនោះមានប្រភេទព្រៃឈ្មោះទំហំ ៥ ៤៤១,៤៤ហិកតា ស្ថិតនៅខាងលិចតាមបណ្តោយផ្លូវជាតិលេខ ២៦៤ និងព្រៃពាក់កណ្តាលស្រោងមានទំហំ ១ ៦១២,១៣ហិកតា ស្ថិតនៅភាគខាងជើងនៃឃុំជាប់ជាមួយឃុំទំរីង ស្រុកសណ្តាន់។ ព្រៃទាំងនេះត្រូវបានគ្រប់គ្រងនិងថែទាំដោយសហគមន៍មូលដ្ឋាននិងអាជ្ញាធរដែនដីភូមិឃុំ(ជាដីកម្មសិទ្ធិរបស់រដ្ឋ)មានមុខងារការពារឱ្យមានស្ថេរភាពលើបរិស្ថានធម្មជាតិ ដូចជាចរន្តទឹកភ្លៀងខ្យល់អាកាស សីតុណ្ហភាពជាដើម។ល។ ព្រមទាំងបង្កើតនូវលក្ខខណ្ឌជីវៈចម្រុះប្រកបដោយនិរន្តរភាព និងផលិតកម្មកសិកម្ម ។ ទន្ទឹមនេះ ព្រៃពាក់កណ្តាលស្រោងនេះ មានមុខងារផ្តល់នូវផលិតផលដែលប្រជាជនប្រមូលផលបានពីក្នុងព្រៃមានដូចជា ឈើសំណង់ ឃ្មុំ ផ្លែឈើព្រៃ ផ្សិត វល្លិ និងរុក្ខជាតិជាច្រើនប្រភេទ ព្រមទាំងមានមុខងារសង្គមដែលបង្កើតបាននូវបរិយាកាសអំណោយផលដល់សុខភាព និងជាជម្រកសត្វព្រៃគ្រប់ប្រភេទ ។

តារាង 26៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - មានការកាប់បំផ្លាញឈើសម្រាប់ធ្វើឧសដុត និងប្រើប្រាស់ផ្សេងៗ<br>- មានការកាប់បំផ្លាញឈើដើម្បីយកដីកាន់កាប់<br>- ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីផលប្រយោជន៍នៃដើមឈើនៅមានកម្រិត<br>- ការអនុវត្តច្បាប់ព្រៃឈើនូវទាន់បានពេញលេញ<br>- ការផ្សព្វផ្សាយច្បាប់ពុំទាន់បានទូលំទូលាយនៅឡើយ | - មានច្បាប់និងអនុក្រឹត្យស្តីពីព្រៃឈើ<br>- មានសហគមន៍ព្រៃឈើការពារ<br>- មានដីព្រៃឈើធម្មជាតិ<br>- មានរដ្ឋបាលព្រៃឈើជាសមត្ថកិច្ចគ្រប់គ្រងព្រៃឈើ |

#### ខ. ធនធានជលផល

បច្ចុប្បន្ននៅក្នុងឃុំក្រយា មានស្ទឹងចំនួន០២ គឺស្ទឹងតាំងក្រសាំង និងស្ទឹងជីនិត មានទំហំផ្ទៃដីសរុបទំហំ ៤០៤,៣៤ហិកតា បឹងផ្ទៃដីទំហំ ១៩,២១ហិកតា និងស្រះទឹកមាន ផ្ទៃដីទំហំ ៥៨,០៣ហិកតា ។ ស្ទឹង បឹង និងស្រះទាំងអស់នេះ មានធនធានជលផលជាច្រើនប្រភេទដូចជា ត្រីរ៉ស់ ត្រីឆ្តោរ ត្រីអណ្តែង ត្រីក្រាញ់ ត្រីទីឡាបស្យា អន្ទង់ ក្តាម ខ្យង កង្កែប អណ្តើក និងពស់ជាដើម។ល។ ហើយត្រូវបានធ្វើការនេសាទដោយប្រជាជនក្នុងឃុំជាលក្ខណៈគ្រួសារតាមរយៈការប្រើប្រាស់ ឧបករណ៍ សំណាញ់ មង ទ្រូ អួន សន្ទូច ជាលក្ខណៈប្រពៃណី ដែលផលនេសាទទាំងនេះសម្រាប់តែការហូបចុក និងលក់ដូរតិចតួចប៉ុណ្ណោះ ។

តារាង 27៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - មានការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិតមិនសមស្របលើដំណាំកសិកម្ម នាំឱ្យមានការថយចុះបរិមាណធនធានជលផល<br>- ការប្រើឧបករណ៍នេសាទខុសច្បាប់។ | - មានស្ទឹង បឹង ស្រះ និងស្រែ ដែលអំណោយផលដល់ធនធានជលផល<br>- មានច្បាប់ជលផល<br>- ប្រើប្រាស់ឧបករណ៍បែបប្រពៃណី ។ |

### ១.៣.៤.ធនធានរ៉ែ

នៅក្នុងក្រយា មានធនធានខ្សាច់ ដែលស្ថិតនៅតាមមាត់ស្ទឹងតាំងក្រសាំង និងស្ទឹងជីនិត ។ ទីតាំងទាំងនេះមានការចេញលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មដោយពីមន្ទីរ ឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបានដឹកចេញ និងយកទៅធ្វើអាជីវកម្មនិងសំណង់ផ្សេងៗ ។ ឃុំនិងប្រជាពលរដ្ឋពុំបានទទួលផលប្រយោជន៍អ្វីពីធនធានរ៉ែនេះនោះទេ។ ការធ្វើអាជីវកម្មខ្សាច់នេះមានផលប៉ះពាល់ ដូចជា ៖ បាក់ច្រាំងស្ទឹង ដីហុយនៅពេលដឹកជញ្ជូននិងធ្វើឱ្យប៉ះពាល់ដល់សុខភាព និងសោភ័ណ្ឌភាពក្នុងឃុំ និងធ្វើឱ្យខូចផ្លូវជាដើម ។ ក្រៅពីរ៉ែខ្សាច់ និងថ្មចម្លាក់ ឃុំក្រយា មិនមានធនធានរ៉ែផ្សេងៗទៀតឡើយ ។

## ១.៤.ទីផ្សារ និងខ្សែសង្វាក់ផលិតផល

### ១.៤.១.ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ

បច្ចុប្បន្ននេះនៅក្នុងឃុំក្រយាមានតែផលិតផលស្រូវ ស្វាយចន្ទីនិងកៅស៊ូ ដែលអាចនាំចេញទៅរកទីផ្សារ ហើយផលិតផលស្រូវ ដែលនៅសល់ពីការហូបចុកអាចនាំទៅរកទីផ្សារមានប្រភេទ ស្រូវរាំងជ័យនិងស្រូវផ្ការំដួល ដោយឡែកផលិតផលដំណាំស្វាយចន្ទី និងកៅស៊ូនាំទៅរកទីផ្សារទាំងអស់។ បើយោងតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំក្រយាឆ្នាំ២០១៧ បានឱ្យដឹងថាប្រភេទស្រូវផ្ការំដួលមានទីផ្សារនៅក្នុងប្រទេស និងទីផ្សារនៅប្រទេសប្រទេសវៀតណាមដូចគ្នា ប្រជាពលរដ្ឋតែងតែលក់ស្រូវស្ងួត ២០ ភាគរយ តាមរយៈឈ្មួញមកទទួលទិញដល់ក្នុងឃុំដែរមានតម្លៃ ៩៥០-១០៥០រៀលក្នុងមួយគីឡូក្រាម ព្រមទាំងស្រូវរាំជ័យមានទីផ្សារនៅក្នុងប្រទេស និងទីផ្សារនៅប្រទេសប្រទេសវៀតណាមដូចគ្នា ប្រជាពលរដ្ឋតែងលក់ស្រូវស្ងួត ១៥ ភាគរយ តាមរយៈឈ្មួញមកទទួលទិញដល់ក្នុងឃុំដែរមានតម្លៃ៩៥០-៩៨០រៀលក្នុងមួយគីឡូក្រាម។ ចំណែកផលិតផលស្វាយចន្ទីតាមការសាកសួរប្រជាពលរដ្ឋនៅក្នុងឃុំ បានឱ្យដឹងថាមានឈ្មួញមកទិញដល់ឃុំ និងបន្តដឹកទៅលក់នៅប្រទេសវៀតណាម មានតម្លៃចាប់ពី៣ ៧០០រៀល ទៅ ៦ ៥០០រៀល ។

តារាង 28៖ ស្ថិតិផលិតផលស្រូវ និងតម្លៃ

| ល.រ | ប្រភេទផលិតផលស្រូវ | ឯកតា | តម្លៃជារៀល | ទីផ្សារ | |
|---|---|---|---|---|---|
| | | | | ក្នុងស្រុក | ក្រៅប្រទេស |
| ២ | ស្រូវផ្ការំដួល | ១ គ.ក្រ | ៩៥០-១០៥០ | | វៀតណាម |
| ៣ | ស្រូវរាំងជ័យ | ១ គ.ក្រ | ៩៥០-៩៨០ | | វៀតណាម |
| ៤ | ស្វាយចន្ទី | ១គ.ក្រ | ៣ ៧០០-៦ ៥០០ | | វៀតណាម |

### ១.៤.២.ខ្សែសង្វាក់ និងចរាចរផលិតផល

បើយោងតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំក្រយានៅឆ្នាំ ២០១៧ បានឱ្យដឹងថា បច្ចុប្បន្ន នៅក្នុងឃុំក្រយា ការផលិតដំណាំស្រូវរហូតដល់បានផលលក់ចេញគឺ ត្រូវដំណើរការតាមខ្សែសង្វាក់ជាបន្តបន្ទាប់ ដូចជា ការផលិតស្រូវផ្ការំដួល ដោយចាប់ផ្តើមពីការត្រៀមពូជស្រូវ ដែលភាគច្រើនបានរក្សាទុកដោយខ្លួនឯង ៧០ភាគរយ និង មានការទិញចូល ៣០ភាគរយ ហើយមានការរៀបចំដី រួមទាំងការថែទាំមានការដាក់ជីនិងបាញ់ថ្នាំសម្លាប់សត្វល្អិតរហូត ដល់ច្រូតកាត់ដែលប្រើដោយគ្រឿងយន្តរហូតដល់ ៩០ភាគរយ និងច្រូតកាត់ដោយដៃតែ ១០ភាគរយប៉ុណ្ណោះ ។ ផល ស្រូវដែលទទួលបានត្រូវហាលសម្ងួតទុកពូជ ៣០ ភាគរយ និងទុកផ្គត់ផ្គង់ការហូបចុកប្រមាណ ៥០ ភាគរយ ចំណែក ផលស្រូវដែលសល់ប្រមាណ ២០ភាគរយ យកទៅលក់ឱ្យឈ្មួញនៅតាមដងផ្លូវក្នុងឃុំបានតម្លៃ៩៥០-៩៨០រៀលក្នុង មួយគីឡូក្រាម ហើយឈ្មួញបន្តលក់ឱ្យរោងម៉ាស៊ីនកិនស្រូវយកទៅកិនកែច្នៃជាអង្ករនាំទៅទីផ្សារក្នុងប្រទេសនិងទីផ្សារ ក្រៅប្រទេស ។ ចំណែកដំណាំស្រូវរាំងជ័យ ដោយចាប់ផ្តើមពីការត្រៀមពូជស្រូវដែលភាគច្រើនបានរក្សាទុកដោយខ្លួន ឯង ៧០ភាគរយ និងមានការទិញចូល ៣០ភាគរយ ដោយមានការរៀបចំដី រួមទាំងការថែទាំ មានការដាក់ជី បញ្ចូលទឹក និងបាញ់ថ្នាំសម្លាប់សត្វល្អិត រហូតដល់ច្រូតកាត់ដែលប្រើដោយគ្រឿងយន្តរហូតដល់ ៩០ភាគរយ និងច្រូតកាត់ដោយ ដៃតែ ១០ភាគរយប៉ុណ្ណោះ ។ ផលស្រូវដែលទទួលបានត្រូវហាលសម្ងួតទុកពូជ ៣០ភាគរយ និងទុកផ្គត់ផ្គង់ការហូប ចុកប្រមាណ ៥៥ភាគរយ ចំណែកផលស្រូវដែលសល់ប្រមាណ ១៥ ភាគរយ យកទៅលក់ឱ្យឈ្មួញនៅតាមដងផ្លូវក្នុង ឃុំបានតម្លៃ ៩៥០-៩៨០រៀលក្នុងមួយគីឡូក្រាម ហើយឈ្មួញបន្តលក់ទៅឱ្យរោងម៉ាស៊ីនកិនស្រូវយកទៅកិនកែច្នៃ ជាអង្ករនាំទៅទីផ្សារក្នុងប្រទេស និងទីផ្សារក្រៅប្រទេស ។ ក្រៅពីផលិតផលស្រូវ ឃុំក្រយានៅមានផលិតផលស្វាយចន្ទី ថែមទៀត ដែលនាពេលបច្ចុប្បន្នដំណាំនេះមានដើមលូតលាស់ធំៗ និងកំពុងផ្តល់ផលជាបណ្តើរៗ បើតាមការសាកសួរ ប្រជាពលរដ្ឋក្នុងឃុំ បានឱ្យដឹងថាប្រជាពលរដ្ឋនៅក្នុងឃុំកំពុងថែទាំ ជួលដាក់ជី បាញ់ថ្នាំសម្លាប់សត្វល្អិតបំផ្លាញដំណាំ ធ្វើដី និងបេះផ្លែជាដើម ។ ការប្រមូលផលស្វាយចន្ទីបាន ២ដងក្នុងមួយឆ្នាំ គឺចុងរដូវ និងដើមរដូវ ហើយផលិតផលត្រូវ បាននាំយកទៅលក់ឱ្យឈ្មួញកណ្តាលដែលមកទិញដល់កន្លែង ខ្លះដល់ចម្ការ និងមានខ្លះទៀតទិញតាមផ្ទះ ក្នុងតម្លៃចាប់ ពី ៣ ៧០០រៀលទៅដល់ ៦ ៥០០រៀលក្នុង១គីឡូក្រាម ហើយឈ្មួញបន្តលក់ទៅទីផ្សារទីរួមខេត្តកំពង់ធំ និងមានឈ្មួញ ទី២បន្តលក់នៅទីផ្សារ ប្រទេសវៀតណាម ។

រូបភាព 13៖ ផលិតកម្មកសិកម្ម

| | |
|---|---|
|  |  |
| ការប្រមូលផលស្រូវ | ផលិតផលស្រូវ |

## ដ្យាក្រាម 4៖ គំនូសតាងនៃការលំហូផលិតផលកសិកម្ម នៅក្នុងភូមិ និង ការប្រើប្រាស់






### ១.៨.៣.ឧបសគ្គ និងឱកាស

តារាង 29៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ទីផ្សារនិងខ្សែសង្វាក់ផលិតផល

| ឧបសគ្គ | ឱកាស |
|---|---|
| - ឈ្មួញជាអ្នកកំណត់តម្លៃស្រូវ<br>- ឈ្មួញកណ្តាលយកជី ថ្នាំ និងប្រេងមកបណ្តាក់ដោយគិតការប្រាក់ខ្ពស់រហូតដល់២%ក្នុងមួយខែ ហើយទូទាត់នៅពេលប្រមូលផល<br>- កសិករប្រើពូជទុកខ្លួនឯងច្រើនជំនាន់<br>- ធាតុចូលកសិកម្មថ្លៃខ្ពស់<br>- តម្លៃស្រូវមិនទៀងទាត់(អាស្រ័យលើឈ្មួញ)<br>- ប្រើប្រាស់ពូជស្រូវវៀតណាម។ | - មានឈ្មួញមកទិញដល់កន្លែង<br>- មានភាពងាយស្រួលក្នុងការដឹកជញ្ជូនផលិតផលស្រូវ<br>- អាចប្រកួតប្រជែងតម្លៃជាមួយប្រទេសជិតខាង<br>- គុណភាពស្រូវស្របតាមស្តង់ដាសម្រាប់ការនាំចេញ<br>- តម្លៃអង្ករកើនឡើង និងទៀងទាត់<br>- ពូជស្រូវមានទិន្នផលខ្ពស់ និងតម្លៃខ្ពស់<br>- កែច្នៃចេញជាផលិតផលសម្រេច។ |

# ជំពូក ២៖ ការវិភាគ តម្រូវការ សក្តានុពល និងឧបសគ្គសម្រាប់អនាគត

## ២.១.តម្រូវការសម្រាប់អនាគត

### ២.១.១.ផែនការអភិវឌ្ឍន៍ឃុំ

#### ក. ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ(២០១៧-២០២២)

ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ គឺជាមធ្យោបាយយ៉ាងសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រើប្រាស់សម្រាប់សម្រាប់កំណត់អំពីបញ្ហា តម្រូវការជាអាទិភាពយ៉ាងពិតប្រាកដរបស់មូលដ្ឋាន និងយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនោះ សំដៅឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ នៅក្នុងឃុំយ៉ាងមានប្រសិទ្ធភាព តាមរយៈការរៀបចំឱ្យមានតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំមួយ មានរយៈពេលប្រាំឆ្នាំ សម្រាប់អាណត្តិក្រុមប្រឹក្សាឃុំ។ តារាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំនេះបានរំលេចនូវចក្ខុវិស័យអភិវឌ្ឍន៍ ដែលជាទស្សនៈរបស់ក្រុមប្រឹក្សាឃុំចង់បាន ការប្រែប្រួលជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្លួនឱ្យស្របតាមចក្ខុវិស័យ របស់រាជរដ្ឋាភិបាល ហើយដើម្បីសម្រេចបាននូវចក្ខុវិស័យនេះក៏បានរំលេចឱ្យឃើញពីគោលបំណងនៃការអភិវឌ្ឍន៍ ដែលជាលទ្ធផលរួមរបស់ក្រុមប្រឹក្សាចង់បាន ព្រមទាំងគោលដៅអភិវឌ្ឍន៍ ដែលជាលទ្ធផលនានារបស់ក្រុមប្រឹក្សាឃុំចង់បានទៅតាមវិស័យនីមួយៗ ។ ទន្ទឹមនេះក៏បានរំលេចឱ្យឃើញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដែលជាការកំណត់នូវវិធីសាស្ត្រ ឬសកម្មភាពត្រូវអនុវត្ត ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍នីមួយៗខាងលើ ។

ចំណែកឃុំក្រយា ក្រុមប្រឹក្សាឃុំក្នុងអាណត្តិ(២០១៨-២០២២) ក៏បានរៀបចំឱ្យមានផែនការអភិវឌ្ឍន៍ឃុំរយៈពេលប្រាំឆ្នាំរបស់ខ្លួន ក្នុងនោះបានលើកឡើង អំពីគម្រោងវិនិយោគរយៈពេលប្រាំឆ្នាំទៅក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍឃុំ ដូចមានខ្លឹមសារដែលក្រុមការងារបានដកស្រង់បញ្ចូលក្នុងតារាងខាងក្រោម៖

តារាង 30៖ ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ និងជម្រើសនៃការប្រើប្រាស់ដីធ្លីអនាគត

| កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និង យុទ្ធសាស្ត្រ | | | | | |
|---|---|---|---|---|---|
| តម្រូវការនៃការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃ ការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ | សកម្មភាពជា អាទិភាព | លេខរៀងនៅលើផែនទី |
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| ១.ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូនល្អប្រសើរ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ប្រជាពលរដ្ឋក្នុងឃុំមានផ្លូវធ្វើដំណើរស្រួលចាប់ពីឆ្នាំ ២០១៨ | -កែលម្អជួសជុលផ្លូវ និងដាក់លូបង្ហូរទឹក<br>-សាងសង់ផ្លូវថ្មីបន្ថែម | -កសាងផ្លូវកៅស៊ូ<br>-កសាងផ្លូវបេតុង<br>-កសាងផ្លូវគ្រួសក្រហម<br>-កសាងផ្លូវលំ<br>-សាងសង់ស្ពាន(ថ្ម ម៉ាឡេ ឈើ)<br>-ជួសជុលផ្លូវក្រាលគ្រួសក្រហម<br>-ជួសជុលផ្លូវលំដីស<br>-ដាក់លូកាត់ផ្លូវ | |
| ២.មានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ប្រជាពលរដ្ឋមានប្រព័ន្ធស្រោចស្រពគ្រាប់គ្រាន់ | -ស្តារនិងជួសជុលប្រព័ន្ធធារាសាស្ត្រចាស់ៗឡើងវិញ<br>-សាងសង់ប្រព័ន្ធធារាសាស្ត្រថ្មីបន្ថែមទៀត | -ជីកប្រឡាយស្រោចស្រព<br>-លើកទំនប់ទឹក<br>-សាងសង់ទ្វារទឹក<br>-សាងសង់សំណង់បង្ហៀរទឹក<br>-សាងសង់អាងស្តុកទឹក<br>-ស្តារប្រឡាយស្រោចស្រព<br>-ជួសជុលទ្វារទឹក | |

| | | | | | |
|---|---|---|---|---|---|
| | | | | -ជួសជុលស្ថានីយបូមទឹក<br>-ពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹក<br>-ផ្តល់ម៉ាស៊ីនបូមទឹក<br>-ពង្រឹងគណៈកម្មការគ្រប់គ្រងធារាសាស្ត្រ | |
| ៣.កម្រិតអប់រំមានគ្រប់កម្រិត និងសិស្សបានចូលរៀនគ្រប់គ្នានៅក្នុងឃុំ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -បង្កើនការចូលរៀនកុមារអាយុ ៣-៤ ឆ្នាំឱ្យបាន ៩០% នៅឆ្នាំ ២០១៨<br>-កុមារអាយុ ៦-១៤ ឆ្នាំបានរៀនបញ្ចប់នូវកម្រិតមូលដ្ឋាន ០៩ ឆ្នាំ<br>-ចំនួនអនក្ខរជននឹងថយនៅត្រឹម២% | -ពង្រឹងនិងពង្រីកផ្នែកមត្តេយ្យសាលាឱ្យបានគ្រប់មូលដ្ឋានភូមិ<br>-ជំរុញការយល់ដឹងដល់ឪពុកម្តាយកុមារពីតម្លៃសិក្សា<br>-ពង្រឹងកិច្ចសហការជាមួយមន្ទីរជំនាញ និងអង្គការនានាដើម្បីកាត់បន្ថយអនក្ខរកម្មរបស់ប្រជាពលរដ្ឋ | -បង្កើតថ្នាក់មត្តេយ្យ<br>-ផ្តល់គ្រូមត្តេយ្យ<br>-ផ្សព្វផ្សាយឱ្យឪពុកម្តាយនាំកូនចូលរៀន<br>-ផ្តល់សម្ភារសិក្សាដល់សិស្សក្រីក្រ<br>-ផ្តល់អាហាររូបករណ៍ដល់សិស្សក្រីក្រ<br>-អប់រំកុមារឱ្យយល់ដឹងពីតម្លៃនៃការសិក្សា<br>-បើកថ្នាក់អក្ខរកម្មឱ្យបានគ្រប់ភូមិ | |
| ៤.សុខភាពរបស់ប្រជាជនល្អប្រសើរ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ធ្វើឱ្យប្រសើរឡើងសុខភាព និងអនាម័យរបស់ប្រជាជនបានល្អ | -បង្កើននិងកែលម្អសេវាសុខភាព និងចំណេះដឹងដល់ភ្នាក់ងារសុខភាពភូមិ | -ចាក់វ៉ាក់សាំងការពារជម្ងឺ៧មុខ<br>-ផ្តល់ថ្នាំជាតិដែក<br>-សំណើសុំគ្រូពេទ្យ និងថ្នាំ<br>-ជួសជុលដីកអណ្តូងទឹកស្អាត<br>-ធ្វើទស្សនកិច្ចសិក្សាយកបទពិសោធន៍ ពីកន្លែងផ្សេងៗ<br>-បណ្តុះបណ្តាលស្ត្រីមេម៉ាយក្រីក្របង្កើតជាសមាគមន៍ក្រុមចេះជួយខ្លួនឯង<br>-សាងសង់បង្គន់អនាម័យ<br>-អប់រំ និងផ្សព្វផ្សាយអំពីជម្ងឺឆ្លង ដូចជា របេង ផ្តើម គ្រុនចាញ់ និង គ្រុណឈាមជាដើម<br>-កម្មវិធីពន្យាកំណើត | |
| ៥.ឃុំមានបរិស្ថាន និង ធនធានធម្មជាតិស្រស់បំព្រង | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ធ្វើឱ្យប្រសើរឡើងនូវធនធានធម្មជាតិ | -បង្កើនសេវាលើការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន | -បណ្តុះបណ្តាលច្បាប់ការពារព្រៃសហគមន៍<br>-បណ្តុះបណ្តាលច្បាប់រុក្ខាប្រមាញ់ និងនេសាទត្រីខុសច្បាប់<br>-ដាំកូនឈើតាមទីសាធារណៈ<br>-ស្តារត្រពាំងចាស់ៗ ឡើងវិញ<br>-ចិញ្ចឹមត្រីតាមគ្រួសារតាមគោលការណ៍ធម្មជាតិ | |
| ៦.ធ្វើឱ្យប្រជាពលរដ្ឋរស់នៅប្រកបដោយភាពសុខសាន្ត និងសុវត្ថិភាព | សាលាឃុំ | -ភូមិឃុំមានសន្តិសុខ និងសណ្តាប់ធ្នាប់ និងមានសុវត្ថិភាពល្អ | -ជម្រុញពង្រីកការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព<br>-ប្រជាពលរដ្ឋចូលរួមនិងបង្កើតក្រុម | -បង្កើតប៉ុស្តិ៍ស្ម័យការពារតាមភូមិ<br>-បង្កើតក្រុមប្រជាជនការពារតាមភូមិឃុំ<br>-ផ្សព្វផ្សាយច្បាប់ភូមិបាលនិងច្បាប់ផ្សេងៗទៀត<br>-ចុះបញ្ជីអគ្រានុកូលដ្ឋានបាន | |

| | | | | | |
|---|---|---|---|---|---|
| | | | ការពារភូមិ ដើម្បី រក្សាសន្តិសុខ សណ្តាប់ធ្នាប់ភូមិ-ឃុំ | គ្រប់ៗគ្នា<br>-ផ្សព្វផ្សាយអប់រំក្រុមក្រុមក្មេងទំនើង<br>-អប់រំពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន<br>-កាត់បន្ថយល្បែងស៊ីសងគ្រប់ប្រភេទ<br>-បំផុសឱ្យចូលរួមសហការណ៍ជាមួយសមត្ថកិច្ច | |
| ៧.លុបបំបាត់កាត់បន្ថយទំនាស់ដីធ្លី | សាលាឃុំ | -មានប័ណ្ណកម្មសិទ្ធិគ្រប់គ្រងដីធ្លីនិងយល់ច្បាស់ពីសិទ្ធិក្នុងការគ្រប់គ្រង | -ជំរុញឱ្យ ប្រជាពរដ្ឋបានយល់ដឹងពីច្បាប់ និងមានកម្មសិទ្ធិដីធ្លីដោយស្របច្បាប់<br>-បង្កើនការគ្រប់គ្រងដីធ្លីឱ្យស្របតាមគោលនយោបាយរបស់រដ្ឋ | -ផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ប្រជាពលរដ្ឋ<br>-ផ្សព្វផ្សាយពីច្បាប់ភូមិបាល និងច្បាប់ផ្សេងៗ<br>-ជំរុញឱ្យឱ្យប្រជាពលរដ្ឋធ្វើរបងនិងព្រំដីឱ្យបានច្បាស់លាស់ | |
| ៨.ទិន្នផលកសិកម្មកើនឡើង | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ធានាស្បៀងហូបគ្រប់គ្រាន់ | -បង្កើនផលិតកសិកម្ម | -លើកទំនប់<br>-ជីកប្រឡាយ<br>-លូស្ពាក់ទឹក ទ្វារទឹក<br>-ពូជស្រូវល្អ<br>-ធ្វើជីកំប៉ុស្ត<br>-បច្ចេកទេសជីគីមី<br>-ចិញ្ចឹមសត្វ ត្រី<br>-ឈើហូបផ្លែ | |
| ៩.មានទឹកស្អាតសម្រាប់គ្រួសារប្រើប្រាស់ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ការរស់នៅមានអនាម័យតាមរយៈមានទឹកស្អាតប្រើប្រាស់ | -ពង្រីក និងកែលម្អប្រភពផ្គត់ផ្គង់ទឹក | -ជីកអណ្តូងលូ ស្នប់ ស្រះសហគមន៍<br>-ជួសជុលអណ្តូង<br>-បច្ចេកទេសចម្រោះទឹក | |
| ១០ សមភាព និងសមធម៌ក្នុងការរស់នៅ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ធ្វើឱ្យប្រសើរឡើងដល់ប្រជាជនគ្រប់រូបរស់នៅប្រកបដោយសមភាព សមធម៌ គោរពគ្នាទៅវិញទៅមក | -បង្កើនការផ្សព្វផ្សាយច្បាប់ និងលើកកម្ពស់មុខរបរ | -ផ្សព្វផ្សាយច្បាប់សិទ្ធិមនុស្ស<br>-ផ្សព្វផ្សាយច្បាប់អំពើហិង្សាក្នុងគ្រួសារ<br>-ផ្សព្វផ្សាយច្បាប់ជួញដូរស្ត្រី និងកុមារ<br>-ពង្រឹងជនបង្គោលជាស្ត្រីតាមភូមិ<br>-ផ្សព្វផ្សាយច្បាប់កេងប្រវ័ញ្ចដល់កម្លាំងពលកម្មស្ត្រីនិងកុមារ<br>-បណ្តុះបណ្តាលពីតួនាទី យេនឌ័រ | |
| ១១.ទិន្នផលត្រីកើនឡើង | សាលាឃុំ | -បង្កើនធនធានជលផល | -ជំរុញការបង្កើតវារីវប្បកម្ម | -បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី<br>-ជ្រើសរើសទីតាំងល្អ<br>-ផ្តល់ឥណទាននិងពូជ<br>-ផ្សព្វផ្សាយច្បាប់ជលផល<br>-បង្កើនការចិញ្ចឹមត្រីតាមគ្រួសារ<br>-អប់រំ និងផ្សព្វផ្សាយបំរាមនេសាទនៅរដូវត្រីពង | |

| | | | | | |
|---|---|---|---|---|---|
| ១២.គ្រួសារចិញ្ចឹមសត្វកើនឡើង | សាលាឃុំ | -បង្កើនការចិញ្ចឹមសត្វបន្ថែមទៀត | -ជំរុញការផ្តល់បច្ចេកទេសជំនាញកសិកម្ម<br>-ជំរុញការផ្តល់បច្ចេកទេសចិញ្ចឹមថែទាំសុខភាពសត្វនិងជ្រើសរើសពូជ | -ចាក់វ៉ាក់សាំងការពារជម្ងឺគោក្របីឱ្យបានទៀងទាត់<br>-ផ្តល់ឥណទានគោក្របី<br>-ផ្តល់ឥណទានមានការប្រាក់ទាប | |
| ១៣.កាត់បន្ថយមរណមាតា និងទារកក្រោយសម្រាល | សាលាឃុំ | -បង្កើនការលុបបំបាត់អត្រាស្លាប់មាតា និងទារកក្រោយសម្រាល | -ពង្រឹងនិងពង្រីកការផ្តល់សេវាគាំពារសុខភាពមាតា និងទារក | -ផ្សព្វផ្សាយដល់ស្ត្រីមានផ្ទៃពោះឱ្យទៅសម្រាលកូនដោយពេទ្យឆ្មប<br>-អប់រំឱ្យស្ត្រីចេះរបៀបការពារជម្ងឺឆ្លងកាមរោគ និងជម្ងឺអេដស៍<br>-មិនរើសអើង និងគាំទ្រដល់អ្នកកើតមេរោគអេដស៍<br>-ជំរុញឱ្យស្ត្រីមានផ្ទៃពោះទៅពិនិត្យពោះនៅមណ្ឌលសុខភាព<br>-ជំរុញឪពុកម្តាយយកកុមារទៅចាក់ថ្នាំការពារជម្ងឺ០៧មុខ | |
| ១៤.ឱ្យមានថាមពលអគ្គិសនីប្រើប្រាស់គ្រប់ផ្ទះ | សាលាឃុំ | -ទូទាំងឃុំមានអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ | -ពង្រឹងកិច្ចសហការជាមួយអង្គភាពជំនាញដើម្បីជំរុញការផ្គត់ផ្គង់ថាមពលអគ្គិសនី | -រៀបចំបណ្តាញអគ្គិសនីតាមភូមិ | |

ប្រភពទិន្នន័យៈ *របាយការណ៍ក្សេត្រ-បរិស្ថាន CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំក្រយា ឆ្នាំ២០១៨*

### ខ. គម្រោងអភិវឌ្ឍន៍ផ្សេងៗទៀតដែលបានអនុម័តរួច

នៅក្នុងឃុំក្រយា បច្ចុប្បន្នមិនមានគម្រោងអភិវឌ្ឍន៍ណាមួយ ដែលត្រូវបានអនុម័តរួចដើម្បីដំណើរការជួយជំរុញក្នុងការអភិវឌ្ឍន៍ឃុំឡើយ ។

ផែនទី ១៖ ផែនទីគម្រោងអាទិភាព ឃុំក្រយា




## ២.១.២.ចំណោលប្រជាសាស្ត្រគិតទៅដល់ឆ្នាំ២០៣២

ការព្យាករណ៍ពីកំណើនប្រជាជន ជាចំណុចសំខាន់ណាស់ សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំក្រយាដែលអាចឱ្យយើងដឹងមុននូវចំនួនប្រជាជននៅក្នុងឃុំក្នុងរយៈពេល១៥ឆ្នាំខាងមុខដ៏វែងអត្រាកំណើនជាមធ្យមរបស់ប្រជាពលរដ្ឋនៅក្នុងឃុំដែលបានបង្ហាញក្នុងជំពូកទី១បានឱ្យដឹងគឺ១,៩៦ភាគរយ ដូច្នេះប្រជាពលរដ្ឋក្នុងឃុំនឹងមានការកើនឡើងរហូតដល់ឆ្នាំ២០៣២ ត្រូវបានធ្វើចំណោលតាមរយៈការគណនាដូចខាងក្រោម៖

-ចំនួនប្រជាពលរដ្ឋសរុបក្នុងឆ្នាំ ២០១៧ គឺ ១៤ ៧១៣នាក់

-អត្រាកំណើនមធ្យមប្រចាំឆ្នាំ: ១,៩៦%

-ចំនួនប្រជាជនកើនឡើងក្នុងរយៈពេល១ឆ្នាំ: **១៤ ៧១៣នាក់ x ១,៩៦% = ២៨៨នាក់/ឆ្នាំ**

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាពលរដ្ឋកើនឡើងបាន:២៨៨នាក់/ឆ្នាំ x ១៥ឆ្នាំ =៤ ៣២០នាក់**

**-ដូច្នេះប្រជាជនសរុបក្នុងរយៈពេល១៥ខាងមុខមាន:១៤ ៧១៣នាក់ + ៤៣២០នាក់ = ១៩០៣៣នាក់**

ចំណែកចំនួនគ្រួសារក្នុងឃុំ នឹងមានការកើនឡើងនៅក្នុងឆ្នាំ២០៣២ ត្រូវបានធ្វើចំណោលតាមរយៈការគណនាដូចខាងក្រោម៖

-ចំនួនប្រជាជនសរុបក្នុងឆ្នាំ២០១៧ គឺ ១៤ ៧១៣នាក់

-ចំនួនគ្រួសារសរុបក្នុងឆ្នាំ២០១៧ គឺ ៣ ៣៨៧គ្រួសារ

-ចំនួនសមាជិកមធ្យមក្នុងមួយគ្រួសារក្នុងឆ្នាំ២០១៧ គឺ:

**១៤ ៧១៣នាក់ /៣ ៣៨៧គ្រួសារ = ៤,៣៤នាក់/គ្រួសារ**

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខចំនួនគ្រួសារកើនឡើងបាន:

**៤ ៣២០នាក់/ ៤,៣៤នាក់/គ្រួសារ = ៩៩៥គ្រួសារ**

-ដូច្នេះចំនួនគ្រួសារសរុបក្នុងរយៈពេល១៥ឆ្នាំខាងមុខទៀតមាន:

**៣ ៣៨៧គ្រួសារ + ៩៩៥គ្រួសារ = ៤ ៣៨២គ្រួសារ**

តារាង 31៖ ចំណោលប្រជាសាស្ត្រនៃចំនួនគ្រួសារ និងប្រជាជនសរុប (០៥ឆ្នាំ)

| ឆ្នាំ | ចំនួនគ្រួសារ | ចំនួនប្រជាជន(នាក់) | |
|---|---|---|---|
| | | សរុប | ស្រី |
| ២០១៧ | ៣ ៣៨៧ | ១៤ ៧១៣ | ៧ ៤១៦ |
| ២០២២ | ៣ ៧២០ | ១៦ ១៥៥ | ៨ ១៤៣ |
| ២០២៧ | ៤ ០៥៣ | ១៧ ៥៩៧ | ៨ ៨៧០ |
| ២០៣២ | ៤ ៣៨២ | ១៩ ០៣៣ | ៩ ៥៩៧ |

ប្រភពទិន្នន័យ៖ *ក្រុមការងារCLUP ឆ្នាំ២០១៩*

**__☞ចំណាំ៖__**

- ចំណោលប្រជាសាស្ត្រសម្រាប់១៥ឆ្នាំខាងមុខ៖ អត្រាកំណើនមធ្យមប្រចាំឆ្នាំxចំនួនប្រជាជនឆ្នាំបច្ចុប្បន្ន/១០០
- ដូច្នេះក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើន៖ អត្រាកំណើនប្រជាជនប្រចាំឆ្នាំx១៥
- ដូច្នេះប្រជាជនសរុបក្នុងរយៈពេល១៥ទៀតមាន៖ ចំនួនអត្រាកំណើនប្រជាជន១៥ខាងមុខ+ចំនួនប្រជាជនឆ្នាំបច្ចុប្បន្ន

តារាង 32៖ ចំណោលប្រជាសាស្ត្រតាមក្រុមអាយុ (០៥ឆ្នាំ)

| ស្ថិតិតាមក្រុមអាយុ | ២០១៧ | | ២០២២ | | ២០២៧ | | ២០៣២ | |
|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អាយុពី០-២ឆ្នាំ | ៤៨០ | ២៤៤ | ៥៤១ | ២៧៥ | ៦០១ | ៣០៦ | ៦៦២ | ៣៣៧ |
| អាយុពី៣-៤ឆ្នាំ | ៦១៥ | ២៨៧ | ៦៧៦ | ៣១៨ | ៦៧៦ | ៣៤៩ | ៦៧៦ | ៣៨០ |
| អាយុ៥ឆ្នាំ | ៥៥៤ | ២៥៧ | ៦០៨ | ២៨២ | ៦៦៣ | ៣០៧ | ៧១៧ | ៣៣៣ |
| អាយុ៦-១១ឆ្នាំ | ១ ៨៤០ | ៩៣៣ | ២ ០២០ | ១ ០២៤ | ២ ២០១ | ១ ១១៦ | ២ ៣៨១ | ១ ២០៧ |
| អាយុ១២-១៤ឆ្នាំ | ១ ០៧៩ | ៥៣៤ | ១ ១៨៥ | ៥៨៦ | ១ ២៩១ | ៦៣៩ | ១៣៩៦ | ៦៩១ |
| អាយុ១៥-១៧ឆ្នាំ | ១ ០០៩ | ៤៩៣ | ១ ១០៨ | ៥៤១ | ១ ២០៧ | ៥៩០ | ១ ៣០៦ | ៦៣៨ |
| អាយុ១៨-២៤ឆ្នាំ | ១ ៩៤៧ | ១ ០១២ | ២ ១៣៨ | ១ ១១១ | ២ ៣២៩ | ១ ២១០ | ២ ៥២០ | ១ ៣១០ |
| អាយុ២៥-៦០ឆ្នាំ | ៥ ៦៩៩ | ២ ៩៣៥ | ៦ ២៥៨ | ៣ ២២៣ | ៦ ៨១៦ | ៣ ៥១០ | ៧ ៣៧៥ | ៣ ៧៩៨ |
| អាយុ៦១ឆ្នាំ | ១ ៣០៧ | ៦៥៥ | ១ ៤៣៥ | ៧១៩ | ១ ៥៦៣ | ៧៨៣ | ១ ៦៩១ | ៨៤៨ |
| ប្រជាជនសរុប | ១៤ ៧១៣ | ៧ ៤១៦ | ១៦ ១៥៥ | ៨ ១៤៣ | ១៧ ៥៩៧ | ៨ ៨៧០ | ១៩ ០៣៣ | ៩ ៥៩៧ |
| ចំនួនគ្រួសារ | ៣ ៣៨៧ | | ៣ ៧២០ | | ៤ ០៥៣ | | ៤ ៣៨២ | |

### ២.១.៣. តម្រូវការដីធ្លីជាមូលដ្ឋាន

#### ក. ដីលំនៅឋាន

ចំពោះដីលំនៅឋាន ភូមិ សំដៅទៅលើដីសម្រាប់សង់ផ្ទះ និងសម្រាប់សួនដំណាំជុំវិញផ្ទះតាមគ្រួសារ ។ នៅក្នុងឆ្នាំ២០១៧ ដែលជាឆ្នាំគោលយើងបានដឹងថា ដីលំនៅឋានមានទំហំ ៧៣៤,៦២ហិកតា និងមានគ្រួសារសរុបចំនួន ៣ ៣៨៧ គ្រួសារ គឺជាស្ថានភាពមួយដែលប្រជាជនរស់នៅមានភាពសមស្របមិនមានបញ្ហាពីការខ្វះដីសម្រាប់លំនៅឋានឡើយ លើកលែងតែគ្រួសារមួយចំនួនតូចគឺស្មើចំនួន ៣៣២គ្រួសារប៉ុណ្ណោះ ដែលមិនមានដីសម្រាប់សាងសង់លំនៅឋានហើយបច្ចុប្បន្នគ្រួសារទាំងនោះកំពុងតែរស់នៅលើដីចំណីប្រឡាយជាដីសាធារណៈ និងគ្រួសារមួយចំនួនទៀតកំពុងរស់នៅលើដីកម្មសិទ្ធរបស់អ្នកដទៃ (យោងទៅតាមទិន្នន័យនៅក្នុងជំពូកទី១ត្រង់ចំណុច ១.៣.១ អំពីការកាន់កាប់ និងគ្រប់គ្រងការប្រើប្រាស់ដី) ដែលត្រូវយកចិត្តទុកដាក់ដោះស្រាយជូនតាមរយៈដីសម្បទានដីសង្គមកិច្ចមាននៅទីតាំងក្រៅឃុំតាមការសម្រេចរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ច

ក្នុងឆ្នាំ២០១៧ ផ្ទៃដីលំនៅឋានជាមធ្យមសម្រាប់មួយគ្រួសារមានចំនួន៖

**៧៣៤,៦២ហិកតា/ ៣៣៨៧គ្រួសារ = ០,២២ហិកតា/ គ្រួសារ**

តែបើយោងទៅតាមអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច ចែងតម្រូវឱ្យមានដីលំនៅឋានយ៉ាងច្រើន ០,២៥ ហិកតា ក្នុងមួយគ្រួសារ ដែលអាចប្រើប្រាស់សម្រាប់ដោះស្រាយជូន ៣៣២គ្រួសារ ដែលគ្មានដីពិតប្រាកដ សម្រាប់លំនៅឋាន ដើម្បីអាចទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋ ដែលមាននៅទីតាំងផ្សេងក្រៅពីឃុំក្រយានេះ។

ដូច្នេះ ដើម្បីធានានិរន្តរភាពនៃការរស់នៅដូចបច្ចុប្បន្ន ចំពោះប្រជាជនដែលមានកំណើនក្នុងរយៈពេល ១៥ឆ្នាំខាងមុខ ត្រូវការដោះស្រាយដីសម្រាប់ធ្វើកសិកម្ម ក្នុងចំនួនតាមការគណនាដូចខាងក្រោម៖

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើនឡើងចំនួនៈ ៤ ៣២០នាក់

-ចំនួនសមាជិកមធ្យមក្នុងមួយគ្រួសារមានៈ ៤,៣៤នាក់/គ្រួសារ

-តម្រូវការដីលំនៅឋានក្នុង១គ្រួសារមានចំនួន ០,២២ហិកតា/ គ្រួសារ

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខចំនួនគ្រួសារកើនឡើងបានៈ

**៤ ៣២០នាក់ / ៤,៣៤នាក់/គ្រួសារ = ៩៩៥គ្រួសារ**

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ (២០១៧-២០៣២) ដីលំនៅឋានត្រូវកើនឡើងៈ**

**៩៩៥គ្រួសារ x ០,២២ហិកតា/គ្រួសារ = ២១៩ហិកតា**

**-ដូច្នេះរហូតដល់ឆ្នាំ ២០៣២ ដីលំនៅឋាននៅក្នុងឃុំក្រយាត្រូវកើនឡើងដល់ៈ**

**៧៣៤,៦២ហិកតា + ២១៩ហិកតា = ៩៥៣,៦២ហិកតា**

-ចំណែកការដោះស្រាយដីលំនៅឋានជូនគ្រួសារដែលគ្មានដីពិតប្រាកដចំនួន៣៣២គ្រួសារតាមរយៈ

សម្បទានសង្គមកិច្ចមានចំនួនៈ **៣៣២គ្រួសារ x០,២៥ ហិកតា/គ្រួសារ = ៨៣ហិកតា**

តារាង 33៖ តម្រូវការដីសម្រាប់លំនៅឋានក្នុងឆ្នាំ២០៣២

| បរិយាយ | ២០១៧ បច្ចុប្បន្ន | អនាគត ២០៣២ | បម្រែបម្រួលតម្រូវការដី |
|---|---|---|---|
| គ្រួសារ | ៣ ៣៨៧គ្រួសារ | ៤ ៣៨២គ្រួសារ | ៩៩៥ គ្រួសារ |
| តម្រូវការដីលំនៅឋាន | ៧៣៤,៦២ហិកតា | ៩៥៣,៦២ហិកតា | ២១៩ហិកតា |

### ខ. ដីកសិកម្ម

ចំពោះដីកសិកម្មសំដៅទៅលើដីសម្រាប់ធ្វើស្រែ និងដីចម្ការដំណាំ។នៅពេលវិស័យកសិកម្មកំពុងមានការវិវឌ្ឍពីកសិកម្មបែបបុរាណ ទៅជាកសិឧស្សាហកម្មនោះ តម្រូវការដីធ្លីសម្រាប់អភិវឌ្ឍវិស័យកសិកម្ម និងកសិឧស្សាហកម្ម ក៏មានកំណើនខ្ពស់លើសពីការរំពឹងទុកផងដែរ ។ នៅក្នុងឆ្នាំ២០១៧ ដែលជាឆ្នាំគោលយើងបានដឹងថា ដីកសិកម្មមានទំហំ ២ ៤៦៨,១០ហិកតា និងមានគ្រួសារសរុបចំនួន ៣ ៣៨៧គ្រួសារ អាចធ្វើស្រែផលិតស្រូវបានសល់ពីការហូបចុកខ្លះសម្រាប់ការនាំចេញទៅទីផ្សារដោះស្រាយជីវភាពគឺជាស្ថានភាពដែលប្រជាពលរដ្ឋអាចរស់នៅក្នុងជីវភាពសមរម្យបាន លើកលែងតែគ្រួសារចំនួន ៧៦០គ្រួសារ ដែលមិនមានដីសម្រាប់ធ្វើកសិកម្មផ្ទាល់ខ្លួន និងមួយចំនួនស៊ីឈ្នួលគេ ។

ដូច្នេះបច្ចុប្បន្នទំហំដីកសិកម្មសម្រាប់មួយគ្រួសារមានចំនួន៖

**២ ៤៦៨,១០ហិកតា / ៣ ៣៨៧គ្រួសារ = 0,៧៣ហិកតា/ គ្រួសារ**

បើតាមអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច ចែងតម្រូវឱ្យមានដីកសិកម្មយ៉ាងច្រើន ២ហិកតានៅក្នុង១គ្រួសារ ដែលអាចប្រើប្រាស់សម្រាប់ដោះស្រាយជូនទៅ ៧៦០គ្រួសារ ដែលគ្មានដីពិតប្រាកដសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ដើម្បីអាចទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋ ដែលមាននៅទីតាំងផ្សេងក្រៅពីនៅឃុំក្រយា។

ដូច្នេះ ដើម្បីធានានិរន្តរភាពនៃការរស់នៅដូចបច្ចុប្បន្ន ចំពោះប្រជាជនដែលមានកំណើនក្នុងរយៈពេល ១៥ឆ្នាំខាងមុខ ត្រូវការដោះស្រាយដីសម្រាប់ធ្វើកសិកម្មចំនួនតាមការគណនាដូចខាងក្រោម៖

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ គ្រួសារកើនឡើងចំនួនៈ ៩៩៥ គ្រួសារ

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ (២០១៧-២០៣២) ដីកសិកម្មត្រូវកើនឡើងៈ**

**៩៩៥ គ្រួសារ x 0,៧៣ហិកតា/គ្រួសារ = ៧២៦ហិកតា**

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ (២០១៧-២០៣២) ដីកសិកម្មសរុបមានចំនួនៈ**

**២ ៤៦៨,១០ហិកតា + ៧២៦ហិកតា = ៣ ១៩៤ហិកតា**

ចំណែកការដោះស្រាយដីកសិកម្មជូនគ្រួសារដែលគ្មានដីពិតប្រាកដចំនួន ២៥0គ្រួសារ តាមរយៈសម្បទានសង្គមកិច្ចមានទំហំដីចំនួន ៥00ហិកតា។

**៧៦0គ្រួសារ x២ ហិកតា/គ្រួសារ = ១ ៥២0ហិកតា**

តារាង 34៖ តម្រូវការដីសម្រាប់កសិកម្មក្នុងឆ្នាំ២០៣២

| បរិយាយ | ២០១៧ បច្ចុប្បន្ន | អនាគត ២០៣២ | បម្រែបម្រួលតម្រូវការដី |
|---|---|---|---|
| គ្រួសារ | ៣ ៣៨៧គ្រួសារ | ៤ ៣៨២គ្រួសារ | ៩៩៥ គ្រួសារ |
| តម្រូវការដីស្រែ | ២ ៤៦៨,១០ហិកតា | ៣ ១៩៤ហិកតា | ៧២៦ហិកតា |

ប្រភពទិន្នន័យ៖ *ក្រុមការងារបច្ចេកទេស អេស ប៊ី ខេ*

### គ. ដីព្រៃឈើ

ព្រៃឈើផ្តល់នូវផលិតផលនានា ដូចជា ឈើហ៊ុប គ្រឿងសង្ហារឹម ឈើបង្គោល ឧស និងអនុផលនានា មានជ័រ វល្លិ និងឱសថដែលជួយគាំទ្រដល់ការចិញ្ចឹមជីវិតរបស់ប្រជាជននៅជនបទតាមរយៈការប្រើប្រាស់ដោយផ្ទាល់ ឬតាមរយៈការលក់ដូរ ។ ទន្ទឹមនឹងនេះ ព្រៃឈើក៏បានដើរតួយ៉ាងសំខាន់នៅក្នុងចំណោមតួនាទីដទៃទៀត

ដូចជាទាក់ទាញទឹកភ្លៀង បញ្ចុះសីតុណ្ហភាព អាកាសធាតុបរិសុទ្ធ (ផ្តល់ខ្យល់អាកាសបរិសុទ្ធ) បញ្ចេញឧស្ម័នអុកស៊ីសែន (ជួយស្រូបយកឧស្ម័នកាបូននិច និងបញ្ចេញឧស្ម័នអុកស៊ីសែនទៅដល់មនុស្ស) ការពារគ្រោះធម្មជាតិ (ជួយទប់ទល់នឹងខ្យល់ព្យុះ ការពារទឹកជំនន់ ជួយការពារការហូរច្រោះនិងការបាក់ដី)ធ្វើឱ្យដីមានជីជាតិ ជាតំបន់ទេសចរធម្មជាតិ។ចំណែកព្រៃលិចទឹកសាបជា ជម្រកត្រីពង ផ្តល់នូវជីជាតិដី សម្រាប់ធ្វើកសិកម្ម រក្សាជីវសាស្រ្តចម្រុះ ។

ចំពោះឃុំក្រយាមានដីព្រៃឈើ ៧ ០៥៣,៥៧ហិកតា ស្មើនឹង ០៨ភាគរយ នៃផ្ទៃដីឃុំទាំងមូល ដែលនៅពេលអនាគតក្នុងឃុំក្រយាមិនមានលទ្ធភាពពង្រីកដីបន្ថែមសម្រាប់ព្រៃឈើនោះទេ តែនៅក្នុងឃុំមានលទ្ធភាពក្នុងការដាំដើមឈើបន្ថែមលើដីសាធារណៈផ្សេងៗ ដូចជាតាមដងផ្លូវ ស្ទឹង ប្រឡាយ សាលាឃុំ សាលារៀន មណ្ឌលសុខភាព និងតាមវត្តអារាមជាដើម សម្រាប់ផ្តល់ផលជាម្លប់ ពណ៌បៃតង ធ្វើឱ្យដីមានជីជាតិ ផ្តល់អុកស៊ីសែនស្រូបឧស្ម័នកាបូនិកជួយដល់សុខភាពប្រជាពលរដ្ឋ។ល។

### ឃ. ធនធានទឹក

ឃុំក្រយា ជាឃុំមានសក្តានុពលទៅលើផ្នែកសិកម្ម ដំណាំស្រូវ និងចម្ការដំណាំឧស្សាហកម្ម ដែលនាំឱ្យឃុំក្រយាមានគោលដៅអភិវឌ្ឍន៍រយៈពេលវែងរបស់ខ្លួន ដោយផ្តោតសំខាន់លើកសិកម្មដំណាំស្រូវ និងចម្ការដំណាំឧស្សាហកម្មនេះមិនអាចគេចចេញបានឡើយ ។ ដូច្នេះ ដើម្បីជំរុញវិស័យកសិកម្មដំណាំស្រូវ កត្តាចាំបាច់មួយក្នុងចំណោមកត្តាជាច្រើន គឺកត្តាទឹក ជាកត្តាសំខាន់ ដែលត្រូវយកចិត្តទុកដាក់ដោយត្រូវធ្វើយ៉ាងណាឱ្យមានទឹកគ្រប់គ្រាន់សម្រាប់ការស្រោចស្រពបានគ្រប់រដូវកាលទៅលើដីស្រែ និងចម្ការដែលឃុំមាន ដើម្បីដោះស្រាយទឹកនៅពេលមានគ្រោះរាំងស្ងួតនិងធ្វើស្រែបង្កើនរដូវឱ្យទទួលបានផលិតភាពខ្ពស់ក្នុងការជួយផ្គត់ផ្គង់ដល់ការហូបចុក និងជំរុញការនាំចេញបង្កើនសេដ្ឋកិច្ចគ្រួសារក៏ដូចសេដ្ឋកិច្ចជាតិដើម្បីអាចឆ្លើយតបបានទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការជម្រុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ។

ចំពោះឃុំក្រយានាបច្ចុប្បន្ន មានស្ទឹង បឹង និងស្រះទឹក ដែលមានផ្ទៃដីសរុបទំហំ ៤៨១,៥៨ ហិកតា ស្មើនឹង ០,៥៤ភាគរយ នៃផ្ទៃដីឃុំសរុប ដូច្នេះពេលអនាគត ឃុំក្រយាត្រូវការប្រើប្រាស់ដីបន្ថែមក្នុងតំបន់ដីស្រែសម្រាប់រៀបចំស្តារប្រឡាយដែលមានស្រាប់ សម្រាប់ការនាំទឹកមកស្រោចស្រពដំណាំស្រូវ ហើយក៏អាចជាជម្រកត្រីនាំឱ្យកើនឡើងបរិមាណត្រី បូកផ្សំជាមួយការយកចិត្តទុកដាក់ក្នុងការចិញ្ចឹមត្រីតាមបែបចិញ្ចឹមនៅក្នុងស្រះខ្នាតតូច ស្រះចិញ្ចឹមត្រីតាមគ្រួសារលាយឡំជាមួយបន្លែចម្រុះ និងកសិដ្ឋានចិញ្ចឹមត្រីក្នុងស្រែដែលជាទម្រង់មួយនៃវារីវប្បកម្ម ដែលជាបច្ចេកទេសមួយជួយដើម្បីបង្កើនបរិមាណត្រី ដោយអាចបង្កើនផលិតភាពជលផលតាមវាលស្រែ ហើយមានប្រយោជន៍ក្នុងការប្រើត្រីសម្រាប់ទប់ទល់សត្វល្អិត និងដង្កូវហ្វូងក្នុងស្រែដែលបំផ្លាញផលស្រូវផង ដែលអាចផ្តល់ជាប្រភពប្រូតេអ៊ីនសាច់ដ៏សំខាន់បំផុតសម្រាប់ប្រជាពលរដ្ឋក្នុងឃុំគួរទទួលបាននូវអាហារ សម្រាប់ទ្រទ្រង់សុខភាព និងជិវិតរស់នៅឱ្យមានភាពល្អប្រសើរ ។

## ង. ហេដ្ឋារចនាសម្ព័ន្ធសង្គម និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត

### ង.១. វិស័យអប់រំ

កុមារគ្រប់រូបមានសិទ្ធិរៀនសូត្រ មិនថាពួកគេស្ថិតនៅក្នុងកាលៈទេសៈបែបណានោះឡើយ ។ ការផ្តល់ការគាំទ្រគ្រប់គ្រាន់ដល់ការរៀនសូត្ររបស់កុមារ មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីឱ្យពួកគេអាចអភិវឌ្ឍខ្លួនឈានទៅសម្រេចបានសក្តានុពលរបស់ពួកគេ ។ យ៉ាងណាមិញនៅក្នុងឃុំក្រយាទៅថ្ងៃអនាគត ក្នុងរយៈពេល១៥ឆ្នាំទៅ

មុខនឹងមានការកើនឡើងនូវចំនួនកុមារ និងមនុស្សវ័យជំទង់ក្នុងវ័យសិក្សា ដូចមានការគណនាក្នុងចំណុច ២.១.២ ស្តីពីចំណោលប្រជាសាស្ត្រខាងលើ ដែលចាំបាច់ត្រូវគិតគូរដោះស្រាយបន្ទប់រៀនបន្ថែមគ្រប់កម្រិត នៅតាមទីតាំងសាលារៀនដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ន ។

❖ មត្តេយ្យសិក្សា:

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ កុមារមានអាយុពី៣-៥ឆ្នាំ នឹងកើនឡើងចំនួនៈ ១ ៣៩៣នាក់

-តាមរយៈមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ បានឱ្យដឹងពីការកំណត់សម្រាប់មត្តេយ្យសាលាក្នុងមួយថ្នាក់មានចំណុះកុមារសិក្សារៀនសូត្រ **៥០នាក់**

**-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់មត្តេយ្យត្រូវការបន្ថែមចំនួនៈ**

**១ ៣៩៣នាក់ /៥០ នាក់/បន្ទប់= ២៨បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ**

**២៨បន្ទប់ / ៥ បន្ទប់/អគារ=៦អគារ**

❖ **បឋមសិក្សា**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ៦-១១ ឆ្នាំនឹងកើនឡើងចំនួនៈ ២ ៣៨១នាក់

**-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់បឋមសិក្សាត្រូវការបន្ថែមចំនួនៈ**

**២ ៣៨១នាក់ ៖ ៤៥នាក់/បន្ទប់ = ៥៣បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៦ បន្ទប់បន្ថែមចំនួនៈ**

**៥៣បន្ទប់ ៖ ៦ បន្ទប់/អគារ = ៩អគារ**

-តែក្នុងករណីត្រូវរៀន**២វេន**ក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាតែចំនួនៈ

**៩អគារ/វេន ៖ ២ វេន = ៥អគារ**

❖ **អនុវិទ្យាល័យ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ១២-១៤ ឆ្នាំនឹងកើនឡើងចំនួនៈ ២ ៧០២នាក់

**-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់អនុវិទ្យាល័យសិក្សាត្រូវការបន្ថែមចំនួនៈ**

**២ ៧០២នាក់ ៖ ៤៥នាក់/បន្ទប់ = ៦០បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ១២ បន្ទប់បន្ថែមចំនួនៈ**

**៦០បន្ទប់ ៖ ១២បន្ទប់/អគារ = ៥អគារ**

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាតែចំនួនៈ

**៥ អគារ / វេន ៖ ២ វេន = ៣អគារ**

❖ **វិទ្យាល័យ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ១៥-១៧ឆ្នាំនឹងកើនឡើងចំនួនៈ ២ ៥២០នាក់

**-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់អនុវិទ្យាល័យសិក្សាត្រូវការបន្ថែមចំនួនៈ**

**២ ៥២០នាក់ ៖ ៤៥នាក់/បន្ទប់ = ៥៦បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ១២ បន្ទប់បន្ថែមចំនួនៈ**

**៥៦បន្ទប់ ៖ ១២បន្ទប់/អគារ = ៥អគារ**

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាតែចំនួនៈ

**៥អគារ / វេន ៖ ២ វេន = ៣អគារ**

តារាង 35៖ កំណើនកុមារ តម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១៨ ដល់ ឆ្នាំ២០៣២

| បរិយាយ | បច្ចុប្បន្ន២០១៧ | អនាគត ២០៣២ | បម្រែបម្រួល |
|---|---|---|---|
| **សាលាមត្តេយ្យ** | | | |
| សិស្ស | 0 | ១ ៣៩៣នាក់ | ១ ៣៩៣នាក់ |
| បន្ទប់ | 0 | ២៨បន្ទប់ | ២៨បន្ទប់ |
| អគារ | 0 | ៦អគារ | ៦អគារ |
| **សាលាបឋមសិក្សា** | | | |
| សិស្ស | ២ ២៧៨នាក់ | ២ ៣៨១នាក់ | ១០៣នាក់ |
| បន្ទប់ | ៦៥បន្ទប់ | ៥៣បន្ទប់ | -១២បន្ទប់ |
| អគារ | ១២ អគារ | ៩ អគារ | -៣អគារ |
| **អនុវិទ្យាល័យ** | | | |
| សិស្ស | ៣៤៨នាក់ | ២ ៧០២នាក់ | ២ ៣៥៤នាក់ |
| បន្ទប់ | ៥ បន្ទប់ | ៦០បន្ទប់ | ៥៥បន្ទប់ |
| អគារ | ១អគារ | ៥ អគារ | ៤អគារ |
| **វិទ្យាល័យ** | | | |
| សិស្ស | 0 | ២ ៥២០នាក់ | ២ ៥២០នាក់ |
| បន្ទប់ | 0 | ៥៦បន្ទប់ | ៥៦បន្ទប់ |
| អគារ | 0 | ៥អគារ | ៥អគារ |

ប្រភពទិន្នន័យ៖ *ក្រុមការងារបច្ចេកទេស អេស ប៊ី ខេ*

## ង.២. វិស័យសុខាភិបាល

ឃុំក្រយា មិនទាន់មានមណ្ឌលសុខភាពស្ថិតនៅក្នុងឃុំនោះទេ មានតែប៉ុស្តិ៍សុខភាព ដែលស្ថិតនៅក្នុងភូមិសែនសេរីមង្គល។ ប្រជាពលរដ្ឋមួយចំនួនបានមកប្រើប្រាស់សេវាសុខភាពនៅមណ្ឌលសុខភាពល្អក់ ដែលស្ថិតនៅក្នុងភូមិល្អក់ ឃុំកំពង់ថ្ម ។ ជាយុទ្ធសាស្ត្រក្រុមប្រឹក្សាឃុំអាណត្តិទី៤ ក៏ដូចជា បណ្តាមេភូមិ បានរៀបចំផែនការបង្កើតឱ្យមានមណ្ឌលសុខភាព ០១ កន្លែង នៅក្នុងឃុំសម្រាប់រយៈពេល១៥ឆ្នាំខាងមុខ ដើម្បីងាយស្រួលផ្តល់ការគាំទ្រសេវាថែទាំ និងព្យាបាលសុខភាពផ្សេងៗរបស់ប្រជាពលរដ្ឋបានរហ័សទាន់ចិត្ត និងកាត់បន្ថយការចំណាយពេលវេលារបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានមកមណ្ឌលសុខភាពនៅឃុំផ្សេងឬពេទ្យបង្អែកស្រុក ដែលមានទីតាំងឆ្ងាយៗ ។

## ង.៣. អគ្គិសនី

អគ្គិសនី គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ជីវិតរស់នៅរបស់មនុស្សយើង។ អគ្គិសនីផ្តល់ឱ្យយើងនូវសន្តិសុខ សុវត្ថិភាព សុខភាព និងភាពសម្បូររុងរឿង ដូចជា ជួយដោះស្រាយបញ្ហា និងធ្វើឱ្យកាន់តែប្រសើរ

ឡើងនូវសន្តិសុខ សុវត្ថិភាព ការប្រែប្រួលអាកាសធាតុ ផលិតកម្មស្បៀងអាហារ និងការពង្រឹងសេដ្ឋកិច្ចដោយរួមទាំងការអប់រំ និងកម្សាន្តផងដែរ ។ ចំពោះស្ថានភាពនៃការប្រើប្រាស់អគ្គិសនីនៅក្នុងឃុំក្រយា ដូចដែលបានរៀបរាប់ក្នុងជំពូកទី១ ដោយបច្ចុប្បន្នមានប្រជាពលរដ្ឋប្រើប្រាស់បណ្តាញអគ្គិសនីមានចំនួន ៣៣ភាគរយប៉ុណ្ណោះ ហើយនៅសល់ចំនួនគ្រួសារប្រមាណ ៦៧ភាគរយ ដែលមិនទាន់បានទទួលសេវាកម្មនេះនៅឡើយ ។ ដូច្នេះនៅពេលអនាគត ១៥ឆ្នាំទៅមុខនឹងមានការកើនឡើងចំនួនគ្រួសារថែមទៀត អាជ្ញាធរពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ជាពិសេសក្រុមប្រឹក្សាឃុំក្រយា ត្រូវខិតខំយកចិត្តទុកដាក់ក្នុងការដោះស្រាយ ពង្រីកបណ្តាញអគ្គិសនីតភ្ជាប់ផ្គត់ផ្គង់ឱ្យដល់គ្រប់គ្រួសារបានប្រើប្រាស់ ។

### ៦.៨. ទីលានចាក់សំរាម

សំរាម គឺជាកាកសំណល់ដែលត្រូវបានគេបោះបង់ចោល វាមានពីរបែប គឺកាកសំណល់រឹង និងរាវ។ ដូច្នេះសំរាមគឺជាអ្វីៗដែលបានបំបែកចេញពីបរិស្ថានយើង ហើយនឹងបង្កើតកន្លែងគរសំរាមមួយផ្សេងទៀតប្រសិនបើយើងមិនប្រុងប្រយ័ត្ន ។ គំនរសំរាមចេញមកពីកាកសំណល់ផ្ទះបាយដាក់លាយឡំចូលគ្នាជាមួយនឹងអំបែងកែវ អំបែងចាន និងអំបែងដបជាដើម។ នៅពេលមានភ្លៀងធ្លាក់ចុះមក គឺដូចជាការចម្រោះជាតិពុល គ្រប់បែបយ៉ាង ឱ្យហូរជ្រាបទៅបំពុលដី បំពុលទឹក និងបំពុលដល់ប្រភពទឹកនៅក្នុងស្រទាប់ដីខាងក្រោម ជាហេតុធ្វើឱ្យទឹកស្អាតក្លាយជាទឹកមិនស្អាត មានលោហៈធ្ងន់ និងជួនកាលមានបាក់តេរីកាចៗ ដែលនៅពេលនោះ មានលេចឡើងនូវជម្ងឺរាតត្បាតផ្សេងៗដោយសារតែការទទួលទានទឹកមិនស្អាត ។

ចំពោះសំរាមនៅក្នុងឃុំក្រយាបច្ចុប្បន្នប្រជាពលរដ្ឋភាគច្រើនបោះចោលសំរាមនៅក្បែរផ្ទះ ខ្លះចោលរាយប៉ាយនៅតាមផ្លូវ ខ្លះដុតចោល ដែលធ្វើឱ្យរងការបំពុលពីផ្សែងដុត និងបាត់បង់សោភ័ណភាពក្នុងភូមិ ឃុំ។ ដើម្បីអាចគ្រប់គ្រងសំរាមបាន ឃុំត្រូវរកដីដែលមានទីតាំងសមស្របនៅក្នុងឃុំ ដែលនៅដាច់ដោយឡែកឆ្ងាយពីភូមិធ្វើទីលានចាក់សំរាមមួយកន្លែង តែក្នុងករណីក្នុងឃុំមិនមានទីលានចាក់សំរាមក៏គួររៀបចំឱ្យមានឡត៍ សម្រាប់ដុតសំរាមមួយផងដែរ ដើម្បីប្រមូលសំរាមដែលមាននៅក្នុងឃុំទៅរក្សាទុកឱ្យបានគត់មត់ ឬត្រូវប្រមូលសំរាមប្លាស្ទីកយកកែច្នៃផលិតឡើងវិញ ចំណែកសំរាមពីផ្ទះបាយនិងស្លឹកឈើផ្សេងពីប្លាស្ទីកអាចកែច្នៃធ្វើជីដូចជាជីកំប៉ុស្តជាដើម ដើម្បីប្រើប្រាស់បង្កើនគុណភាពដីដាំដុះ ។ ជារួមសំខាន់ជាងគេបំផុត គឺត្រូវលុបបំបាត់សំរាមប្លាស្ទិកឱ្យអស់ពីភូមិ ឃុំ។

### ៦.៩. ដីកប់ខ្មោច

ជាទូទៅពិធីបូជាសព មានពីបែបគឺពិធីដុតសព និងកប់សពរក្សាក្នុងដី ដែលពិធីទាំងពីរនេះពីធីកប់សពត្រូវការប្រើប្រាស់ដី ដែលធ្វើឱ្យមានការបាត់បង់ដីសម្រាប់ប្រើប្រាស់បម្រើឱ្យការអភិវឌ្ឍន៍ក្នុងសហគមន៍ ដែលមនុស្សរស់នៅ។ នៅក្នុងឃុំក្រយាបច្ចុប្បន្នក៍មានប្រើពិធីទាំងពីរនេះដែរហើយការប្រើប្រាស់ដីនៅក្នុងឃុំក្រយា ក៏មានតម្រូវការកាន់តែច្រើនឡើង ស្របនឹងកំណើនប្រជាពលរដ្ឋទៅអនាគត ដែលចាំបាច់អាជ្ញាធរដែលដីពាក់ព័ន្ធជាពិសេសក្រុមប្រឹក្សាឃុំក្រយា ត្រូវតែខិតខំយកចិត្តទុកដាក់គិតគូរអំពីពិធីបូជាសពនេះ ដែលនឹងកើតមានឡើងជាបន្តបន្ទាប់ដោយគួរខិតខំលប់បំបាត់ការបញ្ចុះសព ដោយកប់ក្នុងដី ហើយជំនួសមកវិញដោយការរៀបចំឱ្យមានកន្លែងបូជាសពនៅតាមវត្តអារាមឬកន្លែងណាផ្សេងដាច់ឆ្ងាយពីភូមិដែលជាជម្រើសល្អបំផុត ។

### ង.៦. ស្រះ និងអណ្តូងទឹក

ទឹក គឺជាផ្នែកមួយនៃធាតុដ៏សំខាន់បំផុត សម្រាប់រាងកាយមនុស្ស ជាពិសេសសម្រាប់សុខភាព ដើម្បីធានាបាននូវការរស់រានមានជីវិតរបស់មនុស្ស ។ ទឹកអាចនឹងមានស្ថិតនៅគ្រប់ទីកន្លែង ប៉ុន្តែមិនត្រូវបានយកមកសម្រាប់ការទទួលទានបានទាំងអស់នោះទេ គឺត្រូវការទឹកដែលស្អាត ។ នៅក្នុងឃុំក្រយាបច្ចុប្បន្នមានការប្រើប្រាស់ទឹកស្អាតសម្រាប់ទទួលទានតាមរយៈការប្រើទឹកស្រះ និងអណ្តូងដូចបានរៀបរាប់ក្នុងជំពូកទី១នៃរបាយការណ៍នេះ ប៉ុន្តែបានរកឃើញថា ចំនួនស្រះទឹក និងអណ្តូងទាំងអស់នេះមិនមានបរិមាណគ្រប់គ្រាន់សម្រាប់បំពេញតម្រូវរបស់មនុស្ស និងសត្វចិញ្ចឹមគ្រប់គ្រាន់នារដូវប្រាំងបានឡើយ ។

ដូច្នេះ ដើម្បីឆ្លើយតបទៅនឹងការខ្វះខាតពេលបច្ចុប្បន្ននេះ ក៏ដូចជា ឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋក្នុងរយៈពេល១៥ឆ្នាំខាងមុខបាន អាជ្ញាធរដែនដីពាក់ព័ន្ធទាំងអស់ ជាពិសេសក្រុមប្រឹក្សាឃុំក្រយាត្រូវតែយកចិត្តទុកដាក់លើកទឹកចិត្តឱ្យប្រជាពលរដ្ឋក្នុងឃុំត្រងទឹកភ្លៀងនៅរដូវវស្សា រក្សាទុកក្នុងអាងស្តុកតាមផ្ទះរៀងៗខ្លួនសម្រាប់ទុកដោះស្រាយការប្រើប្រាស់នៅរដូវប្រាំងដែលខ្សត់ទឹក ហើយថែមពីលើនេះទៀត ក៏ត្រូវបំផុសឱ្យមានការរៀបចំជីកស្រះសហគមន៍ផងដែរ ព្រមទាំងជំរុញលើកទឹកចិត្តដល់វិស័យឯកជនឱ្យផលិតទឹកស្អាត តបណ្តាញឱ្យដល់គ្រប់ខ្នងផ្ទះ ប្រជាពលរដ្ឋបានប្រើប្រាស់គ្រប់ក្រុមគ្រួសារដែលជាជម្រើសដ៏ល្អបំផុត ។

## ២.២. តំបន់រសើប

តំបន់រសើប ជាតំបន់ដែលទាមទារនូវការការពារបន្ថែម និងជាពិសេសដោយផ្អែកលើសារៈសំខាន់ ឬជីវចម្រុះនៃបរិស្ថាន បេតិកភ័ណ្ឌវប្បធម៌ តំលៃខាងផ្លូវចិត្តដែលមានលក្ខណៈដូចជា៖ តំបន់ប្រពៃណីសម្រាប់ជនជាតិដើមភាគតិច ឬក៏មូលហេតុសំខាន់ៗផ្សេងទៀត។ តំបន់បង្ហាញបញ្ហាចោទ ចាំបាច់ត្រូវតែកំណត់ ដើម្បីធានាថាឃុំត្រូវការដឹងឮនូវតម្រូវការ និងប្រធានបទពិសេសទាំងនេះ។

នៅក្នុងឃុំក្រយា តំបន់រសើបមាននៅលើដីស្រែចម្ការ របស់ប្រជាពលរដ្ឋដែលសង្ស័យថាមានគ្រាប់មិនទាន់ព្រមទាំងតំបន់ព្រៃស្រោង និងព្រៃល្បោះដែលជាព្រៃសហគមន៍ ។ សម្រាប់តំបន់ដីសង្ស័យមានមីនដែលត្រូវទាមទារនូវកិច្ចការពារបន្ថែម និងជាពិសេសនោះ ដោយសារតំបន់នេះត្រូវការហាមឃាត់ប្រជាពលរដ្ឋចូលទៅតំបន់នេះ ដែលនាំឱ្យមានគ្រោះថ្នាក់ពីគ្រាប់មីនមិនទាន់ផ្ទុះ ចំណែកតំបន់ដីព្រៃសហគមន៍ដែលត្រូវទាមទារនូវកិច្ចការពារបន្ថែម និងជាពិសេសនោះ ដោយសារតំបន់នេះត្រូវថែរក្សាទុកស្របតាមច្បាប់ស្តីពីព្រៃឈើជាតំបន់សហគមន៍ព្រៃឈើ ។

ផែនទី 10៖ ផែនទីតំបន់រសើប




# ២.៣.ការប្រឈម

## ២.៣.១.ការប្រឈមដោយធម្មជាតិ

### ក. កំណើនប្រជាជន

បច្ចុប្បន្ននៅក្នុងឃុំក្រយា បានរកឃើញថា ប្រជាពលរដ្ឋកើនឡើងតាមធម្មជាតិជារៀងរាល់ឆ្នាំមដែលគិតជាមធ្យមប្រមាណ ១,៩៦ភាគរយ ហើយទៅថ្ងៃអនាគតត្រឹមឆ្នាំ២០៣២បញ្ហាកំណើនប្រជាជនត្រូវបានធ្វើការគិតគូរដោះស្រាយ ដោយពុំមានបញ្ហាប្រឈមធ្ងន់ធ្ងរឡើយ តែបន្តពីនេះទៅមុខវែងឆ្ងាយនឹងអាចកើតមានបញ្ហាប្រឈមដែលត្រូវបន្តដោះស្រាយមួយចំនួនដូចខាងក្រោម៖

-មានការខ្វះខាតដីលំនៅឋាន ដែលនាំឱ្យមានការដោះស្រាយផលប៉ះពាល់ទៅដល់ដីស្រែ។

-មានការខ្វះខាតដីស្រែ ដែលនាំឱ្យពិបាកដោះស្រាយ ដោយនៅក្នុងឃុំពុំមានដីសល់ទំនេរសម្រាប់បំពេញការខ្វះខាតនេះ។

-មានការខ្វះខាតទៅដល់ការផ្តល់សេវាអប់រំដែលត្រូវដោះស្រាយការសាងសង់សាលារៀន គ្រូបង្រៀន និងសម្ភារៈសិក្សាបន្ថែម។

-មានការខ្វះខាតសេវាសុខាភិបាល ដែលត្រូវដោះស្រាយគ្រូពេទ្យ ឧបករណ៍ និងសម្ភារៈបរិក្ខាពេទ្យ និងថ្នាំសង្កូវបន្ថែម។

-មានការខ្វះខាតទឹកស្អាត អគ្គិសនី ដែលត្រូវដោះស្រាយ សម្រាប់ការផ្គត់ផ្គង់បន្ថែម។

ខ. គ្រោះធម្មជាតិ ការរេចរឹលនៃធម្មជាតិ

បច្ចុប្បន្ននៅក្នុងឃុំក្រយា គេបានកត់សម្គាល់ឃើញថា មានជួបប្រទះនូវគ្រោះធម្មជាតិកើតឡើង ស្ទើរតែរៀងរាល់ឆ្នាំ ដូចជាគ្រោះរាំងស្ងួត ទឹកជំនន់ ខ្យល់កន្ត្រាក់ជាដើម ។ ទន្ទឹមនឹងនេះ ដីធ្លីដែលជាធនធានធម្មជាតិកម្រនៅក្នុងឃុំក្រយា ក៏មានភាពរេចរឹលទៅៗផងដែរ ដូចជាធ្វើឱ្យដីស្រែរឹង និងខ្សោះជីជាតិ ដោយសារមូលហេតុនៃការប្រើប្រាស់ជីគីមី និងថ្នាំគីមីសម្លាប់សត្វល្អិតទៅលើដំណាំស្រូវ និងដំណាំដទៃទៀតមិនបានស្របតាមបទដ្ឋានបច្ចេកទេស ព្រមទាំងមានការថយចុះ និងបាត់បង់នូវធនធានជលផល ជាពិសេសមច្ឆាជាតិ ដោយការប្រើប្រាស់ឧបករណ៍ឆក់ដែលជាឧបករណ៍នេសាទខុសច្បាប់ ។ ទៅថ្ងៃអនាគតប្រជាពលរដ្ឋនៅតែបន្ត ជួបប្រទះនូវបញ្ហាប្រឈមទាំងអស់នេះជាដដែល បើសិនមិនមានយន្តការ ឬដំណោះស្រាយទប់ទល់នឹងគ្រោះរាំងស្ងួត ព្រមទាំងមានការកែប្រែឥរិយាបថក្នុងការប្រើប្រាស់ដីធ្លីសម្រាប់កសិកម្មឱ្យបានសមស្របទេនោះ។

### ២.៣.២. ការប្រឈមដោយ ការអភិវឌ្ឍន៍ដែលពុំមាននិរន្តរភាព

ជាការពិតណាស់រាល់គម្រោងអភិវឌ្ឍន៍នានា ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានធម្មជាតិ ជាពិសេសការប្រើប្រាស់ដីនៅក្នុងទីតាំងភូមិសាស្ត្រណាមួយ តែងនាំមកការរីកចម្រើនជានិច្ច តែផ្ទុយទៅវិញបើគម្រោងអភិវឌ្ឍន៍ទាំងនោះពុំទាន់បានគិតគូរគ្រប់ជ្រុងជ្រោយទៅដល់ទីតាំងភូមិសាស្ត្រនីមួយៗ និងសក្តានុពលនៃធនធាន ដែលមានវានឹងនាំមកនូវផលប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ចសង្គម និងបរិស្ថាននាពេលអនាគត ដោយមិនអាចធានាចិរភាពនៃគម្រោងទាំងនោះដល់កូនចៅជំនាន់ក្រោយក្នុងតំបន់នោះបានឡើយ ដូចជា ស្ថានភាពនៅក្នុងឃុំក្រយាដែលជាឃុំគោលដៅសិក្សារៀបចំផែនការប្រើប្រាស់ដី ដូចបានរៀបរាប់ក្នុងជំពូកទី១ នៃរបាយការណ៍នេះបានឱ្យដឹងថា ឃុំក្រយា មានស្ថានភាពភូមិសាស្ត្រជាតំបន់ខ្ពង់រាប និងវាលទំនាបមានធនធានដីអំណោយផលដល់ដំណាំស្រូវ និងដំណាំចម្ការ ដែលជាសក្តានុពលដល់ការអភិវឌ្ឍដល់ឃុំនេះ ដោយមិនមានការអះអាងណាផ្សេងក្រៅពីនេះនៅឡើយ ។ ដូចនេះឃុំក្រយា គួរជៀសវាងដាច់ខាតនៅគម្រោងអភិវឌ្ឍន៍ទាំងឡាយណាដែលនាំឱ្យមានផលប៉ះពាល់ដល់ការបាត់បង់ដីស្រែ និងដីចម្ការដំណាំដែលខ្លួនមាន ធ្វើឱ្យឃុំក្រយាមានការថយចុះនូវឱកាសអភិវឌ្ឍ ដូចជាគម្រោងចាក់លុបដីស្រែ ដីចម្ការបង្កកទុកលក់ ឬពុះដីឡូត៍លក់ ដើម្បីកេងផលចំណេញពីឈ្មួញ និងគម្រោងជីកយកអាចម៍ដីយកលក់ជាដើម ។ លើកលែងតែគម្រោងណាដែលពាក់ព័ន្ធដែលធ្វើឱ្យប្រសើរឡើងដល់ប្រព័ន្ធកសិកម្ម ដូចជា កសិដ្ឋានផលិតពូជស្រូវ ពូជដំណាំ ស្រែគម្រូ ផលិតជីធម្មជាតិ និងទុកដាក់គ្រឿងយន្តកសិកម្ម ទន្ទឹមនិងនេះ ក៏នៅមានគម្រោងអភិវឌ្ឍន៍ដល់ការរស់នៅ និងបរិស្ថាន ដែលគួរចៀសវាងផងដែរ ដូចជាគម្រោងបង្កើតសិប្បកម្ម ឧស្សាហកម្ម ដែលធ្វើឱ្យមានការបង្ហូរទឹកស្អុយកខ្វក់ជាដើម។ល។ ទន្ទឹមនឹងការប្រឈមដោយការអភិវឌ្ឍខាងលើដែលត្រូវចៀសវាងក៏នៅមានការប្រឈមទៅ និងអំពើអនាធិបតេយ្យដែលកើតឡើងពីការដោះស្រាយការខ្វះខាតរបស់ប្រជាពលរដ្ឋនៅក្នុងឃុំផងដែរ ដូចជា ការសាងសង់ផ្ទះស្នាក់លើដីនៅតាមមាត់ប្រឡាយ នៅតាមចិញ្ចើមផ្លូវសាធារណៈ ការទន្ទ្រានដីទួលសាធារណៈ ធ្វើស្រែបំពានលើប្រឡាយ ព្រមទាំងការនេសាទខុសច្បាប់ជាដើម ។

## ២.៤. ឱកាស

### ២.៤.១.ដោយអំណោយផលពីធម្មជាតិ

នៅលើលោកយើងនេះ ធម្មជាតិ គឺបានផ្តល់នូវធនធានដ៏មានសារៈសំខាន់ សម្រាប់ធ្វើអ្វីៗគ្រប់បែបយ៉ាងដែលមនុស្សចង់ធ្វើ ដូចជា មនុស្សប្រើប្រាស់ដី និងទឹកសម្រាប់ការដាំដំណាំ ឈើធ្វើអុសដុតសម្រាប់ផ្តល់កំដៅ ឬ

សាងសង់ទីជម្រក ខ្យល់អាកាស ធ្យូងថ្ម ប្រេង ឧស្ម័នធម្មជាតិ និងរ៉ែ ព្រមទាំងវត្ថុធាតុដើមជាច្រើនទៀត ដូចជាដែក ទង់ដែង។ល។ សម្រាប់ធ្វើឧបករណ៍ប្រើប្រាស់ផ្សេងៗ ។ ចំណែកនៅក្នុងឃុំក្រយា យើងផ្តោតសំខាន់ទៅធនធានដី ដែលមានសក្តានុពលលើសលប់ទៅលើការអភិវឌ្ឍន៍ឃុំ ដូចអ្វីដែលបានរកឃើញ និងរៀបរាប់នៅក្នុងជំពូកទី១នៃរបាយការណ៍នេះ។ នៅក្នុងឃុំក្រយាមានស្ថានភាពអំណោយផលពីធម្មជាតិដូចខាងក្រោម៖

- ស្ថានភាពដីជាវាលទំនាប អំណោយផលទៅដល់ការដាំដុះដំណាំស្រូវ ព្រមទាំងទំនាបទាប និងទំនាបខ្ពស់អំណោយផលដល់ការដាំដំណាំចម្ការជាពិសេសដំណាំឧស្សាហកម្ម។
- នៅជិតប្រភពស្ទឹង បឹង អូរ អាចមានលទ្ធភាពនាំទឹកមកស្រោចស្រពដំណាំស្រូវ និងដំណាំចម្ការ នៅពេលជួបប្រទះគ្រោះរាំងស្ងួត និងមានលទ្ធភាពនាំទឹកមកស្រោចស្រពបង្កើនរដូវធ្វើស្រែបានច្រើនដង។
- នៅរដូវវស្សាមានភ្លៀងធ្លាក់ច្រើនអាចស្រោចស្រពដំណាំស្រូវ និងដំណាំចម្ការបាន។
- អាកាសធាតុ ក្តៅ ហើយសើម ជាអំណោយផលដល់ការលូតលាស់របស់រុក្ខជាតិ និងដំណាំគ្រប់ប្រភេទ។

### ២.៤.២. ដោយបច្ចេកវិទ្យាថ្មីៗ

ជីវិតរស់នៅ ដែលយើងកំពុងទទួលបានភាពល្អប្រសើរឡើងនាពេលបច្ចុប្បន្ននេះ គឺដោយសារតែមានការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា ។ បច្ចេកវិទ្យាថ្មីៗ ធ្វើឱ្យមានការផ្លាស់ប្តូរបានយ៉ាងប្រសើរឡើងនៃជីវិតរស់នៅរបស់ពលរដ្ឋ ដែលធ្វើឱ្យអ្វីៗ ក្នុងពេលបច្ចុប្បន្នកាន់តែប្រសើរឡើង និងងាយស្រួលជាងមុន ។ បច្ចេកវិទ្យាថ្មីអាចកាត់បន្ថយបាននូវពេលវេលា គុណភាព និងការចំណាយទៅលើកម្លាំងពលកម្មក្នុងផលិតកម្មនានា ។

បច្ចុប្បន្ន ស្ថានភាពនៅក្នុងឃុំក្រយា គឺមានសក្តានុពលខ្លាំងដោយពឹងផ្អែកទៅលើផលិតកម្មដំណាំស្រូវ និងដំណាំចម្ការឧស្សាហកម្មហើយនាពេលអនាគតក៏នៅតែពឹងផ្អែកលើផលិតកម្មដំណាំទាំងនេះដដែលដែរនោះ ប្រជាពលរដ្ឋនឹងចាំបាច់ត្រូវការបច្ចេកវិទ្យាទំនើបទាន់សម័យ សម្រាប់វិស័យកសិកម្មដំណាំស្រូវ និងចម្ការៈដើម្បីជួយជំរុញឱ្យមានការកើនឡើងទិន្នផលខ្ពស់ ដើម្បីដោះស្រាយបាននូវសន្តិសុខស្បៀង និងប្រាក់ចំណូលកាន់តែខ្ពស់នាំឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង ក្នុងពេលដែលមានកំណើនប្រជាពលរដ្ឋកាន់តែខ្ពស់។ បើតាមរយៈបច្ចេកវិទ្យាថ្មីនឹងនាំឱ្យប្រជាពលរដ្ឋមានឱកាសអាចប្រើប្រាស់នូវគ្រឿងយន្តកសិកម្មទំនើបទាន់សម័យសម្រាប់ការផលិតដំណាំស្រូវ រួមមានដូចជា ៖ ម៉ាស៊ីនភ្ជួររាស់ដី ម៉ាស៊ីនពង្រាបដីស្រែដោយប្រើប្រព័ន្ធឡាស៊ែរ ម៉ាស៊ីនដកស្ទូង ដ្រូនបាញ់ថ្នាំសម្លាប់សត្វល្អិត និងដាក់ជី ម៉ាស៊ីនច្រូតកាត់ និងបោកបែន ព្រមទាំងគ្រឿងយន្តដឹកជញ្ជូនជាដើម។ល។

### ២.៤.៣. ដោយគម្រោងវិនិយោគ

សម្រាប់នាពេលអនាគត ឃុំក្រយា ដែលមានសក្តានុពលខ្ពស់ទៅលើដំណាំស្រូវ នឹងនាំឱ្យមានផ្តួចផ្តើមបង្កើតគម្រោងវិនិយោគនានា ភាគច្រើនផ្តោតទៅលើដំណាំស្រូវ និងដំណាំចម្ការ ដូចជា គម្រោងបង្កើតកសិដ្ឋានកសិកម្ម ដើម្បីជំរុញផលិតកម្មដំណាំស្រូវ និងដំណាំចម្ការ គម្រោងវិនិយោគទៅលើការកែច្នៃផលិតផលកសិកម្មដើម្បីនាំចេញ ដែលនឹងផ្តល់ការងារបន្ថែមដល់ប្រជាពលរដ្ឋ ដើម្បីបង្កើនប្រាក់ចំណូលអោយបានកាន់តែខ្ពស់នាំឱ្យជីវភាពរស់នៅកាន់តែប្រសើរឡើង ព្រមទាំងជួយកាត់បន្ថយបាននូវភាពក្រីក្រស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។

## ២.៥. បញ្ហា មូលហេតុ និងដំណោះស្រាយ

បើផ្អែកតាមការរកឃើញនៅក្នុងជំពូកទី១នៃរបាយការណ៍នេះ អាចឱ្យយើងធ្វើការវិភាគនិងចងក្រងបាននូវបញ្ហាដែលកើតមាននៅក្នុងឃុំក្រយា មូលហេតុដែលនាំឱ្យកើតមានបញ្ហានិងដំណោះស្រាយលើបញ្ហាទាំងនេះ ដោយមានបង្ហាញអំពីទីតាំងដែលកើតមានបញ្ហានៅក្នុងតារាង ព្រមទាំងកំណត់បាននូវទីតាំងបញ្ហានៅក្នុងផែនទីទៀតផងដែរ ដូចមាននៅខាងក្រោមនេះ៖

តារាង 36៖ បញ្ហាប្រឈម និងសក្តានុពល(ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ)

| បញ្ហា | ទីតាំងបញ្ហា | មូលហេតុ | ដំណោះស្រាយ |
|---|---|---|---|
| ១.ទីតាំងលំនៅឋាន នៅលើដីសាធារណៈ របស់រដ្ឋ (លើស្ទឹង ប្រឡាយ...ចំនួន ៣៣២គ្រួសារ) | -គ្រប់ភូមិ | ក-រស់នៅតាំងពីដូនតាមក | ក-១-ស្រង់ស្ថិតិប្រជាជននៅលើដីសារធារៈរបស់រដ្ឋ<br>ក-២-នៅលើដីសារធារណៈរបស់រដ្ឋ<br>ក-៣-ផ្សព្វផ្សាយច្បាប់ភូមិបាល |
| | | ខ-ខ្វះខាតដីលំនៅឋាន | ខ-១- ដោះស្រាយដីសម្បទានសង្គមកិច្ច<br>ខ-២-បញ្ឈប់ការសាងសង់លំនៅឋានថ្មី |
| ២.ខ្វះដីកសិកម្ម(ចំនួន ៧៦០គ្រួសារ) | -គ្រប់ភូមិ | ក-លក់សងបំណុល | ក-ខ-គ-១-ស្នើសុំដីសម្បទានសង្គមកិច្ច<br>ក-ខ-គ-២-ផ្តល់បច្ចេកទេសកសិកម្មទំនើបៗ |
| | | ខ-កំណើនគ្រួសារក្នុងភូមិ | |
| | | គ-ដីកសិកម្មតិច | |
| ៣.កង្វះខាតទីលានទុកដាក់សំរាម ក្នុងឃុំ | -ក្នុងឃុំ | ក-ទុកដាក់សំរាមគ្មានសណ្តាប់ធ្នាប់ មិនមានទីតាំងសមរម្យ | ក-ខ-១-យល់ដឹងពីការបែងចែកសំរាម (ប្រភេទសំរាមនីមួយ)<br>ក-ខ-២-ជំរុញឱ្យក្រុមហ៊ុនវិនិយោគ ក្នុងការប្រមូលសំរាមកែច្នៃ<br>ក-ខ-៣-មន្ទីរ ឬក្រសួងពាក់ព័ន្ធ និងក្រុមប្រឹក្សាឃុំគួរបង្កើតឱ្យមានទីលានទុកដាក់សំរាមក្នុងឃុំ |
| | | ខ-ចោលសំរាមលើដីសារធារណៈរបស់រដ្ឋ | |
| ៤-ទិន្នផលស្រូវទាប<br> | -ដីស្រែវស្សា | ក-ដីខ្វះជីជាតិ | ក-១-បណ្តុះបណ្តាលផលិតជីកំប៉ុស្ត<br>ក-២-បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី<br>ក-៣-ជំរុញការចិញ្ចឹមសត្វដើម្បីបានលាមក |
| | | ខ-ខ្វះបច្ចេកទេសកសិកម្ម | ខ-១-បណ្តុះបណ្តាលពីបច្ចេកទេសផលិតពូជស្រូវ<br>ខ-២-បណ្តុះបណ្តាលពីការដាំដំណាំស្រូវ<br>ខ-៣-បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី<br>ខ-៤-បណ្តុះបណ្តាលបច្ចេកទេសផលិតជីកំប៉ុស្ត<br>ខ-៥-ប្រើប្រាស់ពូជស្រូវសុទ្ធល្អតាមស្តង់ដា |
| | -ភូមិដងក្តារ<br>-ភូមិក្រយា | ក-ប្រព័ន្ធធារាសាស្ត្ររងការខូចខាត | ក-១-ស្តារប្រឡាយឡើងវិញ<br>ក-២-ជួសជុល និងរៀបចំទ្វារទឹក |

| | | | |
|---|---|---|---|
| ៥-ខ្វះទឹកស្រោចស្រព (ស្ទឹង បឹង ប្រឡាយ...)  | -ភូមិសុភមង្គល<br>-ភូមិតាម៉ិញ<br>-ភូមិត្រពាំងព្រីង<br>-ភូមិឈើទាលជ្រុំ | ខ-ធ្វើស្រែក្នុងប្រឡាយ | ខ-១-ស្រង់ស្ថិតិអ្នកធ្វើស្រែក្នុងប្រឡាយ<br>ខ-២-ផ្សព្វផ្សាយពីច្បាប់ភូមិបាល និងច្បាប់ពាក់ព័ន្ធនានា។<br>ខ-៣-រកវិធីដោះស្រាយនិងធ្វើកិច្ចសន្យាបញ្ឈប់ |
| | | គ-ប្រើប្រាស់ប្រឡាយនៅជាប់ដីរបស់ខ្លួនផ្តាច់មុខ | គ- ១- ស្រង់ស្ថិតិប្រជាជនដែលប្រើប្រាស់ប្រឡាយផ្តាច់មុខ<br>គ-២-ផ្សព្វផ្សាយពីច្បាប់ភូមិបាល និងច្បាប់ពាក់ព័ន្ធ<br>គ-៣-រកវិធីដោះស្រាយនិងធ្វើកិច្ចសន្យាបញ្ឈប់<br>គ-៤-បង្កើតសហគមន៍ប្រើប្រាស់ទឹកដើម្បីបានទឹកក្នុងការស្រោចស្រពស្មើភាព |
| ៦-ផ្លូវរងការខូចខាតពិបាកធ្វើដំណើរ   | -ផ្លូវជាតិលេខ ២៦៤បេ និង លេខ២៧១៨<br>-ផ្លូវគ្រួសក្រហម | ក-ឡានធុនធ្ងន់ដឹកលើសទម្ងន់ឆ្លងកាត់ | ក-១-ពង្រឹងការអនុវត្តន៍ច្បាប់ចរាចរណ៍ ទប់ស្កាត់<br>ឡានដឹកលើសទម្ងន់តាមរយៈដាក់សញ្ញាកំណត់ទម្ងន់ដឹកជញ្ជូនរបស់រថយន្ត<br>ក-២-ដាក់បារាស់កាត់ផ្លូវដែលមានរថយន្តធំឆ្លងកាត់ |
| | | ខ-គ្មានប្រព័ន្ធលូគ្រប់គ្រាន់ | ខ-១-ដាក់លូបង្ហូរទឹកតាមមុខផ្ទះនៅជាប់ផ្លូវ |
| | | គ-ខ្វះការថែទាំផ្លូវ | គ-១- ថែទាំផ្លូវ ខួប ជាប្រចាំ<br>គ-២-បង្កើតគណៈកម្មការថែទាំផ្លូវ |
| ៧-ធនធានមច្ឆាថយចុះ និងបាត់បង់ | -ភូមិឈើទាលជ្រុំ<br>-ភូមិដងក្តារ<br>-ភូមិទក់<br>វភូមិត្រពាំងឫស្សី<br>-ភូមិក្រយា<br>-ភូមិថ្មសំលៀង<br>-ភូមិអូរទឹកថ្លា<br>-ភូមិសុភមង្គល<br>-ភូមិតាម៉ិញ<br>-ភូមិភ្នំប្រាច់<br>ភូមិសែនសិរីមង្គល<br>-ភូមិសូងសាង<br>-ភូមិត្រពាំងព្រីង | ក-នេសាទខុសច្បាប់ | ក-១ផ្សព្វផ្សាយច្បាប់ជលផល និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា<br>ក-២-ហាមឃាត់ការប្រើប្រាស់ឧបករណ៍ឆក់ខុសច្បាប់<br>ក-៣-ធ្វើវារីវប្បកម្ម |
| ៨-ខ្វះទឹកស្អាតប្រើប្រាស់ | -ក្នុងឃុំ | ក-គ្មានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត<br>ក-គ្មានស្រះទឹកគ្រប់គ្រាន់ | ក-១-គាំទ្រសេវាកម្មផ្គត់ផ្គង់ប្រព័ន្ធទឹកស្អាត<br>ក-១-ជីកស្រះទឹកបន្ថែម |

| | | | |
|---|---|---|---|
| | | ខ-គ្មានអណ្តូងស្នប់គ្រប់គ្រាន់ | ខ-១-ជីកអណ្តូងស្នប់បន្ថែម |
| | | គ-ប្រជាពលរដ្ឋមួយចំនួនខ្វះការសម្ភារៈបរិក្ខារទឹកស្អាត | គ-១-ផ្តល់ធុងចម្រោះទឹកស្អាត<br>គ-២-ដាំទឹកឆ្អិនមុននឹងបរិភោគ |
| ៩-ពិបាកឆ្លងស្ទឹង<br> | ភូមិសែនសិរីមង្គល | ក-គ្មានស្ពានឆ្លងស្ទឹង | ក-សាងសង់ស្ពានឆ្លងស្ទឹង |
| ១០.គ្រាប់មីននៅសេសសល់<br> | -ភូមិទក់<br>-ភូមិក្រយា | ក-ជាកន្លែងសមរភូមិប្រយុទ្ធ | ក-១-ដាក់សញ្ញាសម្គាល់ដីដែលមានមីន និងគ្រាប់មិនទាន់ផ្ទុះ<br>ក-២-ដាក់សំណើទៅអង្គភាពកំចាត់ មីនឬអង្គការដើម្បី ជួយអន្តរាគមន៍ |

ប្រភពទិន្នន័យៈ *សៀវភៅផែនអភិវឌ្ឍន៍០៥ឆ្នាំ និងក្រុមប្រឹក្សាឃុំក្រយា ឆ្នាំ២០១៨*

ផែនទី 11៖ ផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ



# ជំពូក ៣៖ ផែនការប្រើប្រាស់ដីសម្រាប់អនាគតឆ្នាំ២០១៧-២០៣២

## ៣.១. តម្រូវការ ស្ថានភាព និងសក្តានុពលដីជាក់ស្តែង

### ៣.១.១. តម្រូវការដីទៅតាមប្រភេទ

នាពេលអនាគតរហូតទៅដល់ឆ្នាំ២០៣២ នៅក្នុងឃុំក្រយា នឹងមានការកើនឡើងនូវចំនួនប្រជាពលរដ្ឋ ៤ ៣២០នាក់ ដែលត្រូវនឹងចំនួន ៩៩៥គ្រួសារ ។ ដោយសារសន្ទុះនៃកំណើនប្រជាពលរដ្ឋនេះហើយ ដែលតម្រូវឱ្យមានការគិតគូរយកចិត្តទុកដាក់ដល់ការរកដីបន្ថែម សម្រាប់លំនៅឋាន និងដីស្រែជូនដល់ប្រជាពលរដ្ឋ ដែលមានចំនួនកើនឡើង ដើម្បីធានាឱ្យមាននិរន្តរភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងឃុំក្រយា ទៅថ្ងៃអនាគតបន្តពីពេលបច្ចុប្បន្ន ដូចបានរកឃើញនៅក្នុងជំពូក២ខាងលើនៃរបាយការណ៍នេះ ។ តែដោយសារទំហំផ្ទៃដីដែលត្រូវបានប្រើប្រាស់បច្ចុប្បន្នក្នុងឃុំ ពុំមានប្រែប្រួលកើនឡើងស្របគ្នាទៅនឹងកំណើនប្រជាពលរដ្ឋនាពេលអនាគត ដើម្បីដោះស្រាយបានតាមតម្រូវការដីសម្រាប់លំនៅឋាន និងដីស្រែចម្ការបន្ថែមនោះ គឺជាដំណោះស្រាយសមស្របដីសម្រាប់លំនៅឋានត្រូវប្រើប្រាស់ដីលំនៅឋានភូមិ ដែលមានស្រាប់ ព្រោះស្ថានភាពការតាំងលំនៅឋានបច្ចុប្បន្ន មិនទាន់មានភាពចង្អៀត ដែលអាចមានលទ្ធភាពទ្រទ្រង់ទៅដល់ការសាងសង់លំនៅឋានបន្ថែមទៀតបាន សម្រាប់រយៈពេល១៥ឆ្នាំទៅមុខ ហើយម្យ៉ាងទៀតការតាំងលំនៅឋានមានលក្ខណៈប្រមូលផ្តុំ វានឹងផ្តល់ភាពងាយស្រួលដល់ការផ្គត់ផ្គង់ទឹកស្អាត ភ្លើង និងសេវាសង្គមផ្សេងៗទៀតដូចជាសេវាអប់រំ សេវាសុខភាពជាដើម។ល។

ដោយឡែកចំពោះដីស្រែវិញ ក៏មិនមានលទ្ធភាពពង្រីកបន្ថែមទៀតដែរ ដែលជាដំណោះស្រាយគឺ ត្រូវតែគិតគូរពិចារណាដោយយកចិត្តទុកដាក់ទៅលើការបង្កើនផលិតភាព គុណភាព និងពិពិធកម្មកសិកម្មដំណាំស្រូវ ដោយត្រូវធ្វើស្រែប្រាំងបង្កើនរដូវឱ្យបាន៣ដងក្នុងមួយឆ្នាំ និងធ្វើស្រែតាមបែបប្រពលវប្បកម្ម ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៃរាជរដ្ឋាភិបាលកម្ពុជា ។

### ៣.១.២.ស្ថានភាពនៃដីធ្លី និងសក្តានុពល

នាពេលអនាគតធនធានដីនៅក្នុងឃុំក្រយា នៅតែរក្សាទំហំក្រឡាផ្ទៃសរុបចំនួន ៨៨៥៨២,៥៩ហិកតា ដដែលដោយពុំមានការប្រែប្រួលឡើយ ហើយដីធ្លីទាំងនេះនឹងមានការប្រើប្រាស់សម្រាប់ការសាងសង់លំនៅឋាន (រួមទាំងហេដ្ឋារចនាសម្ព័ន្ធមួយចំនួននិងដំណាំជុំវិញលំនៅឋាន) ដីស្រែ (រួមទាំងប្រព័ន្ធធារាសាស្ត្រនឹងហេដ្ឋារចនា សម្ព័ន្ធមួយចំនួន) ដីចម្ការដំណាំ ដីព្រៃឈើ ដីស្មៅ បឹង និងស្រះ ដូចការប្រើប្រាស់ដីធ្លីបច្ចុប្បន្នដដែល ដោយពុំមានការប្រែប្រួលឡើយ ពីព្រោះដីធ្លី ដែលបានប្រើប្រាស់ក្នុងពេលបច្ចុប្បន្ននេះបានសមស្រប និងចំសក្តានុពលនៃដីរួចហើយ។ ចំណែកទំហំផ្ទៃដីតំបន់ប្រើប្រាស់នីមួយៗ ដូចមានរៀបរាប់ក្នុងសេចក្តីអត្ថាធិប្បាយអំពីការបែងចែកដីតាមតម្រូវការប្រើប្រាស់ខាងក្រោមនេះ។ ជាទូទៅធនធានដីនៅក្នុងឃុំក្រយាមាន សក្តានុពលខ្ពស់សមស្របទៅលើកសិកម្មដំណាំស្រូវ និងចម្ការដំណាំ ដោយសារដីនៅក្នុងឃុំមានទីតាំងភូមិសាស្ត្រ អំណោយផលពីធម្មជាតិដូចបានរៀបរាប់ក្នុងជំពូកទី២ខាងលើ ។ ដូច្នេះការប្រើប្រាស់ដីនាពេលបច្ចុប្បន្ន និងការសម្រេចចិត្តប្រើប្រាស់ដីទៅថ្ងៃអនាគតនៅក្នុងឃុំ ដែលបានផ្តោតសំខាន់ទៅលើកសិកម្មដំណាំស្រូវ និងចម្ការជាចម្បង គឺជាការប្រើប្រាស់ដ៏បានត្រឹមត្រូវចំសក្តានុពលនៃដី ហើយក៏ជាការគាប់ជួនដែលភាពអំណោយផលពីធនធានដី នៅក្នុងឃុំសមស្របទៅលើវិស័យកសិកម្មដំណាំស្រូវនិងចម្ការនេះ ក៏ស្របទៅនឹងគោលដៅដែលជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនៅក្នុងការពង្រឹងតួនាទីលើវិស័យកសិកម្ម នៅក្នុងការបង្កើតការងារ ការធានាសន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍជនបទដែលមានចែងនៅក្នុងមុំទី១ ចតុកោណទី៤ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់

រាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា ដែលជាការផ្តល់ឱកាសដ៏ល្អដល់អាចអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួនឱ្យឃុំមានការរីកចម្រើនបានតាមរយៈការជំរុញធ្វើពិពិធកម្មកសិកម្មដំណាំស្រូវ នៅលើផ្ទៃដីកសិកម្មដ៏ធំល្វឹងល្វើយស្ទើរតែពេញដែនដីឃុំទាំងមូល ដើម្បីបង្កើនទិន្នផលស្រូវ និងចម្ការ ដែលជាដំណាំដ៏មានសារៈសំខាន់សម្រាប់ជាស្បៀងផ្គត់ផ្គង់ការហូបចុកមិនអាចខ្វះបាននិងការនាំចេញទៅលក់នៅទីផ្សារ ដើម្បីបានចំណូលផ្គត់ផ្គង់តម្រូវការចាំបាច់ក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង រួមទាំងចូលរួមក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ តាមរយៈសកម្មភាពធ្វើពាណិជ្ជកម្មនាំអង្ករចេញ របស់រាជរដ្ឋាភិបាលកម្ពុជា ។

ចំណែកដីដែលមានទំហំតិចតួច ដែលបានកំណត់ជាការប្រើប្រាស់ដីសម្រាប់សាងសង់លំនៅឋាននៅលើដីខ្ពស់ជាប់តាមដងផ្លូវសំខាន់ៗ ដែលមិនលិចទឹកនៅរដូវវស្សា បានផ្តល់ភាពងាយស្រួលក្នុងការធ្វើដំណើរចេញ-ចូល និងងាយស្រួលក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត សម្រាប់បម្រើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងឃុំបានប្រកបដោយផាសុកភាព ព្រមទាំងដីប្រើប្រាស់សម្រាប់ប្រព័ន្ធធារាសាស្រ្ត និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត គឺជាការប្រើប្រាស់បានត្រឹមត្រូវផងដែរ ។

## ៣.២.ការបែងចែកដីទៅតាមតម្រូវការប្រើប្រាស់

### ៣.២.១.ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ

ជាទូទៅការកំណត់តំបន់ប្រើប្រាស់ដី ត្រូវបានផ្តោតសំខាន់ទៅលើមុខងារនៃការប្រើប្រាស់ដី សម្រាប់គោលបំណងផ្សេងៗដូចជា ផ្លូវ កសិកម្ម លំនៅឋាន ពាណិជ្ជកម្ម សួនកម្សាន្ត ព្រៃឈើ ។ល។ ទន្ទឹមនឹងនោះការប្រើប្រាស់ដីតែងតែមានការផ្លាស់ប្តូរមុខងាររបស់វា តែការផ្លាស់ប្តូរមុខងារប្រើប្រាស់ដីទាំងនេះត្រូវតែគិតគូរពិចារណាឱ្យបានហ្មត់ចត់ ដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវតាមស្ថានភាពច្បាប់ សេដ្ឋកិច្ច សង្គម និងបរិស្ថានហើយត្រូវតែប្រាកដថាដីដែលក្រោយពីបានប្តូរមុខងារប្រើប្រាស់ហើយនោះត្រូវតែមានតម្លៃសេដ្ឋកិច្ច ឬផលប្រយោជន៍ខ្ពស់ជាងមុខងារប្រើប្រាស់ដីពីមុន តាមរយៈការរក្សានូវជំហរច្បាស់លាស់ក្នុងការបង្កើនធនធានប្រើប្រាស់ប្រកបទៅដោយប្រសិទ្ធិភាពជាមួយនឹងផលប៉ះពាល់ដ៏តិចតួចបំផុត ចំពោះមនុស្សនៅជំនាន់ក្រោយ។ ឧទាហរណ៍ដូចជា៖ ការផ្លាស់ប្តូរពីប្រភេទដីព្រៃឈើរេចរិលទៅជាដីសម្រាប់កសិកម្មវានឹងនាំឱ្យមានការបាត់បង់បរិមាណដីព្រៃឈើ ដែលផ្តល់ប្រយោជន៍ច្រើនយ៉ាងដល់សហគមន៍មូលដ្ឋាន តែត្រូវបានកើតឡើងជំនួសដោយវាលស្រែសម្រាប់ផលិតកម្មស្រូវ ដែលជាចំណីអាហារសម្រាប់ជីវិតរស់នៅមិនអាចខ្វះបាន ដែលទាំងនេះជាការបង្ហាញឱ្យឃើញអំពីអន្តរអំពើរវាងមុខងារប្រើប្រាស់ដីមួយ ជាមួយនឹងមុខងារប្រើប្រាស់ដីមួយផ្សេងទៀតនៅលើទីតាំងដីដដែល។

យ៉ាងណាមិញនៅក្នុងរយៈពេល១៥ឆ្នាំ ខាងមុខរហូតដល់ឆ្នាំ២០៣២ ការប្រើប្រាស់ដីនៅក្នុងឃុំក្រយាត្រូវបានធ្វើការគិតគូរយ៉ាងយកចិត្តទុកដាក់ ដើម្បីដោះស្រាយនិងឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋ ដូចបានរៀបរាប់ខាងលើ ជាពិសេសគឺការដោះស្រាយក្នុងការបែងចែកការប្រើប្រាស់ដីធ្លី ដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋតាមគោលការណ៍របស់រាជរដ្ឋាភិបាល ដោយឈរលើស្មារតីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការប្រើប្រាស់ដីធ្លីនៅក្នុងរដ្ឋបាលឃុំ ។ បញ្ហាដែលត្រូវដោះស្រាយខាងលើនេះ យើងសង្កេតឃើញមានការដោះស្រាយដី សម្រាប់ការពង្រីកប្រព័ន្ធស្រោចស្រពតែប៉ុណ្ណោះ ហើយការដោះស្រាយនេះត្រូវបានសម្រេចចិត្តកំណត់យកទៅលើដីស្រែទៅតាមទីតាំងដែលសមស្របអាចមានលទ្ធភាពនាំទឹកទៅស្រោចស្រពលើផ្ទៃដីស្រែបានគ្រប់គ្រាន់ ដែលនឹងនាំឱ្យមានការប្រែប្រួលពីបរិមាណផ្ទៃដីស្រែមួយភាគតូច ទៅជាដីសម្រាប់ការរៀបចំធ្វើប្រព័ន្ធប្រឡាយស្រោចស្រព គឺមានន័យថា ៖ មានការថយចុះផ្ទៃដីស្រែដែលជាមូលដ្ឋាន ដ៏រឹងមាំនៃការអភិវឌ្ឍឃុំក្រយា

វានឹងនាំឱ្យមានការថយចុះផលិតផលស្រូវ ដែលនឹងនាំឱ្យមានការបាត់បង់ប្រាក់ចំណូល ប៉ះពាល់ទៅដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ តែបរិមាណនៃផ្ទៃដី សម្រាប់ស្រោចស្រពមានការកើនឡើង ដែលជាតម្រូវការចាំបាច់សម្រាប់ដោះស្រាយការស្រោចស្រពដំណាំកសិកម្មមិនអាចខ្វះបានដើម្បីធានាចីរភាពនៃផលិតកម្មកសិកម្មសម្រាប់ការអភិវឌ្ឍន៍ឃុំ ។

តារាង 37៖ តារាងប្រើប្រាស់ដីនាពេលអនាគតឃុំ ក្រយា

| ប្រភេទដីប្រើប្រាស់ (ឈ្មោះហៅតាមបច្ចេកទេស) | ផ្ទៃដីបច្ចុប្បន្ន (ហិកតា) | ផ្ទៃដី១៥ក្រោយ (ហិកតា) | បម្រែបម្រួល (ហិកតា) |
|---|---|---|---|
| **ក.ដីលំនៅឋាន** | **៧៣៤,៦២** | **៧៣៤,៦២** | **០០** |
| -ដីលំនៅឋាន ភូមិក្រៅគម្របព្រៃឈើឆ្នាំ២០០២ | ៥៣៨,៨១ | ៥៣៨,៨១ | ០០ |
| -ដីលំនៅឋាន ភូមិក្នុងគម្របព្រៃឈើឆ្នាំ២០០២ | ១៩៥,៨១ | ១៩៥,៨១ | ០០ |
| **ខ.ដីស្រែវស្សា** | **២ ៤៦៨,១** | **២ ៤៦៨,១** | **០០** |
| -ដីស្រែវស្សាក្រៅគម្របព្រៃឈើឆ្នាំ២០០២ | ២ ៤២៦,០៣ | ២ ៤២៦,០៣ | ០០ |
| -ដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ២០០២ | ៤២,០៧ | ៤២,០៧ | ០០ |
| **គ.ដីចម្ការ** | **៧៧ ៨៤៤,៧២** | **៧៧ ៨៤៤,៧២** | **០០** |
| -ដីចម្ការក្រៅគម្របព្រៃឈើឆ្នាំ២០០២ | ៨ ៧៣៨,៥៣ | ៨ ៧៣៨,៥៣ | ០០ |
| -ដីចម្ការក្នុងគម្របព្រៃឈើឆ្នាំ២០០២ | ៦៩ ១០៦,១៩ | ៦៩ ១០៦,១៩ | ០០ |
| **គ.ដីព្រៃ/គម្របព្រៃ** | **៧ ០៥៣,៥៧** | **៧ ០៥៣,៥៧** | **០០** |
| -ព្រៃល្បោះ | ៥ ៤៤១,៤៤ | ៥ ៤៤១,៤៤ | ០០ |
| -ព្រៃស្រោង | ១ ៦១២,១៣ | ១ ៦១២,១៣ | ០០ |
| **ឃ.ផ្ទៃទឹក និងខ្សែទឹក** | **៤៨១,៥៨** | **៤៨១,៥៨** | **០០** |
| -ស្ទឹងមានទឹកតាមរដូវ | ៤០៤,៣៤ | ៤០៤,៣៤ | ០០ |
| -ស្រះ | ២៨,៥៥ | ២៨,៥៥ | ០០ |
| -ស្រះក្នុងគម្របព្រៃឈើឆ្នាំ២០០២ | ២៩,៤៨ | ២៩,៤៨ | ០០ |
| -បឹងមានទឹកតាមរដូវ | ១៩,២១ | ១៩,២១ | ០០ |
| **ផ្ទៃដីឃុំសរុប** | **៨៨ ៥៨២,៥៩** | **៨៨ ៥៨២,៥៩** | **០០** |

តារាង 38៖ តារាងផែនការផ្នែកហេដ្ឋារចនាសម្ព័ន្ធនាពេលអនាគត

| ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ប្រវែង/ចំនួន ឆ្នាំ២០១៧(ម) | ប្រវែង/ ចំនួន ១៥ឆ្នាំ(ម) | បម្រែបម្រួល(ម) |
|---|---|---|---|
| ផ្លូវក្រាលកៅស៊ូ | ៤០ ៦០៦,៣៧ | ៤៩ ៥៨៤,៣៩ | ៨ ៩៧៨,០២ |
| ផ្លូវបេតុង | ០០ | ៥០ ២៩២,៦៩ | ៥០ ២៩២,៦៩ |
| ផ្លូវក្រាលគ្រួសក្រហម | ១០៩ ០៨៩,៣៩ | ៤៩ ៨១៨,៦៧ | -៥៩ ២៧០,៧២ |

| | | | |
|---|---|---|---|
| ផ្លូវលំដីស/រទេះ | ១៥៣ ១៦៨,១១ | ១៥៦ ០២៣,៤៦ | ២ ៨៥៥,៣៥ |
| ប្រឡាយមេ | ១៩ ២២០,៩៨ | ១៩ ២២០,៩៨ | ០០ |
| ប្រឡាយរង | ២ ៣២០,៥៥ | ៣ ៨០៧,៩៤ | ១ ៤៨៧,៣៩ |
| ប្រឡាយតូច | ៣ ០៤៦,២៤ | ៣ ០៤៦,២៤ | ០០ |

តារាង 39៖ តារាងផែនការផ្នែកសេវាកម្មនាពេលអនាគត

| ហេដ្ឋារចនាសម្ព័ន្ធ | ចំនួនក្នុងឆ្នាំ២០១៧ | ចំនួនសម្រាប់១៥ឆ្នាំក្រោយ | បម្រែបម្រួល |
|---|---|---|---|
| សាលាមតេយ្យ | ០០អគារ /០០បន្ទប់ | ៦អគារ /២៨ បន្ទប់ | ៦អគារ /២៨ បន្ទប់ |
| សាលាបឋមសិក្សា | ១២ អគារ/ ៦៥បន្ទប់ | ៩ អគារ/ ៥៣ បន្ទប់ | -៣ អគារ/ -១២ បន្ទប់ |
| សាលាអនុវិទ្យាល័យ | ១ អគារ/ ៥ បន្ទប់ | ៥ អគារ/ ៦០ បន្ទប់ | ៤ អគារ /៥៥ បន្ទប់ |
| សាលាវិទ្យាល័យ | ០០អគារ/ ០០បន្ទប់ | ៥អគារ/ ៥៦ បន្ទប់ | ៥អគារ/ ៥៦ បន្ទប់ |
| ប៉ុស្តិ៍សុខភាព | ១កន្លែង | ១កន្លែង | ០កន្លែង |
| មណ្ឌលសុខភាព | ០កន្លែង | ១កន្លែង | ១កន្លែង |

### ៣.២.២.ផែនទីប្រើប្រាស់ដីអនាគត

ការកំណត់ការប្រើប្រាស់ដីនាពេលអនាគតនៅក្នុងឃុំ គឺជាការសម្រេចចិត្តមួយដ៏ត្រឹមត្រូវបំផុត ដោយពឹងផ្អែកទាំងស្រុងទៅលើការវិភាគដីដ៏សមស្របមួយ តាមរយៈការវាយតម្លៃបែបសាមញ្ញទៅលើធនធានដី រយៈកម្ពស់ ទីជម្រាល ធនធានទឹក ការកាន់កាប់ដី និងសក្តានុពលនៃការប្រើប្រាស់ដីនៅក្នុងឃុំនេះនាពេលបច្ចុប្បន្ន ដោយយកផែនទីប្រើប្រាស់ដីបច្ចុប្បន្នធ្វើជាមូលដ្ឋានក្នុងការគិតពិចារណា ដូចមានរំលេចឱ្យឃើញនៅក្នុងតារាងទី៣៧ខាងលើនេះ ដោយមានភ្ជាប់នូវផែនទីប្រើប្រាស់ដីនាពេលអនាគតដូចខាងក្រោម ដែលសមស្របអាចទទួលយកបាន និងអាចប្រើប្រាស់មានប្រសិទ្ធិភាពតាមរយៈការបង្ហាញយ៉ាងពិស្តារពីជម្រើសដ៏ល្អ សម្រាប់ការប្រើប្រាស់ដីនាពេលអនាគតរបស់ឃុំនេះ ។ ទន្ទឹមនឹងនោះផែនទីប្រើប្រាស់ដីនាពេលអនាគត ខាងក្រោម ក៏មានការអត្ថាធិប្បាយលម្អិតទៅលើតំបន់ប្រើប្រាស់ដីនីមួយៗដែលបានកំណត់នៅលើផែនទីនេះផងដែរ ។

ផែនទី 12៖ ផែនទីប្រើប្រាស់ដីពេលអនាគត ឃុំក្រយា



### ៣.២.៣.សេចក្ដីអត្ថាធិប្បាយអំពីការប្រើប្រាស់ដីនាពេលអនាគត

ផ្អែកតាមផែនទីប្រើប្រាស់ដីអនាគតខាងលើ បានបង្ហាញឱ្យឃើញពីប្រភេទនៃការប្រើប្រាស់ដីនៅក្នុងឃុំក្រយា ដូចខាងក្រោម៖

#### ក. ដីលំនៅឋាន ភូមិ៖

ដីលំនៅឋាន ភូមិ គឺជាដីត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានមានលាយសួនដំណាំ និងឈើហូបផ្លែនៅជុំវិញ ។ នៅក្នុងឃុំក្រយា ដីលំនៅឋានភូមិ មានផ្ទៃដីសរុបទំហំ ៧៣៤,២៦ហិកតា ដែលភាគច្រើន ដែលស្ថិតនៅអមតាមដងផ្លូវជាតិលេខ២៦៤មួយផ្នែកធំ ដែលសព្វថ្ងៃជាផ្លូវគ្រួសក្រហមចេញពីឃុំកំពង់ថ្ម កាត់ចូលកណ្ដាលឃុំពីខាងត្បូងឆៀងលិចទៅខាងជើងឆៀងខាងកើតនៃឃុំឆ្ពោះទៅកាន់ឃុំទំរីងស្រុកសណ្ដាន់ មានភូមិទក់ ភូមិត្រពាំងព្រីង ភូមិតាម៉ិញ ភូមិសុភមង្គល ភូមិក្រយា ភូមិដងក្ដារ ភូមិឈើទាលជ្រុំ និងភូមិត្រពាំងឬស្សី និងមួយផ្នែកទៀតចេញពីផ្លូវជាតិ២៦៤ មានផ្លូវគ្រួសក្រហមមួយបត់មកខាងកើតឃុំត្រង់ភូមិក្រយា មានភូមិថ្មសំលៀង ភូមិអូរទឹកថ្លា និងភូមិបន្ទាយរងៀង និងមានភូមិពីរទៀតនៅតាមផ្លូវគ្រួសក្រហមមួយផ្សេងទៀតកាត់ទៅឆៀងខាងកើតនៃឃុំជាប់ព្រំប្រទល់ឃុំបឹងល្វា មានភូមិសូសាង និងភូមិភ្នំប្រាច់ ដែលមានផ្ទៃដីសរុបទំហំ ៧៣៤,២៦ហិកតា ។ ដីលំនៅឋានភូមិទាំងអស់ ជាតំបន់ទំនាបមធ្យម មានប្រភេទក្រុមដីប្រទះឡាង ក្រុមដីបាកាន ព្រៃខ្មែរ និងជាតំបន់ដីខ្ពស់មិនលិចទឹកនៅរដូវវស្សា ជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់ និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋផង និងរបស់រដ្ឋផង ដែលបច្ចុប្បន្នដីនេះត្រូវបានប្រើប្រាស់សម្រាប់ដីលំនៅឋានភូមិ ដោយពុំមានការពង្រីកបន្ថែមសម្រាប់ការដោះស្រាយទៅនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២នោះឡើយ ដោយសារបច្ចុប្បន្ននេះដីលំនៅឋានភូមិនៅមានភាពទូលាយ ដែលអាចធ្វើការដោះស្រាយសម្រាប់ការសាងសង់លំនៅឋានរហូតដល់ឆ្នាំ ២០៣២ បាន។ ដីដែលបានកំណត់ជាដីភូមិនេះ ពឹងផ្អែកលើប្រភពទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ និងស្រោចស្រពដំណាំរួមផ្សំជុំវិញលំនៅឋានបានមកពីទឹកភ្លៀង ស្ទឹងជីនិត ស្ទឹងតាំងក្រសាំង អណ្ដូងស្នប់ បឹងនិង ស្រះ ហើយត្រូវនាំទឹកមកប្រើប្រាស់ដោយម៉ូទ័របូម និងស្នប់សប់ដៃ ។ នាពេលអនាគតទីតាំងដីលំនៅឋាន ភូមិ ដែលមានស្រាប់នាពេលបច្ចុប្បន្ននេះនឹងត្រូវរក្សាទុកជាដីសម្រាប់សាងសង់លំនៅឋានដដែល ដោយសារទីតាំងដីនេះមានស្ថានភាពជាដីខ្ពស់មិនលិចទឹកនៅរដូវវស្សា និងនៅជាប់ផ្លូវសំខាន់ៗ ក្នុងឃុំងាយស្រួលក្នុងការចេញចូលប្រកបរបររកស៊ីរបស់ប្រជាពលរដ្ឋដែលសមស្របសម្រាប់ការតាំងលំនៅឋាន ជាជម្រកដ៏កក់ក្ដៅសម្រាប់ជីវិតរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ។ បើផ្អែកតាមកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២ ដែលនឹងមានប្រជាជនកើនឡើងរហូតដល់ ៤ ៣៨២ គ្រួសារ និងដីលំនៅឋានមិនមានការប្រែប្រួលកើនឡើងដូចរៀបរាបខាងលើ គឺនៅរក្សាទំហំ ៧៣៤,៦២ហិកតា ដូច្នេះទៅថ្ងៃអនាគត១៥ឆ្នាំខាងមុខការប្រើប្រាស់ដីលំនៅឋាននឹងមានទំហំ ០,១៧ ហិកតា/គ្រួសារ ដែលប្រហាក់ប្រហែលនិងដីប្រើប្រាស់ដីលំនៅឋាននាពេលបច្ចុប្បន្នដែរ គឺចំនួន ០,២២ហិកតា/គ្រួសារ ។

-ទំហំដីលំនៅឋានជាមធ្យមសម្រាប់មួយគ្រួសារ១៥ឆ្នាំខាងមុខ =

**៧៣៤,៦២ហិកតា/៤ ៣៨២គ្រួសារ=០,១៧ហិកតា**

#### ខ. ដីស្រែវស្សា

នៅក្នុងឃុំក្រយា ដីស្រែវស្សាមានភាគច្រើន ស្ថិតនៅប៉ែកត្បូងនៅជាប់សងខាងផ្លូវជាតិលេខ២៦៤រហូតដល់ចំណុចផ្លូវភូមិតាម៉ិញ ជាដីស្រែវស្សាក្រៅគម្របព្រៃឈើឆ្នាំ២០០២ ដែលបច្ចុប្បន្នត្រូវបាននឹងកំពុងប្រើប្រាស់ជាដីស្រែវស្សាមានទំហំផ្ទៃដី ២៤២៦ហិកតា និងមានមួយភាគទៀតជាចំនួនតិចតួច ស្ថិតនៅបន្តចាប់ពីភូមិតាម៉ិញ

រហូតដល់ផ្លូវកែងត្រង់ភូមិក្រយា ជាដីស្រែវស្សាស្ថិតក្នុងគម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ៤២ហិកតា ដែលបច្ចុប្បន្នត្រូវបាននឹងកំពុងប្រើប្រាស់ជាដីស្រែវស្សា ។ ដីដែលបានកំណត់ជាដីស្រែវស្សាទាំងអស់ខាងលើ ជាតំបន់ទំនាបមធ្យម និងមានប្រភេទក្រុមដីប្រទះឡាង ក្រុមដីបាកាន និងព្រៃខ្មែរ ដែលជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់ប្រើប្រាស់ដោយប្រជាពលរដ្ឋផង និងរបស់រដ្ឋផង។ ដីស្រែវស្សាទាំងនេះពឹងផ្អែកទៅលើប្រភពទឹកសម្រាប់ការស្រោចស្រពពីទឹកភ្លៀង ស្ទឹងជីនិត ស្ទឹងតាំងក្រសាំង បឹង និងស្រះទឹក ដែលមានទំនប់បង្ហៀរស្ពាក់ទឹកស្ទឹងជីនិតដែលនាំទឹកពីភាគខាងជើងមកស្រោចស្រពតាមរយៈប្រឡាយមេមួយខ្សែ ព្រមទាំង បឹងធម្មជាតិ និងស្រះ ហើយដីស្រែវស្សាដែលនៅក្បែរដីលំនៅឋាន ភូមិ ក៏អាចដាំដំណាំរួមផ្សំផងដែរដូចជា ពោត សណ្តែក ឪឡឹក និងបន្លែគ្រប់មុខផ្សេងៗទៀតជាដើម ក្រោយពីច្រូតកាត់ស្រូវរួច ។ នាពេលអនាគតទីតាំងដីនេះ នឹងត្រូវរក្សាទុកជាដីស្រែដូចបច្ចុប្បន្នដដែល ដោយសារទីតាំងដីនេះមានស្ថានភាពជាដីទាបលិចទឹកនៅរដូវវស្សា សមស្របសម្រាប់ដំណាំស្រូវសម្រាប់ផ្គត់ផ្គង់ការហូបចុកសម្រាប់ជីវិតរស់របស់មនុស្ស និងនៅសល់លក់ទៅទីផ្សារក្នុងនិងក្រៅដើម្បីបង្កើនប្រាក់ចំណូលជាតិ និងគ្រួសារ ។

**-ដីស្រែវស្សាក្រៅគម្របព្រៃឈើឆ្នាំ២០០២**

នៅក្នុងឃុំក្រយា មានដីស្រែវស្សាក្រៅគម្របព្រៃឈើឆ្នាំ ២០០២ មានផ្ទៃដីទំហំចំនួន ២ ៤២៦ ហិកតា ដែលមាន នៅសងផ្លូវជាតិលេខ២៦៤ (ហៅផ្លូវក្រយា) ចាប់ពីព្រំប្រទល់ឃុំកំពង់ថ្មស្ថិតនៅត្រង់ភូមិទក់ រហូតដល់ភូមិតាម៉ិញទៅខាងជើងនៃឃុំ ។ ដីស្រែវស្សាក្រៅគម្របព្រៃឈើឆ្នាំ ២០០២ ជាតំបន់ទំនាបមធ្យម មានប្រភេទដីខ្សាច់សុទ្ធពណ៌ស និងដីខ្សាច់លាយពណ៌ប្រផេះ ជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់និងប្រើប្រាស់ជារបស់ប្រជាពលរដ្ឋ ដែលបច្ចុប្បន្ននេះត្រូវបាននឹងកំពុងប្រើប្រាស់ដោយប្រជាពលរដ្ឋជាដីស្រែវស្សា ដែលមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ស្ទឹងជីនិត ស្ទឹងតាំងក្រសាំង បឹង និងស្រះទឹក ។ នាពេលអនាគតទីតាំងដីទាំងនេះ នឹងត្រូវរក្សាទុកជាដីស្រែវស្សាដូចបច្ចុប្បន្នដដែល ដោយសារទីតាំងដីទាំងនេះមានស្ថានភាពជាដីទាបលិចទឹកនៅក្នុងរដូវវស្សាសមស្របសម្រាប់ដំណាំស្រូវ ដែលផ្តល់ផលផ្គត់ផ្គង់ការហូបចុក សម្រាប់ជីវិតរស់របស់មនុស្ស និងនៅសល់លក់ទៅទីផ្សារក្នុងនិងក្រៅដើម្បីបង្កើនប្រាក់ចំណូលជាតិ និងគ្រួសារ ។

**-ដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ២០០២**

នៅក្នុងឃុំក្រយា មានដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ ២០០២ ទំហំផ្ទៃដីចំនួន ៤២ហិកតា ស្ថិតនៅខាងកើតផ្លូវជាតិលេខ២៦៤(ហៅផ្លូវក្រយា) ត្រង់ភូមិតាម៉ិញរហូតដល់ភូមិក្រយាទៅខាងជើងនៃឃុំ ។ ដីស្រែវស្សាក្នុងគម្របព្រៃឆ្នាំ ២០០២ ជាតំបន់ទំនាបមធ្យម មានប្រភេទដីខ្សាច់សុទ្ធពណ៌ស និងដីខ្សាច់លាយពណ៌ប្រផេះ ជាដីសាធារណៈរបស់រដ្ឋ ដែលបច្ចុប្បន្ននេះត្រូវបាននឹងកំពុងប្រើប្រាស់ដោយប្រជាពលរដ្ឋ មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ស្ទឹងជីនិត ស្ទឹងតាំងក្រសាំង បឹង និងស្រះទឹក ។ នាពេលអនាគតទីតាំងដីទាំងនេះ នឹងត្រូវរក្សាទុកជាដីស្រែវស្សាដូចបច្ចុប្បន្នដដែល ដោយសារទីតាំងដីនេះមានស្ថានភាពជាដីទាបលិចទឹកនៅក្នុងរដូវវស្សាសមស្របសម្រាប់ដំណាំស្រូវ ដែលផ្តល់ផលផ្គត់ផ្គង់ការហូបចុក សម្រាប់ជីវិតរស់របស់មនុស្ស និងនៅសល់លក់ទៅទីផ្សារនៅក្នុងនិងក្រៅដើម្បីបង្កើនប្រាក់ចំណូលជាតិនិងគ្រួសារ ប៉ុន្តែនាពេលអនាគតនឹងត្រូវរក្សាទុកជាដីគម្របព្រៃឈើវិញដដែល ប្រសិនបើមិនត្រូវបានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យប្រជាពលរដ្ឋមានសិទ្ធិកាន់កាប់ប្រើប្រាស់តាមរយៈការស្នើសុំពីអាជ្ញាធរដែនដីទេនោះ។

### គ. ដីចម្ការ

នៅក្នុងឃុំក្រយា ដីដែលបានកំណត់ការប្រើប្រាស់ សម្រាប់ដំណាំចម្ការដែលផ្តោតសំខាន់ទៅលើដំណាំឧស្សាហកម្ម នាពេលអនាគតមានផ្ទៃដីសរុបទំហំ ៧៧ ៨៤៤,៧២ ហិកតា ដែលបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាដីចម្ការដំណាំស្វាយចន្ទីភាគច្រើន និងដំណាំកៅស៊ូ ដែលមានផ្ទៃដីស្ទើរប្រហាក់ប្រហែលគ្នា ដោយមានដីចម្ការភាគច្រើនស្ថិតក្នុងដីគម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ៦៩ ១០៦,១៩ហិកតា នៅពាសពេញផ្ទៃដីក្នុងឃុំស្ទើរតែគ្រប់ទីកន្លែង ចំណែកដីចម្ការក្រៅគម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ៨ ៧៣៨,៥៣ ហិកតា ស្ថិតនៅក្បែរដីលំនៅឋានភូមិ និងនៅតាមជាយៗព្រំប្រទល់ផ្នែកខាងត្បូងនៃឃុំ ហើយមានស្ថានភាពជាដីខ្ពង់រាបទាប និងមធ្យមមានប្រភេទក្រុមបាកាន ក្រុមដីប្រទះឡាង និង ក្រុមដីគោកគ្រប់ ព្រមទាំងពឹងផ្អែកលើប្រភពទឹកស្រោចស្រពពីទឹកភ្លៀងប៉ុណ្ណោះ។ នាពេលអនាគតទីតាំងដីនេះ នឹងត្រូវរក្សាទុកជាដីចម្ការដដែល ដោយសារដីនេះមានស្ថានភាពជាដីខ្ពង់រាបដែលសមស្របសម្រាប់ដំណាំចម្ការឧស្សាហកម្មទទួលបានផលិតផលផ្គត់ផ្គង់សម្រាប់ការនាំចេញទៅរកទីផ្សារ ដែលជាការប្រសើរជាងនេះទៀតនោះ ផលិតផលទាំងនេះត្រូវធ្វើការកែច្នៃមុននឹងនាំចេញទៅរកទីផ្សារដែលនាំឱ្យឃុំក្រយា មានមូលដ្ឋានគ្រឹះកាន់តែរឹងមាំក្នុងការអភិវឌ្ឍន៍ក្នុងឃុំខ្លួនឯងថែមទៀត ជាពិសេសនឹងនាំឱ្យកើនឡើងប្រាក់ចំណូលក្នុងគ្រួសារ ក៏ដូចជាបានចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ ដីចម្ការនាពេលអនាគតមានស្ថានភាពនៃការកាន់កាប់ទៅតាម២តំបន់ផ្សេងគ្នាដូចខាងក្រោម៖

-**ដីចម្ការក្រៅគម្របព្រៃឈើឆ្នាំ២០០២** ៖ ស្ថិតនៅក្បែរដីលំនៅឋានភូមិ និងនៅតាមជាយៗព្រំប្រទល់ឃុំភាគខាងត្បូង និងមានផ្ទៃដីទំហំ ៨ ៧៣៨,៥៣ ហិកតា ជាដីកម្មសិទ្ធិឯកជនត្រូវបានកាន់កាប់និងប្រើប្រាស់ដោយប្រជាពលរដ្ឋ ។

-**ដីចម្ការក្នុងគម្របព្រៃឈើឆ្នាំ២០០២** ៖ ស្ថិតនៅស្ទើរតែពាសពេញផ្ទៃដីឃុំទាំងមូល ដែលមានទំហំផ្ទៃដី ១៩ ១០៦,១៩ ហិកតា ជាដីសាធារណៈរបស់រដ្ឋ ត្រូវបានប្រជាពលរដ្ឋប្រើប្រាស់ធ្វើជាចម្ការ ដោយអន្លើៗលាយជាមួយព្រៃឈើ ដែលទៅថ្ងៃអនាគត អាជ្ញាធរដែលពាក់ព័ន្ធត្រូវស្នើសុំការអនុញ្ញាតអនុប្បយោគពីរាជរដ្ឋាភិបាលជូនទៅប្រជាពលរដ្ឋ ដើម្បីជានាសុវត្ថិភាពកាន់កាប់ជាកម្មសិទ្ធិផ្ទាល់ខ្លួនបាន បើពុំមានការអនុញ្ញាតអនុប្បយោគពីរាជរដ្ឋាភិបាលទេនោះ ដីនេះនឹងត្រូវប្រើប្រាស់ជាដីព្រៃឈើ ដែលហាមប្រើប្រាស់មុខងារក្រៅពីរក្សាទុកជាដីគម្របព្រៃឈើឡើងវិញ ។

### ឃ. ព្រៃល្បោះ

នៅក្នុងឃុំក្រយា ដីដែលបានកំណត់ជាដីព្រៃល្បោះ មានផ្ទៃដីទំហំ ៥ ៤៤១,៤៤ ហិកតា ដែលបច្ចុប្បន្នជាក់ស្តែងជាព្រៃសហគមន៍មានប្រភេទឈើដូចជា ព្រៃខ្លុង ត្បែង និងដើមឈើចម្រុះ ។ ដីព្រៃល្បោះនេះស្ថិតនៅខាងលិចផ្លូវជាតិលេខ២៦៤ ។ ព្រៃល្បោះនេះសម្បូរទៅដោយ ខ្លុង ត្បែង ត្រសេក ចំបក់ រាំង គ្រើល ។ល។ ដែលជាដីកម្មសិទ្ធិឯកជនរបស់រដ្ឋ ដែលគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ និងឃុំក្រយា ដែលត្រូវបានថែទាំ និងដាំកូនឈើរក្សាការពារទុកជា តំបន់បៃតង ដើម្បីឱ្យមានលំនឹងបរិស្ថាន ដូចជា ជួយផ្តល់ឧស្ម័នអុកស៊ីសែន ដល់មនុស្ស និងស្រូបយកឧស្ម័នកាបូនិក ជាជម្រកសត្វព្រៃ ផ្តល់ខ្យល់អាកាសបរិសុទ្ធ ជួយទប់ទល់ខ្យល់ព្យុះ និងទឹកជំនន់ ជួយទាក់ទាញទឹកភ្លៀង ជួយរក្សាលំនឹងអាកាសធាតុ។ល។ ដីព្រៃល្បោះនេះ ទៅថ្ងៃអនាគត នឹងត្រូវរក្សាទុកជាដីព្រៃល្បោះដដែល ដោយបង្កើតជាសហគមន៍ព្រៃឈើ ដើម្បីការពារ ថែរក្សាទុក សម្រាប់ប្រើប្រាស់ក្នុងការរស់នៅរបស់ប្រជាពលរដ្ឋ និងជាជម្រកសត្វព្រៃគ្រប់ប្រភេទ រួមទាំងរក្សាបានប្រព័ន្ធជីវចម្រុះក្នុងតំបន់ រួមទាំងជួយកាត់បន្ថយការហូរច្រោះ និងផ្តល់ជីជាតិដល់ដី ។

ង. ព្រៃស្រោង

នៅក្នុងឃុំក្រយា ដីដែលបានកំណត់ជាដីព្រៃស្រោងមានផ្ទៃដីទំហំ ១ ៦១២,១៣ ហិកតា គឺជាដីត្រូវបាន និងកំពុងប្រើប្រាស់សម្រាប់ព្រៃស្រោង ដែលមានសម្បូរទៅដោយ ដើមចំបក់ កកោះ ក្រាយ ធ្នង់ ញ៉ូង បេង និង នាងនួន ជាច្រើនដុះលាយឡំចម្រុះគ្នា ។ ដីព្រៃស្រោងនេះ ជាដីសាធារណៈរបស់រដ្ឋដែលគ្រប់គ្រងកាន់កាប់ដោយ រដ្ឋបាលព្រៃឈើ និងមានការចូលរួមការពារ និងថែទាំពីប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។ ដីព្រៃសោងនេះ ស្ថិតនៅ ភាគខាងជើងនៃឃុំជាប់ព្រំប្រទល់ជាមួយនឹងឃុំទំរីង ស្រុកសណ្ដាន់ ជាតំបន់ខ្ពង់រាបមធ្យម ដែលមានប្រភេទក្រុម ដីប្រទះឡាង និងក្រុមដីបាកាន ។ នាពេលអនាគតទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីព្រៃដដែល ដើម្បីរក្សាទុក ប្រើប្រាស់រៀបចំជាតំបន់សហគមន៍ទេសចរណ៍ធម្មជាតិ និងផ្តល់ឈើសម្រាប់ប្រើប្រាស់ផ្សេងៗ រក្សាទុកដើម ឈើកម្រសម្រាប់មនុស្សនៅជំនាន់ក្រោយ ធ្វើឱ្យដីនៅក្នុងតំបន់នោះមានជីជាតិ ជួយផ្តល់ឧស្ម័នអុកស៊ីសែនដល់ មនុស្ស និងស្រូបយកឧស្ម័នកាបូនិក ជាជម្រកសត្វព្រៃ ផ្តល់ខ្យល់អាកាសបរិសុទ្ធ ជួយទប់ទល់ខ្យល់ព្យុះ និងទឹក ជំនន់ ជួយទាក់ទាញទឹកភ្លៀង និងជួយរក្សាលំនឹងអាកាសធាតុ។ល។

ច. ស្ទឹងមានទឹកតាមរដូវ

ស្ទឹងមានទឹកតាមរដូវនាបច្ចុប្បន្ននេះមានស្ទឹងជិនិត និងស្ទឹងតាំងក្រសាំង ដែលជាប្រភពទឹកស្រោចស្រព យ៉ាងសំខាន់នៅក្នុងឃុំ សម្បូរទៅដោយមច្ឆាជាតិជាច្រើន ។ ស្ទឹងទាំងនេះ ជាដីសាធារណៈរបស់រដ្ឋ មានទំហំផ្ទៃ ដីចំនួន ៤០៤,៣៤ ហិកតា ដែលស្ទឹងជីនិតមានស្ថានភាពពត់ពែនបត់បែនស្ថិតនៅប៉ែកខាងលិចឆៀងខាងត្បូង នៃឃុំ និងស្ទឹងតាំងក្រសាំង ស្ថិតប៉ែកខាងត្បូងនៃឃុំសណ្តូកតាមព្រំប្រទល់ផ្នែកខាងត្បូងរហូតដល់ភាគខាងកើត នៃឃុំជាប់ជាមួយឃុំបាត់ស្នា។ នាពេលអនាគតស្ទឹងទាំងពីរនេះជាប្រភពទឹកស្រោចស្រពនិងប្រើប្រាស់ក្នុងជីវភាព ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋព្រមទាំងជាប្រភពធនធានជលផលសម្រាប់ជាអាហារផ្តល់ប្រូតេអ៊ីនជាប្រយោជន៍យ៉ាង សំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ។

ឆ. ស្រះ

ស្រះបច្ចុប្បន្នជាដីស្រះជីកមានជាច្រើនកន្លែងដែលមានផ្ទៃដីទំហំ ២៨,៥៥ ហិកតា ជាស្រះទឹកស្ថិតនៅ ក្រៅតំបន់គម្របព្រៃឈើឆ្នាំ២០០២ ដែលនៅក្បែរដីលំនៅឋានភូមិ និងនៅតាមវាលស្រែវស្សាខ្លះ ហើយស្រះទឹក ស្ថិតក្នុងគម្របព្រៃឈើឆ្នាំ២០០២ មានផ្ទៃដីទំហំ ២៩,៤៨ ហិកតា ស្ថិតនៅភាគកណ្តាលនៃឃុំមួយចំនួន និងនៅ ក្នុងដីចម្ការមួយចំនួន បច្ចុប្បន្នស្រះទាំងនេះ ត្រូវបានប្រើប្រាស់ជាប្រភពទឹកស្រោចស្រព និងមានសំបូរទៅដោយ មច្ឆាជាតិ។ ស្រះទាំងនេះ ដែលស្ថិតក្នុងគម្របព្រៃឈើឆ្នាំ២០០២ ជាដីសាធារណៈរបស់រដ្ឋ និងក្រៅពីនោះជាដី កម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋ ។ នាពេលអនាគតស្រះនេះនឹងនៅតែជាប្រភពទឹកស្រោចស្រព និង ប្រើប្រាស់ ច្រើនយ៉ាងនៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែលព្រមទាំងជាប្រភពធនធានជលផលសម្រាប់ជាអាហារ ផ្តល់ប្រូតេអ៊ីនជាប្រយោជន៍យ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ។

ជ. បឹង

បឹងបច្ចុប្បន្ន ជាបឹងធម្មជាតិ ស្ថិតនៅកន្លែងក្នុងឃុំ មានផ្ទៃដីទំហំ ១៩,២១ហិកតា ដែលត្រូវបានប្រើប្រាស់ ជាប្រភពទឹកស្រោចស្រព និងមានសំបូរទៅដោយធនធានជលផល។ ដីបឹងទាំងនេះ គឺជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅភាគខាងត្បូងនៃឃុំ មានស្ថានភាព គឺជាដីទំនាបទាបងាយលិចទឹកនៅរដូវវស្សាមានប្រភេទដីប្រទះឡាង

ក្រុមដីបាកាន និងក្រុមដីព្រៃខ្មែរ ។ នាពេលអនាគតដីបឹងនេះនឹងនៅតែជាប្រភពទឹកស្រោចស្រព និង ប្រើប្រាស់ច្រើនយ៉ាងនៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែលព្រមទាំងជាប្រភពធនធានជលផលសម្រាប់ជាអាហារផ្តល់ប្រូតេអ៊ីនជាប្រយោជន៍យ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ។

## ៣.៣. ដំណោះស្រាយផ្សេងៗ ក្នុងករណីខ្វះខាតដីធ្លី

ជាការពិត បច្ចុប្បន្នយើងបានរកឃើញថា នៅក្នុងឃុំក្រយាមានប្រជាពលរដ្ឋក្រីក្រខ្វះខាតដីលំនៅឋានចំនួន ៣៣២ គ្រួសារ និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារពិតប្រាកដចំនួន ៧៦០គ្រួសារ ដូចដែលបានអធិប្បាយនៅក្នុងជំពូកទី១នៃរបាយការណ៍នេះ ដែលប្រជាពលរដ្ឋមួយចំនួនកំពុងរស់នៅលើចិញ្ចើមផ្លូវ លើដីចំណីប្រឡាយ និងដីចំណីស្ទឹង និងមួយចំនួនទៀតរស់នៅក្នុងខ្ទមលើដីរបស់អ្នកដទៃ ដែលពួកគាត់កំពុងស៊ីឈ្នួលឱ្យគេដើម្បីចិញ្ចឹមជីវិត។ ដូច្នេះដើម្បីដោះស្រាយដីសម្រាប់សាងសង់លំនៅឋាននិងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ដែលអាចផ្តល់ឱកាសឱ្យពួកគាត់មានជម្រករស់នៅសមរម្យ និងបង្កើតឱកាសការងារដើម្បីទទួលបានប្រាក់ចំណូលជូនពួកគាត់បាន អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ត្រូវខិតខំដោះស្រាយ តាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ចនៅថ្នាក់ក្រោមជាតិ ដែលត្រូវផ្តួចផ្តើមឡើងដោយក្រុមប្រឹក្សាឃុំក្រយា។ ដីធ្លីដែលត្រូវដោះស្រាយជូនពួកគាត់ដូចបានធ្វើការវិភាគដោះស្រាយនៅក្នុងជំពូក២ត្រង់ចំណុច២.១.៣ ខាងលើ ដីសម្រាប់លំនៅឋានទំហំ ៨៣ហិកតា និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ មានទំហំ ១ ៥២០ហិកតា ។

## ៣.៤. កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព

និរន្តរភាពនៃការប្រើប្រាស់ដី ជាការធានាឱ្យបាននូវគោលដៅ និងអត្ថប្រយោជន៍នៃការប្រើប្រាស់ដីទាំងនោះ ហើយការធានាទាំងនេះ ត្រូវកើតមានឡើងជាបន្តបន្ទាប់ជារៀងរហូត ដោយពុំមានឈប់ឈរ។ និរន្តរភាពជាចំណុចស្នូលសម្រាប់ការប្រើប្រាស់ដីនៅគ្រប់តំបន់គោលដៅទាំងអស់ តាមរយៈការកំណត់កត្តាចាំបាច់នានាសម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធភាព និងធានាឱ្យមាននិរន្តរភាព ។

### ៣.៤.១.កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព

ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ព្រមទាំងថែរក្សាការពារបរិស្ថាន និងធនធានធម្មជាតិប្រកបដោយចីរភាព ។ ដោយធាធានបានការផ្គត់ផ្គង់សេចក្តីត្រូវការ និងការទទួលខុសត្រូវចំពោះផលប្រយោជន៍របស់ប្រជាពលរដ្ឋនាពេលបច្ចុប្បន្ននិងបន្តដល់កូនចៅរបស់ពួកគាត់ទៅជំនាន់ក្រោយទៀត ត្រូវតែយកចិត្តទុកដាក់ដល់ការគ្រប់គ្រងទៅលើការប្រើប្រាស់សេវាកម្ម លើវិស័យទាំងអស់នៅក្នុងឃុំដែលបានកំណត់រួច តាមរយៈការខិតខំប្រឹងប្រែងអនុវត្តឱ្យសម្រេចបានទៅលើកត្តាចាំបាច់មួយចំនួនដូចខាងក្រោម៖

#### ក. ការគ្រប់គ្រងប្រព័ន្ធកសិកម្ម

បើពិនិត្យទៅលើលក្ខណៈភូមិសាស្ត្រ និងសក្តានុពលនៃធនធានដែលមាននៅក្នុងឃុំក្រយា ដែលក្រុមការងារបានធ្វើការសិក្សាស្រាវជ្រាវរកឃើញ បានកំណត់យ៉ាងច្បាស់ថា ឃុំមានគោលដៅអភិវឌ្ឍទៅថ្ងៃអនាគតពឹងផ្អែកទៅលើវិស័យកសិកម្មជាចម្បង ដែលនៅក្នុងនោះបានផ្តោតសំខាន់ទៅលើដំណាំស្រូវ និងចម្ការដំណាំឧស្សាហកម្ម។ ដូចនេះឃុំក្រយានឹងមានតួនាទីសំខាន់មួយនៅក្នុងការធ្វើឱ្យសម្រេចបាននូវគោលនយោបាយជំរុញផលិតកម្មស្រូវ និងនាំចេញអង្ករបស់រាជរដ្ឋាភិបាល ដែលត្រូវចាំបាច់ទាមទារឱ្យមានការគ្រប់គ្រងប្រព័ន្ធកសិកម្មនៅក្នុងមូលដ្ឋានឱ្យបានរឹងមាំ និងមាននិរន្តរភាពទៅថ្ងៃអនាគត ដោយត្រូវយកចិត្តទុកដាក់ជំរុញផលិតកម្មស្រូវ និង

ដំណាំឧស្សាហកម្ម ដើម្បីបង្កើនទិន្នផលស្រូវ និងដំណាំឧស្សាហកម្មឱ្យបានខ្ពស់អស់សក្តានុពល ដើម្បីអាចមានលទ្ធភាពនាំស្រូវចេញបានច្រើនសល់ពីការហូបចុក ឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋ និងអាចមានលទ្ធភាពនាំផលិតផលដំណាំឧស្សាហកម្មចេញផងដែរ ។

ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍឃុំក្រយាដូចខាងលើត្រូវមានការគ្រប់គ្រងដីស្រែនិងដីចម្ការនៅក្នុងឃុំឱ្យបានច្បាស់លាស់ ដោយរាល់ការសម្រេចចិត្តផ្លាស់ប្តូរមុខងារប្រើប្រាស់ដីពីកសិកម្មទៅបម្រើឱ្យការសាងសង់ និងបម្រើឱ្យការប្រើប្រាស់ផ្សេងទៀតត្រូវមានការចូលរួមពីប្រជាពលរដ្ឋនិងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ប្រកបដោយតម្លាភាព ដោយអនុលោមតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងត្រូវមានការផ្សព្វផ្សាយជាសាធារណៈ។ ទន្ទឹមនឹងការគ្រប់គ្រងដីស្រែ ត្រូវគិតគូរពីទឹកស្រោចស្រព ដោយធ្វើយ៉ាងណាអាចធ្វើស្រែបង្កើនរដូវ ស្រែប្រាំងឱ្យបានបីដងក្នុងមួយឆ្នាំតាមរយៈការស្តារប្រព័ន្ធប្រឡាយចាស់ៗនិងកសាងប្រឡាយបន្ថែម សម្រាប់ជាមធ្យោបាយក្នុងការនាំទឹកទៅស្រោចស្រពដីស្រែទាំងអស់បានគ្រប់គ្រាន់។បន្ទាប់ពីកត្តាដីនិងកត្តាទឹកនៅមានកត្តាបច្ចេកទេសដាំដុះថែមទៀត ដោយត្រូវគិតគូរជំរុញការធ្វើស្រែបែបប្រពលវប្បកម្មទំនើប ដូចមានលើកឡើងតាមការវិភាគនៅក្នុងជំពូកទី២ ត្រង់ចំណុចការផ្តល់ឱកាសដោយបច្ចេកវិទ្យាទំនើបដែលកត្តានេះនឹងលើកទឹកចិត្តឱ្យយុវជនចូលរួមក្នុងការងារកសិកម្មបានច្រើនផងដែរ ពីព្រោះយុវជនតែងគិតថាការធ្វើស្រែ នាំឱ្យមានការនឿយហត់ ប្រឡាក់ប្រឡូកដីភក់ មិនស្អាតបាតដែលជាការយល់ខុស តាមពិតការធ្វើស្រែចម្ការតាមបច្ចេកទេសទំនើប កសិករក៏អាចស្លៀកពាក់ស្អាតបាត ពាក់ក្រវាត់កប្រើប្រាស់កុំព្យូទ័រក្នុងបន្ទប់ម៉ាស៊ីនត្រជាក់បានដូចគ្នា ។ ក្នុងការគ្រប់គ្រងប្រព័ន្ធកសិកម្មនៅឃុំក្រយាមិនមែនត្រឹមតែយកចិត្តទុកដាក់តែនៅលើការជំរុញផលិតកម្មកសិកម្ម ដូចខាងលើប៉ុណ្ណោះទេ តែត្រូវខិតខំពង្រឹងការប្រមូលគ្នាចងក្រងជាសហគមន៍កសិករ ដើម្បីជ្រើសរើសតំណាងអាចទៅចូលរួមតស៊ូមតិ នៅក្នុងការចចារកទីផ្សារក៏ដូចជាមួយឈ្មួញដោយធានាការធ្វើស្រែចម្ការបានទិន្នផលខ្ពស់មានគុណភាពតាមស្តង់ដាតម្រូវការទីផ្សារ និងធានាលំនឹងតម្លៃក្នុងទីផ្សារផងដែរ។

តាមការគណនា ដែលផ្អែកទៅលើការការគិតគូរនៅក្នុងជំពូក២ ត្រង់ចំណុច ១.២.៣អាចឱ្យយើងរំពឹងទុកអំពីបរិមាណផលស្រូវនាំចេញនាពេលអនាគតក្នុងអំឡុងពេល១៥ឆ្នាំខាងមុខដូចខាងក្រោមៈ

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ប្រជាពលរដ្ឋកើនឡើងដល់ ១៩ ០៣៣នាក់

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ដីស្រែមានទំហំ ២ ៤៦៨,១០ហិកតា

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ កំណត់ទិន្នផលស្រូវជាមធ្យម ៤ តោនក្នុង១ហិកតា

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ កំនត់ធ្វើស្រែបាន៣ដងក្នុង១ឆ្នាំ

**-ដូច្នេះក្នុងអំឡុងពេល១៥ឆ្នាំ(២០១៧-២០៣១) ផលិតផលស្រូវទទួលបានក្នុង១ឆ្នាំជាមធ្យមៈ**

**២ ៤៦៨,១០ហិកតា x ៤តោន/ហិតា x ៣ដង/ឆ្នាំ = ២៩ ៦១៧ តោន/ឆ្នាំ**

ប្រជាពលរដ្ឋ១នាក់ ត្រូវការអង្ករសម្រាប់ហូបក្នុងមួយឆ្នាំមានចំនួន១៤៣គីឡូក្រាម ដែលបើគិតជាស្រូវត្រូវការចំនួន២២៤ គីឡូក្រាម (ផ្អែកតាមរបាយការណ៍ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ)។

- ក្នុងអំឡុងពេល១៥ឆ្នាំខាងមុខត្រូវការបរិមាណស្រូវសម្រាប់ផ្គត់ផ្គង់ការហូបចុកក្នុងមួយឆ្នាំជាមធ្យម

១៩ ០៣៣នាក់ x ២២៤ គីឡូក្រាម = ៤ ២៦៣ ៣៩២គីឡូក្រាម/ឆ្នាំ

ស្មើនឹងប្រហាក់ប្រហែល **៤ ២៦៣,៣៩តោន/ឆ្នាំ**

- ក្នុងអំឡុងពេល១៥ឆ្នាំខាងមុខត្រូវការបរិមាណពូជស្រូវក្នុងមួយឆ្នាំជាមធ្យមៈ

២ ៤៦៨,១០ហិតា x ៣០០គីឡូក្រាម x ៣ដង/ឆ្នាំ = ២ ២២១ ២៩០ គីឡូក្រាម/ឆ្នាំ

ស្មើនឹងប្រហាក់ប្រហែល **២ ២២១,២៩តោន/ឆ្នាំ**

- ដូច្នេះក្នុងអំឡុងពេល ១៥ ឆ្នាំ ផលិតផលស្រូវទទួលបានសម្រាប់ការនាំចេញក្នុងមួយឆ្នាំជាមធ្យមៈ ២៩៦១៧តោន/ឆ្នាំ - ៤ ២៦៣,៣៩តោន/ឆ្នាំ-២ ២២១,២៩តោន/ឆ្នាំ = ២៣ ១៣២,៣២ តោន/ឆ្នាំ

**- តែបើគិតជាអង្ករវិញអាចនាំចេញបានក្នុងមួយឆ្នាំជាមធ្យមៈ**

**២៣ ១៣២,៣២ តោន/ឆ្នាំ x ៦០%= ១៣ ៨៧៩,៣៩ តោន/ឆ្នាំ**

ខ. ការគ្រប់គ្រងព្រៃឈើ ជលផល និង ធនធានសំខាន់ៗផ្សេងៗទៀត

នាពេលអនាគត នៅក្នុងឃុំក្រយា ត្រូវបានកំណត់តំបន់ប្រើប្រាស់សម្រាប់ដីព្រៃឈើមានទំហំប្រមាណ ៧ ០៥៣,៥៧ហិកតា ស្មើនឹង ០៨ ភាគរយ នៃផ្ទៃដីសរុបនៅក្នុងឃុំ ដែលនៅក្នុងនោះមានព្រៃល្បោះមានទំហំ ៥ ៤៤១,៤៤ហិកតា និងព្រៃស្រោង មានទំហំ ១ ៦១២,១៣ហិកតា ។ ទំហំផ្ទៃដីព្រៃឈើ ០៨% គឺជាចំនួនដ៏ច្រើនដែលត្រូវមានវិធានការគ្រប់គ្រងថែរក្សាឱ្យបានគង់វង្ស ដោយចាំបាច់ត្រូវតែបង្កើតសហគមន៍ព្រៃឈើដែលមានការទទួលស្គាល់តាមផ្លូវច្បាប់ ដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីឱ្យសហគមន៍អាចថែរក្សាព្រៃឈើប្រកប ដោយនិរន្តរភាព និងធានាបាននូវការរក្សាសេវាកម្មបរិស្ថានដែលបានពីព្រៃឈើ ព្រមទាំងមានវិធានការការពារ និងទប់ស្កាត់ភ្លើងឆេះព្រៃ ដែលបង្ករឡើងដោយសកម្មភាពមនុស្សផ្ទាល់ ដោយជនល្មើសនឹងត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើ ។ ទន្ទឹមនេះក៏ត្រូវពិនិត្យមើលដោយកចិត្តដាក់ពីការកាប់បំផ្លាញព្រៃឈើសម្រាប់ការកាន់កាប់យកដីធ្វើកសិកម្មនិងប្រើប្រាស់ផ្សេងៗដោយត្រូវនាំគ្នាគិតថា ការកាប់ព្រៃឈើមួយដើមហាក់បីដូចជាបាត់បង់នូវជម្រកសម្រាប់មនុស្ស សត្វអញ្ចឹងដែរពីព្រោះថាព្រៃឈើជាម្លប់សម្រាប់មនុស្ស សត្វដែលជាធនធានធម្មជាតិមនុស្ស សត្វមិនអាចខ្វះបាន ព្រមទាំងត្រូវពង្រឹងការប្រើប្រាស់ផលិតផលព្រៃឈើនិងព្រៃឈើឱ្យបានត្រឹមត្រូវ ហើយក៏ត្រូវជម្រុញការដាំដើមឈើឡើងវិញទៅលើដីព្រៃដែលឃុំមានទាំងនេះរួមទាំងដាំដើមឈើនៅលើដីសាធារណៈ តាមដងផ្លូវ ប្រឡាយទឹក ទីទួល ទីធ្លាសាលាឃុំ ទីធ្លាសាលារៀន ទីធ្លាមណ្ឌលសុខភាព ទីធ្លានៅតាមវត្តអារាម និងនៅតាមលំនៅឋានជាដើម ។ល។ ដើម្បីឱ្យមានដើមឈើពណ៌បៃតងនៅពាសពេញទូទាំងឃុំបម្រើផលប្រយោជន៍នានាដូចជា ទាក់ទាញទឹកភ្លៀង បញ្ចុះសីតុណ្ហភាព ជួយយើងជៀសផុតពីការកើនឡើងកម្តៅ ជាម្លប់ដ៏ត្រជាក់ មានអាកាសធាតុបរិសុទ្ធ (ផ្តល់ខ្យល់អាកាសបរិសុទ្ធ) បញ្ចេញឧស្ម័នអុកស៊ីសែន (ស្រូបយកឧស្ម័នកាបូននិច និងបញ្ចេញឧស្ម័នអុកស៊ីសែនដល់មនុស្ស) ការពារគ្រោះធម្មជាតិ (ទប់ទល់ខ្យល់ព្យុះ ទឹកជំនន់ ការពារការហូរច្រោះដី និងបាក់ដី)ធ្វើឱ្យដីមានជីជាតិ ជាតំបន់ទេសចរធម្មជាតិ។ ចំណែកព្រៃលិចទឹកជាជម្រកត្រីពង ផ្តល់ជីជាតិដីសម្រាប់ធ្វើកសិកម្ម រក្សាជីវសាស្ត្រចម្រុះ ។

ចំណែកធនធានជលផលនៅក្នុងឃុំវិញ បច្ចុប្បន្នមានតែតាមបែបធម្មជាតិនៅតាមស្ទឹង បឹង ស្រះទឹក និងក្នុងស្រែនារដូវវស្សា ដែលអាចឱ្យប្រជាពលរដ្ឋនៅក្នុងឃុំ អាចទទួលផលជាលក្ខណៈគ្រួសារតែប៉ុណ្ណោះ ។ តែទៅថ្ងៃអនាគត ក៏ត្រូវតែខិតខំយកចិត្តទុកដាក់ក្នុងការចិញ្ចឹមត្រីថែមទៀត តាមស្រះក្តី តាមបៃរក្តី និងតាមបច្ចេកទេសប្រើថង់កៅស៊ូក្តី ដើម្បីបានផលគ្រប់គ្រាន់ផ្តល់ជាប្រភពប្រូតេអ៊ីនសាច់ដ៏សំខាន់សម្រាប់ប្រជាពលរដ្ឋនៅក្នុងឃុំក្រយា។ ចំពោះស្ថានភាពសមស្របក្នុងឃុំគួរចិញ្ចឹមត្រីតាមបែបចិញ្ចឹមនៅក្នុងស្រះខ្នាតតូចស្រះចិញ្ចឹមត្រីតាមគ្រួសារ និងកសិដ្ឋានចិញ្ចឹមត្រីក្នុងស្រែ ដែលជាទម្រង់មួយនៃការបង្កើនបរិមាណត្រី ដោយអាចបង្កើនផលិតភាពជលផលតាមប្រពលវប្បកម្ម (តាមវាលស្រែ) ហើយមានប្រយោជន៍ក្នុងការប្រើត្រីសម្រាប់ទប់ទល់សត្វល្អិត និងដង្កូវហ្វូងនៅក្នុងស្រែ ដែលបំផ្លាញផលដំណាំដូចបានលើកឡើងជាអនុសាសន៍នៅក្នុងជំពូកទី២នៃរបាយការណ៍នេះផងដែរ ។

ចំណែកធនធានសំខាន់ៗផ្សេងទៀតលើសពីការរៀបរាប់ខាងលើនេះ ពុំមានឃើញធនធានណាដែលគួរឱ្យកត់សម្គាល់បានឡើយ ។

### ៣.៤.២.គម្រោងគាំទ្រចាំបាច់ សម្រាប់គាំទ្រនិរន្តរភាព

ដើម្បីមានមធ្យោបាយអាចធ្វើឱ្យសម្រេចបាននូវការគ្រប់គ្រងប្រព័ន្ធកសិកម្មនិងធនធានសំខាន់ៗសម្រាប់ការគាំទ្រទៅដល់និរន្តរភាពនៃការអភិវឌ្ឍន៍ និងអភិរក្ស ដីធ្លីនិងធនធានធម្មជាតិក្នុងឃុំក្រយាចាំបាច់ត្រូវបង្កើតឱ្យមានគម្រោងគាំទ្រជាអាទិភាពមួយចំនួនដូចខាងក្រោម៖

- ជួសជុល និងស្តារប្រព័ន្ធធារាសាស្ត្រ
- ជួសជុល និងថែទាំផ្លូវថ្នល់
- កសាងផ្លូវក្រាលកៅស៊ូ
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម
- បណ្តុះបណ្តាលផលិតជីកំប៉ុស្ត
- បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី
- បណ្តុះបណ្តាលពីការដាំដំណាំស្រូវ
- តបណ្តាញទឹកស្អាតឱ្យបានដល់គ្រប់ភូមិ
- តបណ្តាញអគ្គិសនីអោយបានដល់គ្រប់ភូមិ
- បង្កើតទីលានចាក់សំរាម
- បង្កើតសហគមន៍កសិករ ដើម្បីជំរុញការអនុវត្តន៍ភូមិ១ ផលិតផល១
- ដាក់លូបង្ហូរទឹកតាមមុខផ្ទះនៅជាប់ផ្លូវ
- ដោះស្រាយដីសម្បទានសង្គមកិច្ច
- ជំរុញធ្វើប័ណ្ណក្រីក្រឱ្យដល់ស្ត្រីគ្រប់រូប
- ផ្តល់អាហាររូបត្ថម្ភដល់ស្ត្រី និងកុមារ
- ផ្សព្វផ្សាយពីការចាក់វ៉ាក់សាំងការពារជម្ងឺដល់ស្ត្រីមានផ្ទៃពោះ និងកុមារ
- ពង្រឹងសេវាថែទាំសុខភាព និងព្យាបាលជម្ងឺជូនដល់ប្រជាពលរដ្ឋឱ្យបានល្អប្រសើរឡើង
- ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ
- ផ្សព្វផ្សាយពីច្បាប់ភូមិបាល និងច្បាប់បទដ្ឋានគតិយុត្តនានា ជូនដល់ប្រជាពលរដ្ឋ

## ៣.៥. សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់ ២០៣២)

បើផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវសម្រាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំក្រយាក្នុងឆ្នាំ២០១៧នេះបានឱ្យដឹងថា ឃុំក្រយា ជាឃុំមួយក្នុងចំណោមឃុំ១០ របស់ស្រុកសន្ទុក ខេត្តកំពង់ធំ មានភូមិចំនួន ១៤ និងមានផ្ទៃដីសរុបចំនួន ៨៨ ៥៨២,៥៩ហិកតា ។ នៅក្នុងឆ្នាំ២០១៧ ឃុំក្រយាមានចំនួន ៣ ៨៩៥គ្រួសារ ប្រជាជនសរុប ១៦ ៤៨៩នាក់ ក្នុងនោះស្ត្រី ៨ ៣០៤នាក់ ហើយមានដង់ស៊ីតេប្រជាជនមធ្យម ២៨៨នាក់/គ.ម$^{២}$។ ឃុំក្រយា មានសណ្ឋានភាពដីជាតំបន់ខ្ពង់រាប និងវាលទំនាបលិចទឹកនៅរដូវវស្សា មានប្រភេទក្រុមដីប្រទះឡាង ក្រុមដីបាកាន ក្រុមដីគោកត្រប់ និងក្រុមដីព្រៃខ្មែរ ត្រូវបានប្រើប្រាស់ជាដីស្រែវស្សា ដែលបានផ្តល់នូវមុខរបរសំខាន់ដល់ប្រជាពលរដ្ឋភាគច្រើនរហូតដល់ប្រមាណ ៨៧ភាគរយ សេវាកម្ម ១៣ភាគរយ និងសិប្បកម្ម ១២ភាគរយ ។

ទន្ទឹមនឹងនេះឃុំក្រយាមានប្រឡាយ ១០ខ្សែ ប្រវែង២៤ ៥៨៧,៧៧ម៉ែត្រ ដែលក្នុងនោះមានប្រឡាយមេ ០២ខ្សែ ប្រវែង ១៩២២០,៩៨ ម៉ែត្រ ប្រឡាយរង ០៥ ខ្សែ ប្រវែង ២៣២០,៥៥ ម៉ែត្រ និងប្រឡាយតូច ០៣ ខ្សែ ប្រវែង ៣ ០៤៦,២៤ម៉ែត្រ អូរ ០១ ខ្សែ ប្រវែង ៧៣៦,៤២ ម៉ែត្រ ។ បន្ថែមពីលើនេះ ឃុំក្រយា នៅមានផ្លូវផ្សេងទៀតគ្រប់គ្រាន់អាចភ្ជាប់ទំនាក់ទនងពីភូមិមួយទៅភូមិមួយក្នុងឃុំ និងអាចភ្ជាប់ទំនាក់ទំនងទៅឃុំ និងស្រុកផ្សេង រួមទាំងទីរួមខេត្តកំពង់ធំបានដោយងាយស្រួល ។ ចំពោះកំណើនប្រជាជនវិញបានរកឃើញថា រយៈពេល១៥ឆ្នាំទៅមុខរហូតដល់ឆ្នាំ២០៣២នឹងមានប្រជាជនកើនឡើងរហូតដល់ ១៩ ០៣៣នាក់ ដែលនឹងត្រូវយកចិត្តទុកដាក់គិតគូររកដំណោះស្រាយអំពីការប្រើប្រាស់ដី ដើម្បីឆ្លើយតបបានទៅនឹងតម្រូវការរបស់ប្រជាជន ហើយក៏បានរកឃើញអំពីបញ្ហាប្រឈមមួយចំនួនលើសកម្មភាពនៃការអភិវឌ្ឍន៍ឃុំក្រយាបច្ចុប្បន្នផងដែរ ដូចជា ការធ្វើស្រែ ដែលមានសក្តានុពលក្នុងការអភិវឌ្ឍន៍ឃុំ មិនទាន់ទទួលបានផលស្រូវសមស្របអស់លទ្ធភាពនៅឡើយ ដោយសារតែដីស្រែទាំងនេះកាន់តែខ្សត់ជីជាតិ ខ្វះទឹកស្រោចស្រព សម្រាប់ផ្គត់ផ្គង់ដល់ការធ្វើស្រែបង្កើនរដូវ ខ្វះចំណេះដឹងពីបច្ចេកទេសនៃការដាំដុះ ខ្វះចំណេះដឹងពីបច្ចេកទេសការប្រើប្រាស់ជីគីមី និងថ្នាំពុលកសិកម្ម ប្រព័ន្ធប្រឡាយដែលមានស្រាប់បានរាក់ ខ្វះកម្លាំងពលកម្មដោយសារតែចំណាកស្រុកច្រើនគឺបាត់កម្លាំងពលកម្មជិតពាក់កណ្តាលនៃកម្លាំងពលកម្មដែលមាន និងតម្លៃកសិផល មិនមានស្ថេរភាពដោយឈ្មួញជាអ្នកកំណត់តម្លៃ។ល។ ទន្ទឹមនឹងការរកឃើញបញ្ហាមួយចំនួនលើសកម្មភាពអភិវឌ្ឍឃុំ ក៏បានរកឃើញថា ជាទូទៅការប្រើប្រាស់ដីនៅក្នុងឃុំបច្ចុប្បន្នបានចំទិសដៅនិងសមស្រប ដូចជាការប្រើប្រាស់ដីសម្រាប់លំនៅឋាន កសិកម្ម ប្រព័ន្ធផ្លូវគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រជាដើម ដែលទៅថ្ងៃអនាគត ក៏នៅតែរក្សាមុខងារប្រើប្រាស់ដីទាំងនោះឱ្យនៅដដែល។ បន្ថែមពីលើនេះក៏បានរកឃើញវិធីដោះស្រាយបញ្ហាផ្សេងៗទៀតផងដែរសម្រាប់អនាគត ដូចជាត្រូវសាងសង់បន្ទប់រៀនបន្ថែមពង្រឹងការផ្តល់សេវាសុខាភិបាលឱ្យបានប្រសើរឡើងជំរុញឱ្យប្រជាពលរដ្ឋហូបទឹកស្អាតនិងប្រើប្រាស់បង្គន់អនាម័យ ជួសជុលផ្លូវស្តារប្រឡាយទឹក ដាំដើមឈើនៅតាមទីសាធារណៈ ជំរុញការចិញ្ចឹមត្រីតាមស្រែ។ល។ ជាពិសេសការដោះស្រាយដីសម្រាប់លំនៅឋានដែលមានស្រាប់ ដោយបច្ចុប្បន្ននេះនៅទូលាយអាចផ្គត់ផ្គង់ការសាងសង់លំនៅឋានបាន។ ដើម្បីដោះស្រាយទៅនឹងកំណើនប្រជាជន ត្រូវពង្រឹងការធ្វើស្រែឱ្យបាន ៣ដងក្នុងមួយឆ្នាំ និងធ្វើស្រែតាមបែបប្រពលវប្បកម្ម ដើម្បីបង្កើនទិន្នផលស្រូវឱ្យបានខ្ពស់អស់សក្តានុពល សម្រាប់ផ្គត់ផ្គង់ការហូបចុក និងអាចមានលទ្ធភាពនាំស្រូវចេញបានចំនួន ២៣១៣២,៣២តោន/ឆ្នាំដើម្បីជួយផ្គត់ផ្គង់ទៅដល់ជីវភាពរបស់ប្រជាពលរដ្ឋក្នុងឃុំឱ្យបានកាន់តែប្រសើរឡើងស្របនឹងកំណើនប្រជាពលរដ្ឋ ព្រមទាំងជួយជំរុញកំណើនសេដ្ឋកិច្ចក្នុងឃុំ។ ការរកឃើញភាពសមស្រប និងជម្រើសនៃការប្រើប្រាស់ដីនៅក្នុងឃុំក្រយានាពេលអនាគត បានមកពីការវាយតម្លៃដ៏ត្រឹមត្រូវដោយផ្អែកលើធនធានដី រយៈកម្ពស់ដី ទីជម្រាល ធនធានទឹក ការកាន់កាប់ដី និងសក្តានុពលនៃការប្រើប្រាស់ដីនៅក្នុងឃុំនេះ ដើមដើម្បីធានាថាការប្រើប្រាស់ដីនៅក្នុងឃុំក្រយាទៅអនាគតប្រកបដោយចីរភាព និងសមធម៌ ។

ដូច្នេះ ដើម្បីសម្រេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីនៅក្នុងឃុំក្រយា ស្របទៅតាមស្ថានភាពដីជាក់ស្តែងនិងសក្តានុពលនៃធម្មជាតិ សម្រាប់គាំទ្រកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមប្រកបដោយចីរភាព និងសមធម៌ រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនាពេលអនាគត ដូចដែលបានរកឃើញមានចែងលម្អិតក្នុងរបាយការណ៍បច្ចេកទេសនេះរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធជាពិសេសក្រុមប្រឹក្សាឃុំ ដែលជាតំណាងប្រជាពលរដ្ឋនៅក្នុងឃុំហើយមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅក្នុងឃុំត្រូវខិតខំអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំក្រយា ដែលបានអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការរួច ដោយបញ្ជៀបទៅនិងផែនការអភិវឌ្ឍន៍ឃុំប្រកបដោយប្រសិទ្ធិភាពខ្ពស់បំផុតដើម្បីធានាភាពជោគជ័យនៃផែនការនេះ៕

លេខ៖ ០៧៦១៩/២០២០

បានពិនិត្យ និង សូមគោរពជូន

**លោកអភិបាលនៃគណៈអភិបាលស្រុក និង ជាប្រធានគណៈកម្មាធិការ**

**រៀបចំដែនដី និងនគរូបនីយកម្មស្រុកសន្ទុក មេត្តាពិនិត្យ និង សម្រេច។**

ថ្ងៃ ចន្ទ ១កើត ខែ កត្តិក ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤

ក្រយា ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០២០

មេឃុំក្រយា

**កែវ សេង**

លេខ៖ ២១០៦/៦០

បានពិនិត្យ និង សូមគោរពជូន

**ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និង ជាប្រធានគណៈកម្មាធិការ**

**រៀបចំដែនដី និង នគរូបនីយកម្មខេត្តកំពង់ធំ មេត្តាពិនិត្យ និង សម្រេចដ៏ខ្ពង់ខ្ពស់ ។**

ថ្ងៃ ពុធ ១០កើត ខែ មិគសិរ ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤

សន្ទុក ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០២០

**អភិបាលនៃគណៈអភិបាលស្រុក និង ជាប្រធាន**

**គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកសន្ទុក**

**ទូច សុខា**

លេខ៖ ៥៤៧/២១

**បានឃើញ និងឯកភាពសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ**

ថ្ងៃ ព្រហស្បតិ៍ ៣កើត ខែ ភទ្របទ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

កំពង់ធំ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០២១

**អភិបាលនៃគណៈអភិបាលខេត្ត និងជា**

**ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ**

សុខ លូ

# ឯកសារឧបសម្ព័ន្ធ

# ផែនទីហេដ្ឋារចនាសម្ព័ន្ធ ឃុំក្រយា



# ផែនទីប្រព័ន្ធធារាសាស្ត្រ ឃុំក្រយា




ផែនទីប្រើប្រាស់ដីសាមញ្ញ ឃុំក្រយា
520000 mE
526000
532000
538000
544000
550000
556000 mE
562000
1415000mN
1410000
1405000
1400000
1395000
1390000
1385000
1380000 mN
ស្រែវ៉ៃ
ទឹកពោ
ក្រយា
មីចស្នា
គំពង់ថ្ម
ក្រទា
ជាក់ស្នា
ត្រពាំងឫស្សី
ភ្នំប្រាច់
សូសាង
សែនសេរីមង្គល
បន្ទាយរវៀង
អូរទឹកថ្លា
ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម
ជ
ត
ក
ល
សញ្ញាសម្គាល់
ព្រំប្រទល់ និងទីតាំងរដ្ឋបាល
សាលាឃុំ
ភូមិ
ព្រំប្រទល់រដ្ឋបាលឃុំ
ហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ន
សាលារៀន
វត្ត
មន្ទីរពេទ្យ មណ្ឌលសុខភាព
ផ្លូវជាតិលេខ២៦៤សេ
ផ្លូវគ្រោះក្រហម
ផ្លូវលំ ឬផ្លូវរទេះ
ប្រឡាយមេ
ប្រឡាយរង
ទំនប់ស្តាក់ទឹក
ប្រឡាយតូច
ប្រភេទប្រើប្រាស់ដីបច្ចុប្បន្ន
ដីលំនៅដ្ឋានភូមិ និងហេដ្ឋារចនាសម្ព័ន្ធ
ដីកសិកម្ម
ដីព្រៃ គម្របព្រៃ
ផ្ទៃទឹក
ប្រព័ន្ធកូអរដោនេ
ចំណោលផែនទី : UTM
តំបន់ទី : 48N
ទិន្នន័យយោង : WGS 1984
អេលីបសូអីត : WGS 1984
ប្រភពទិន្នន័យ
-ទីតាំងវិនិយោគ ប្រភពពីផែនការអភិវឌ្ឍឃុំរយៈពេល៥ឆ្នាំនិងអាជ្ញាធរមូលដ្ឋាន
-ទិន្នន័យទីតាំង និងព្រំប្រទល់រដ្ឋបាលប្រភពពីនាយកដ្ឋានភូមិសាស្ត្រនៃ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (២០១៩)
-ទិន្នន័យសំខាន់ៗផ្សេងទៀត ប្រភពពីមន្ទីរ/ស្ថាប័នពាក់ព័ន្ធជុំវិញខេត្ត
បញ្ជាក់
-ព័ត៌មានដែលបង្ហាញនៅលើផែនទីនេះ គឺផ្អែកលើទិន្នន័យដែលបានបង្កើតឡើងដោយ
ថ្នាក់ជាតិនិងត្រូវបានកែសម្រួលដោយបានចូលរួមពីសហគមន៍មូលដ្ឋាន
-ព្រំប្រទល់រដ្ឋបាលទាំងនោះ មិនអាចចាត់ទុកជាផ្លូវការ និងខ្សែបន្ទាត់
ព្រំដែននៃផែនទីនេះ ពុំមានតម្លៃជាផ្លូវការអន្តរជាតិឡើយ
-ផែនទីនេះត្រូវបានបោះពុម្ពនៅ ខែ............... ឆ្នាំ២០....
មាត្រដ្ឋាន ១:១៦០០០០
0
0.៥
១
គីឡូម៉ែត្រ
គាំទ្រដោយ
ADB
GAFSP
អនុវត្តដោយ
562000 mE


ផែនទីគម្រោងវិនិយោគ ឃុំក្រយា
សញ្ញាសម្គាល់
ព្រំប្រទល់ និងទីតាំងរដ្ឋបាល
សាលាឃុំ
ភូមិ
ព្រំប្រទល់រដ្ឋបាលឃុំ
ហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ន
សាលារៀន
វត្ត
មន្ទីរពេទ្យ មណ្ឌលសុខភាព
ផ្លូវជាតិលេខ២៦៤សេ
ផ្លូវគ្រោះក្រហម
ផ្លូវលំ ឬផ្លូវរទេះ
ប្រឡាយមេ
ប្រឡាយរង
ទំនប់ស្តាក់ទឹក
ប្រឡាយតូច
ប្រភេទប្រើប្រាស់ដីបច្ចុប្បន្ន
ដីលំនៅដ្ឋានភូមិ និងហេដ្ឋារចនាសម្ព័ន្ធ
ដីកសិកម្ម
ដីព្រៃ គម្របព្រៃ
ផ្ទៃទឹក
គម្រោងវិនិយោគ
ជួសជុលផ្លូវគ្រួសក្រហម
ស្តារប្រឡាយស្រោចស្រព
ប្រព័ន្ធកូអរដោនេ
ចំណោលផែនទី : UTM
តំបន់ទី : 48N
ទិន្នន័យយោង : WGS 1984
អេលីបសូអ៊ីត : WGS 1984
ប្រភពទិន្នន័យ
-ទីតាំងវិនិយោគ ប្រភពពីផែនការអភិវឌ្ឍឃុំរយៈពេល៥ឆ្នាំនិងអាជ្ញាធរមូលដ្ឋាន
-ទិន្នន័យទីតាំង និងព្រំប្រទល់រដ្ឋបាលប្រភពពីនាយកដ្ឋានភូមិសាស្ត្រនៃ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (២០១៩)
-ទិន្នន័យសំខាន់ៗផ្សេងទៀត ប្រភពពីមន្ទីរ/ស្ថាប័នពាក់ព័ន្ធជុំវិញខេត្ត
បញ្ជាក់
-ព័ត៌មានដែលបង្ហាញនៅលើផែនទីនេះ គឺផ្អែកលើទិន្នន័យដែលបានបង្កើតឡើងដោយ
ថ្នាក់ជាតិនិងត្រូវបានកែសម្រួលដោយបានចូលរួមពីសហគមន៍មូលដ្ឋាន
-ព្រំប្រទល់រដ្ឋបាលទាំងនោះ មិនអាចចាត់ទុកជាផ្លូវការ និងខ្សែបន្ទាត់
ព្រំដែននៃផែនទីនេះ ពុំមានតម្លៃជាផ្លូវការអន្តរជាតិឡើយ
-ផែនទីនេះត្រូវបានបោះពុម្ពនៅ ខែ............... ឆ្នាំ២០....
មាត្រដ្ឋាន ១:១៦០០០០
0 0.៥ ១
គីឡូម៉ែត្រ
គាំទ្រដោយ
ADB
GAFSP
អនុវត្តដោយ
520000 mE
526000
532000
538000
544000
550000
556000 mE
562000
1415000 mN
1410000
1405000
1400000
1395000
1390000
1385000
1380000 mN
ឃុំស្រង៉ែ
ឃុំទីទែ
ឃុំសុចិត្រ
ឃុំទីពោ
ឃុំបឹងល្វា
ឃុំក្រយា
ឃុំជាក់ស្លា
ត្រពាំងឫស្សី
ភ្នំប្រាច់
ស្វាយ
ដងក្តារ
ក្រយា
តាមិញ
ត្រពាំងព្រីង
សុភមង្គល
សែនសិរីមង្គល
ថ្នល់ល្បៀង
បន្ទាយអង្គ
អូរទឹកថ្លា
ជ
ត
ក
ល

# ឯកសារឧបសម្ព័ន្ធ





សកម្មភាពក្រុមការងារចូលរួមប្រជុំទទួលការណែនាំពីនីតិវិធីរៀបចំផែនការប្រើប្រាស់ដីថ្នាក់ឃុំ ពីប្រធានគ្រប់គ្រងគម្រោងរបស់ក្រុមហ៊ុន





សកម្មភាពប្រមូលទិន្នន័យនៅតាមមន្ទីរជុំវិញខេត្តរបស់ក្រុមការងារក្រុមហ៊ុន SBK





កិច្ចប្រជុំពិភាក្សាអំពីផែនទីប្រើប្រាស់ដីបច្ចុប្បន្នឃុំក្រយា




សកម្មភាពក្រុមការងារចុះទីវាលស្រង់ទិន្នន័យបំពេញបន្ថែមលើ
ផែនទីប្រើប្រាស់ដីបច្ចុប្បន្នដែលមានស្រាប់ឃុំក្រយា




សកម្មភាពចូលរួមត្រួតពិនិត្យ ណែនាំ ការអនុវត្តគម្រោងរបស់អង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ (NIO)




កិច្ចប្រជុំក្រុមប្រឹក្សាឃុំក្រយា ដើម្បីពិនិត្យ និងឯកភាពទៅលើសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំក្រយា





កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកសន្ទុក ដើម្បីពិនិត្យ និងឯកភាពទៅលើ សេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំក្រយា





កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ ដើម្បីពិនិត្យ និងឯកភាពទៅលើសេចក្តី ព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំក្រយា




ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលស្រុកសន្ទុក
ក្រុមប្រឹក្សាឃុំក្រយា

ថ្ងៃ.....[illegible].......ខែ.[illegible]...ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
...[illegible].....ថ្ងៃទី...២៣...ខែ...ធ្នូ.......ឆ្នាំ២០២០...

**សេចក្តីជូនដំណឹង**
**ស្តីពីការបិទផ្សាយជាសាធារណៈផែនការប្រើប្រាស់ដីអនាគតឃុំក្រយា**

យោង: - កិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ រវាងរាជរដ្ឋាភិបាលកម្ពុជានិងធនាគារអភិវឌ្ឍន៍អាស៊ី (ADB )។
- កិច្ចសន្យាលេខ CON-LUP/RICE-SDP/CLUP/MUMUPC/CS/ ០១ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៧ រវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយក្រុមហ៊ុន SBK Research & Development Co.,Ltd។
- អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។
- តម្រូវការចាំបាច់នៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។

ន័យដូចបានជម្រាបជូនក្នុងសេចក្តីយោងខាងលើ និងស្របតាមការរៀបចំផែនការប្រើប្រាស់ដី និងលទ្ធផលការងារដែលសម្រេចបានទៅតាមនីតិវិធីនាពេលកន្លងមកក្រុមប្រឹក្សាឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ សូមគោរពជម្រាបជូនដល់គ្រប់ស្ថាប័ន អង្គការសង្គមស៊ីវិល ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់មេត្តាជ្រាបថា៖ នៅថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០២០.. ដល់ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០២១.. ឃុំក្រយា ធ្វើការរៀបចំបិទផ្សាយជាសាធារណៈនូវឯកសារ និងផែនការប្រើប្រាស់ដីអនាគតដែលសម្រេចបាន នៅទីតាំងសាលាឃុំខាងលើដើម្បីធ្វើការពិនិត្យ កែលម្អ និងផ្តល់យោបល់ ។

អាស្រ័យហេតុនេះ សូមបងប្អូនប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធមេត្តាជួយផ្សព្វផ្សាយ និងចូលរួមពិនិត្យ ផ្តល់យោបល់អោយបានចុះករ កុំបីអាក់ខានឡើយ ។

សូមបងប្អូនជនរួមជាតិ មេត្តាទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ ។

ប្រធានក្រុមប្រឹក្សា
ឃុំក្រយា

កែម ឆេង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលស្រុកសន្ទុក
ក្រុមប្រឹក្សាឃុំ ក្រយា

**របាយការណ៍សង្ខេប**
**លទ្ធផល នៃការបិទផ្សាយជាសាធារណៈ នូវឯកសារផែនទី និង**
**សៀវភៅផែនការប្រើប្រាស់ដីនៅក្នុងឃុំ ក្រយា**

យោង: - កិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១៣ រវាង រាជរដ្ឋាភិបាលកម្ពុជានិងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។
- កិច្ចសន្យាលេខ CON-LUP/RICE-SDP/CLUP/MUMUPC/CS/ ០១ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០១៧ រវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយក្រុមហ៊ុន SBK Research & Development Co.,Ltd។
- អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។
- ក្រុមប្រឹក្សាឃុំក្រយា បានបិទផ្សាយជាសាធារណៈនៅទីតាំង សាលាឃុំក្រយា នូវឯកសារផែនទី និង សៀវភៅពង្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំក្រយា (បានប្រជុំអនុម័តថ្នាក់ស្រុកសន្ទុក រួចរាល់ជាស្ថាពរ) ចាប់ពីថ្ងៃទី២៣.ខែ.ធ្នូ.........ឆ្នាំ ២០២០. ដល់ថ្ងៃទី..០៥....ខែ.កុម្ភៈ.....ឆ្នាំ ២០២១. មានរយៈពេល ៤៥ ថ្ងៃជាលទ្ធផលមានដូចខាងក្រោម៖

**១. ផែនទីប្រើប្រាស់ដីនៅក្នុងឃុំ ក្រយា**

- បានធ្វើការបិទផ្សាយផែនទីប្រើប្រាស់ដីលម្អិតបច្ចុប្បន្ន មានទំហំជាខ្នាត A0
- បានធ្វើការបិទផ្សាយផែនទីប្រើប្រាស់ដីអនាគតសម្រាប់រយៈពេល ១៥ឆ្នាំ ២០១៧ ដល់ ២០៣២ មានទំហំជាខ្នាត A0
- **ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន**

**២. សៀវភៅផែនការប្រើប្រាស់ដីនៅក្នុងឃុំ ក្រយា**

- ជំពូក ១ ៖ ព័ត៌មានស្តីពី ស្ថានភាពឃុំក្រយា
  - ចាប់ពី ១.១. ស្ថានភាពទូទៅ ១.១.១. ទីតាំងរដ្ឋបាលឃុំ រហូតដល់ ១.៤. ទីផ្សារ និង ខ្សែសង្វាក់ផលិតផល ១.៤.៣. ឧបសគ្គ និង ឱកាស។
  - **ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន**
- ជំពូក ២ ៖ ការវិភាគតម្រូវការ សក្តានុពល និង ឧបសគ្គសម្រាប់អនាគត
  - ចាប់ពី ២.១. តម្រូវការសម្រាប់អនាគត់ ២.១.១. ផែនការអភិវឌ្ឍន៍ឃុំ រហូតដល់ ២.៥. បញ្ហា មូលហេតុ និង ដំណោះស្រាយ។
  - **ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន**
- ជំពូក ៣ ៖ ផែនការប្រើប្រាស់ដីសម្រាប់ពេលអនាគត ឆ្នាំ២០១៧ ដល់ ២០៣២
  - ចាប់ពី ៣.១. តម្រូវការ ស្ថានភាព និង សក្តានុពលជាក់ស្តែង ៣.១.១. តម្រូវការដីទៅតាមប្រភេទ រហូតដល់ ៣.៥. សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់ ២០៣២)
  - **ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន**

- **ការវាយតម្លៃ** : ផ្អែកតាមឯកសារភស្តុតាង និងទិន្នន័យជាក់ស្តែង ដែលប្រមូលបាន លទ្ធផលនៃការបិទផ្សាយសាធារណៈនូវឯកសារ ផែនទី និង សៀវភៅពង្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ ក្រយា សម្រាប់ឆ្នាំ ២០១៧ ដល់ ២០៣២ ជាយោបល់គួរដាក់ជូនគណៈកម្មាធិការរៀបចំដែនដី និង នគរូបនីយកម្មខេត្តកំពង់ធំ ដើម្បីពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។

ថ្ងៃ.....[illegible].........ខែ.[illegible].....ឆ្នាំ.[illegible]..........ស័ក ព.ស. ២៥៦៤
ក្រយា ថ្ងៃទី..០៥...ខែ..កុម្ភៈ.......ឆ្នាំ ២០២១

ប្រធានក្រុមប្រឹក្សាឃុំ និងជាមេឃុំក្រយា

កែម ឆេង

សកម្មភាពផ្សព្វផ្សាយជាសាធារណៈសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំក្រយា

# ឯកសារយោង

# ឯកសារយោង

១. ឯកសារព័ត៌មានស្ថានភាពឃុំក្រយាស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៣ របស់មន្ទីរផែនការខេត្ត
២. ឯកសារព័ត៌មានស្ថានភាពឃុំក្រយាស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៤ របស់មន្ទីរផែនការខេត្ត
៣. ឯកសារព័ត៌មានស្ថានភាពឃុំក្រយាស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៥ របស់មន្ទីរផែនការខេត្ត
៤. ឯកសារព័ត៌មានស្ថានភាពឃុំក្រយាស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៦ របស់មន្ទីរផែនការខេត្ត
៥. ឯកសារព័ត៌មានស្ថានភាពឃុំក្រយាស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៧ របស់មន្ទីរផែនការខេត្ត
៦. ផែនការអភិវឌ្ឍឃុំរយៈពេលប្រាំឆ្នាំ(២០១៨-២០២២)របស់ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ
៧. កម្មវិធីវិនិយោគឃុំក្រយា ឆ្នាំ២០១៧ របស់ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ
៨. របាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ឆ្នាំ២០១៧
៩. ផែនការអភិវឌ្ឍស្រុករយៈពេលប្រាំឆ្នាំ(២០១៨-២០២២) របស់ស្រុកសន្ទុក ខេត្តកំពង់ធំ
១០. អនុក្រឹត្យស្តីពីការកំណត់ដែនព្រៃលិចទឹក ៦៤៧,៤០៦ហិកតា ស្ថិតនៅក្នុងខេត្តទាំង៦ជុំវិញបឹងទន្លេសាប (កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប)
១១. អនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ៨៨.អនក្រ.បក ស្តីពីការបង្កើតតំបន់ការពារទេសភាពទំនាបខាងជើងទន្លេសាប។